**Penicillinដែលមានសកម្មភាពខ្លី :** មានឈ្មោះជាច្រើន ដូចជា Crystallin penicillin, benzylpenicillin, Penicillinទឹក Penicillinសម្រាប់លាយ, Sodium penicillin, potassium penicillin និង Penicillin G។ Penicillinទាំងនេះ មានសកម្មភាពយ៉ាងលឿន ប៉ុន្តែស្ថិតនៅក្នុងខ្លួនរយៈពេលខ្លី ដូច្នេះគេត្រូវចាក់រាល់៦ម៉ោងម្តង(៤ដងក្នុង១ថ្ងៃ)។ Penicillinដែលមានសកម្មភាពខ្លី គឺជាជម្រើសដ៏ប្រសើរបំផុតសម្រាប់ការបង្ករោគធ្ងន់ធ្ងរ ដែលត្រូវការPenicillinក្នុងកម្រិតខ្ពស់។ ឧទាហរណ៍ ដូចជាក្នុងករណីដំបៅរលួយ ឬការបាក់ឆ្អឹងដែលមានធ្លាយស្បែក ឬជំងឺរលាកស្រោមខួរ ជាដើម។

**Penicillinមានសកម្មភាពមធ្យម :** Procaine penicillin ឬ Procaine penicillin aluminum monostearate(PAM)។ ថ្នាំនេះមានសកម្មភាពយឺតបន្តិច ហើយស្ថិតនៅក្នុងខ្លួនរយៈពេលប្រហែល១ថ្ងៃ ដូច្នេះគេគួរចាក់មួយថ្ងៃម្តង។ Procaine penicillin ឬការរួមផ្សំប្រូកាអ៊ីនជាមួយPenicillinដែលមានសកម្មភាពខ្លី គឺជាជម្រើសដ៏ប្រសើរបំផុតសម្រាប់ការបង្ករោគភាគច្រើន ដែលត្រូវការPenicillinចាក់។

**Penicillinដែលមានសកម្មវែង :** Benzathine penicillin។ ជាប្រភេទPenicillinដែលមានសកម្មភាពយឺតៗនៅក្នុងខ្លួនមនុស្ស ហើយមានប្រសិទ្ធភាពដល់ទៅ១ខែ។ ការប្រើប្រាស់ជាចំបងនៃPenicillinប្រភេទនេះ គឺសម្រាប់ព្យាបាលជំងឺរលាកបំពង់ក ជំងឺស្វាយ និងគ្រុនរលាកសន្លាក់។ វាមានប្រយោជន៍សម្រាប់អ្នកដែលនៅឆ្ងាយពីអ្នកដែលអាចធ្វើការចាក់ថ្នាំ ឬអ្នកជំងឺដែលមិនអាចលេបថ្នាំតាមមាត់បាន។ ចំពោះការបង្ករោគស្រាល ការចាក់តែ១ម្តុលអាចគ្រប់គ្រាន់។ Benzathine penicillinច្រើនលាយជាមួយPenicillinដែលមានសកម្មភាពលឿន។

<u>Crystallin penicillin</u> ( Penicillinដែលមានកម្មរយៈពេលខ្លី )

ឈ្មោះ______________តម្លៃ_________សម្រាប់________

ច្រើនតែជាដប ១លានអ៊ុយនីតេ(៦២៥ម.ក្រ) ឬ ៥លានអ៊ុយនីតេ (៣១២៥ម.ក្រ)

***កម្រិតប្រើ*** Crystallin penicillin ឬគ្រប់ប្រភេទ Penicillinដែលមានសកម្មភាពខ្លី សម្រាប់ជំងឺធ្ងន់ :

ចាក់រាល់ ៤ម៉ោងម្តង រយៈពេល១០-១៤ថ្ងៃ។

រាល់ពេលចាក់ សូមឲ្យ :
- មនុស្សធំឬកុមារអាយុលើសពី៨ឆ្នាំ : ១លានអ៊ុយនីតេ
- កុមារអាយុពី៣-៥ឆ្នាំ : ៥០០.០០០អ៊ុយនីតេ
- កុមារអាយុក្រោម៣ឆ្នាំ : ២៥០.០០០អ៊ុយនីតេ

សម្រាប់ជំងឺរលាកស្រោមខួរ និងជំងឺធ្ងន់ធ្ងរមួយចំនួនទៀត គួរឲ្យទ្វេរដងនៃកម្រិតនេះ។

<u>Procaine penicillin</u> ( សកម្មភាពមធ្យម )

ឈ្មោះ______________តម្លៃ_________សម្រាប់________

ច្រើនតែជាដប ៣០០.០០០អ៊ុយនីតេ ៤០០.០០០អ៊ុយនីតេ ឬលើសពីនេះ

***កម្រិតប្រើ*** Procaine penicillin សម្រាប់ជំងឺមធ្យម :

ចាក់១ថ្ងៃ ១ម្តុល រយៈពេល១០ ទៅ១៥ថ្ងៃ។ ចាក់ម្តង :
- មនុស្សធំ : ៦០០.០០០ ទៅ ១.២០០.០០០អ៊ុយនីតេ
- កុមារអាយុពី៨-១២ឆ្នាំ : ៦០០.០០០អ៊ុយនីតេ
- កុមារអាយុពី៣-៧ឆ្នាំ : ៣០០.០០០អ៊ុយនីតេ
- កុមារអាយុក្រោម៣ឆ្នាំ : ១៥០.០០០អ៊ុយនីតេ
- ទារក សូមកុំប្រើ លើកលែងតែគ្មានPenicillin ឬ Ampicillinផ្សេងទៀត។ ក្នុងពេលអាសន្ន សូមប្រើ ៧៥.០០០អ៊ុយនីតេ។

សម្រាប់ជំងឺធ្ងន់ធ្ងរ ប្រើមួយទ្វេរជាពីរនៃកម្រិតខាងលើ។ ទោះជាយ៉ាងនេះក៏ដោយ គួរប្រើPenicillinដែលមានកម្មភាពខ្លី។

Procaine penicillinដែលផ្សំជាមួយPenicillinដែលមានសកម្មភាពខ្លី មាន ***កម្រិតប្រើ*** ដូចគ្នានឹងProcaine penicillin តែឯង។

ចំពោះការព្យាបាលជំងឺប្រមេះទឹកបាយដែលមិនស៊ាំជាមួយ Penicillin Procaine penicillinគឺជាការប្រសើរបំផុត។ គេត្រូវការកម្រិតយ៉ាងខ្ពស់។ ចំពោះកម្រិតប្រើ សូមអានទំ.៣៦០។ ចំពោះជំងឺរលាករោងត្រគាក កម្រិតប្រើដូចគ្នានឹងជំងឺប្រមេះទឹកបាយ។

<u>Benzathine benzylpenicillin</u>( សកម្មភាពយូរ )

ឈ្មោះ______________តម្លៃ_________សម្រាប់________

ច្រើនតែជាដប ១.២០០.០០០ ឬ ២.៤០០.០០០អ៊ុយនីតេ

***កម្រិតប្រើ*** Benzathine penicillin សម្រាប់ជំងឺស្រាលទៅធ្ងន់:

ចាក់រាល់ ៤ម៉ោងម្តង។ ចំពោះជំងឺស្រាល ១ម្តុល អាចគ្រប់គ្រាន់។

មនុស្សធំ : ១.២០០.០០០ ទៅ ២.៤០០.៤០០អ៊ុយនីតេ
កុមារអាយុពី៨-១២ឆ្នាំ : ៩០០.០០០អ៊ុយនីតេ
កុមារអាយុពី១-៧ឆ្នាំ : ៣០០.០០០ ទៅ ៦០០.០០០អ៊ុយនីតេ

ចំពោះជំងឺរលាកបំពង់ក ចាក់១ម្តុល ក្នុងកម្រិតខាងលើ។

ដើម្បីបង្ការការលាប់ឡើងវិញ ចំពោះអ្នកធ្លាប់កើតជំងឺគ្រុនរលាកសន្លាក់ ចាក់កម្រិតខាងលើ រៀងរាល់៤សប្តាហ៍ម្តង (មើលទំ.៣១០)។

ចំពោះការព្យាបាលជំងឺស្វាយ Benzathine benzylpenicillin គឺជាជម្រើសល្អជាងគេ។ ចំពោះកម្រិតប្រើ សូមមើលទំ.២៣៨។

## Ampicillin និង Amoxicillin : Penicillinដែលមានប្រសិទ្ធភាពទូលំទូលាយ

<u>Ampicillin</u>

ច្រើនជាថ្នាំទឹកសម្រាប់ផឹក :

១២៥ ឬ២៥០ម.ក្រ/ស្លាបព្រាកាហ្វេ តម្លៃ____សម្រាប់____
ថ្នាំគ្រាប់ : ២៥០ម.ក្រ តម្លៃ____សម្រាប់____
ថ្នាំចាក់ : ៥០០ម.ក្រ តម្លៃ____សម្រាប់____

<u>Amoxicillin</u>

ច្រើនជាថ្នាំគ្រាប់ :
២៥០ ឬ ៥០០ម.ក្រ តម្លៃ______សម្រាប់______

ថ្នាំទឹក :
១២៥ម.ក្រ ក្នុង៥ម.ល តម្លៃ______សម្រាប់______
ឬ ២៥០ម.ក្រ ក្នុង៥ម.ល តម្លៃ______សម្រាប់______

Penicillinដែលមានប្រសិទ្ធភាពទូលាយទាំងនេះ អាចសម្លាប់មេរោគជាច្រើនប្រភេទ ជាងPenicillinដទៃទៀត។ វាមានសុវត្ថិភាពជាងអង់ទីប៊ីយ៉ូទិកដែលមានប្រសិទ្ធភាពទូលាយផ្សេងៗទៀត ហើយមានប្រយោជន៍ពិសេសសម្រាប់ទារកនិងកុមារតូចៗ។

Ampicillin និងAmoxicillin តែងតែអាចប្រើជំនួសគ្នាបាន។ នៅពេលដែលអ្នកឃើញការសំណូមពរឲ្យប្រើប្រាស់Ampicillin នៅក្នុងសៀវភៅនេះ អ្នកតែងតែអាចប្រើAmoxicillinជំនួស ក្នុងកម្រិតដែលត្រឹមត្រូវមួយ(មើលខាងក្រោម)។ ប៉ុន្តែ**មិនត្រូវប្រើAmoxicillinជាថ្នាំលេបទេ នៅពេលគេតម្រូវឲ្យប្រើAmpicillin ចាក់នោះ**(Amoxicillinមិនមានជាថ្នាំចាក់ទេ)។ ហើយក៏សូមចំណាំដែរថា Amoxicillinអាចមិនសូវមានប្រសិទ្ធភាពប្រឆាំងនឹងការបង្ករោគដោយស៊ីហ្សែលឡា។ ប្រើAmpicillin ឬអង់ទីប៊ីយ៉ូទិកផ្សេងទៀតវិញ(មើលទំ.១៥៨)។

Ampicillin និងAmoxicillin ថ្លៃជាងPenicillin ហើយវាអាចធ្វើឲ្យមានរាក ឬផ្សិតក្នុងមាត់។ ដូច្នេះ គេមិនគួរប្រើវាសម្រាប់ការបង្ករោគដែលអាចព្យាបាលដោយPenicillinទេ(មើលទំ. ៥៨)។

Ampicillinមានប្រសិទ្ធភាពល្អ ពេលប្រើជាថ្នាំលេប។ ការចាក់គួរតែប្រើសម្រាប់ជំងឺធ្ងន់ធ្ងរប៉ុណ្ណោះ ដូចជាជំងឺរលាកស្រោមខួរ និងរលាកស្រោមពោះ និងជំងឺរលាកខ្នែងពោះវៀន ឬនៅពេលដែលអ្នកជំងឺក្អួត ឬមិនអាចលេបថ្នាំបាន។

Ampicillin និងAmoxicillinច្រើនមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺរលាកសួត ឬការបង្ករោគក្នុងត្រចៀក លើកុមារអាយុក្រោម៦ឆ្នាំ ជំងឺរលាកផ្លូវនោមធ្ងន់ធ្ងរ ជំងឺប្រមេះទឹកបាយ និងជំងឺគ្រុនពោះវៀន (បើវាស៊ាំជាមួយថ្នាំក្លរំហ្វេនីកុល)។ Ampicillinក៏មានប្រយោជន៍ចំពោះការព្យាបាលការបង្ករោគក្នុងឈាម និងជំងឺទារកដែលគ្មានមូលហេតុច្បាស់លាស់ ជំងឺរលាកស្រោមខួរ ជំងឺរលាកស្រោមពោះ និងជំងឺរលាកខ្នែងពោះវៀន។

អ្នកដែលមានប្រតិកម្មជាមួយPenicillin មិនគួរប្រើAmpicillin ឬAmoxicillinទេ។ សូមអាន គ្រោះថ្នាក់និងការប្រុងប្រយ័ត្នចំពោះPenicillinគ្រប់ប្រភេទ នៅទំ.៣៥១។

***កម្រិតប្រើ*** សម្រាប់Ampicillin និងAmoxicillin :

**ជាថ្នាំលេប** (២៥-៥០ម.ក្រ/គ.ក្រ/ថ្ងៃ): គ្រាប់ ២៥០ម.ក្រ ស៊ីរ៉ូ ១២៥ម.ក្រ ក្នុង១ស្លាបព្រាកាហ្វេ(៥ម.ល)

Ampicillin : ឲ្យ៤ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ
Amoxicillin : ឲ្យ៣ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ២គ្រាប់ ឬ៤ស្លាបព្រាកាហ្វេ(៥០០ម.ក្រ)
- កុមារអាយុពី៨-១២ឆ្នាំ : ១គ្រាប់ ឬ២ស្លាបព្រាកាហ្វេ (២៥០ម.ក្រ)
- កុមារអាយុពី៣-៧ឆ្នាំ : កន្លះគ្រាប់ ឬ១ស្លាបពាក្រាហ្វេ (១២៥ម.ក្រ)
- កុមារអាយុក្រោម៣ឆ្នាំ : ១/៤គ្រាប់ ឬពាក់កណ្តាលស្លាបព្រាកាហ្វេ(៦២ម.ក្រ)
- ទារក : ឲ្យដូចកុមារអាយុក្រោម៣ឆ្នាំ

ចំពោះជំងឺគ្រុនពោះវៀនដែលស៊ាំនឹងថ្នាំChloramphenicol បើគ្មានAmpicillinចាក់ទេ ឲ្យAmpicillinលេបចំនួន ២០០ម.ក្រ/គ.ក្រ/ថ្ងៃ ឬAmoxicillin ១០០ម.ក្រ/គ.ក្រ/ថ្ងៃ បាន។

ចំពោះការបង្ករោគដោយប្រមេះទឹកថ្លា មើលកម្រិតប្រើថ្នាំនៅទំ.៣៦០។

***កម្រិតប្រើ*** ថ្នាំAmpicillin :

**តាមការចាក់** : សម្រាប់ជំងឺធ្ងន់(៥០-១០០ម.ក្រ/គ.ក្រ/ថ្ងៃ ដល់ ៣០០ម.ក្រ/គ.ក្រ/ថ្ងៃ សម្រាប់ជំងឺរលាកស្រោមខួរ): ដប ៥០០ម.ក្រ

ឲ្យ ៤ដងក្នុង១ថ្ងៃ ៦ម៉ោងម្តង រយៈពេល១០-១៤ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ៥០០-១០០០ម.ក្រ (១ឬ២ដប ២៥០ ម.ក្រ)
- កុមារអាយុពី៨-១២ឆ្នាំ : ២៥០ម.ក្រ(១/២ដប ៥០០ ម.ក្រ)
- កុមារអាយុពី៣-៧ឆ្នាំ : ២៥ម.ក្រ(១/៤នៃដប ៥០០ ម.ក្រ)
- កុមារអាយុក្រោម៣ឆ្នាំ : ៦២ម.ក្រ(១/៨នៃដប ៥០០ ម.ក្រ)
- ទារក ១២៥ម.ក្រ(១/៤នៃដប៥០០ម.ក្រ) ចំនួនតែ **២ដង** ក្នុង១ថ្ងៃប៉ុណ្ណោះ។

## Penicillin ជាមួយ Streptomycin

ថ្នាំដែលរួមបញ្ចូលPenicillinជាមួយ Streptomycin ជាថ្នាំPenicillinជាមួយ គឺមាននៅក្នុងប្រទេសជាច្រើន និងត្រូវបានប្រើប្រាស់ជាញឹកញាប់។ បើថ្នាំណាមួយក្នុងចំណោមថ្នាំទាំងនេះ ត្រូវបានប្រើយ៉ាងទូលំទូលាយនៅក្នុងតំបន់របស់អ្នក សូមសរសេរឈ្មោះ ធាតុផ្សំ និងតម្លៃរបស់វាក្នុងចន្លោះខាងក្រោម :

ឈ្មោះ__________________Penicillinប៉ុន្មានម.ក្រ______

Streptomycinប៉ុន្មានម.ក្រ_______តម្លៃ______សម្រាប់_____

**Penicillin និង Streptomycin គួរប្រើចូលគ្នាតែក្នុងករណីសំខាន់ដែលមិនអាចរកAmpicillinបាន ឬថ្លៃពេក។ វាមិនគួរត្រូវបានប្រើសម្រាប់ការបង្ករោគបន្តិចបន្តួច ឬជំងឺផ្តាសាយធម្មតាទេ។**

ការប្រើStreptomycinជាញឹកញាប់ជាមួយជំងឺផ្សេងៗ ក្រៅពីជំងឺរបេង ធ្វើឲ្យបាក់តេរីជំងឺរបេងនៅក្នុងសហគមន៍ មានភាពស៊ាំជាមួយStreptomycin ហើយធ្វើឲ្យកាន់តែពិបាកព្យាបាល។ ម្យ៉ាងទៀត Streptomycinអាចធ្វើឲ្យថ្លង់បាន។

PenicillinជាមួយStreptomycinអាចប្រើបានចំពោះជំងឺជាច្រើនដែលព្យាបាលដោយAmpicillin(មើលទំ.៣៥៣) ប៉ុន្តែ Ampicillinមានសុវត្ថិភាពជាង ជាពិសេសចំពោះទារក។

តាមធម្មតា វាមានតំលៃថោកជាង ហើយងាយជាងក្នុងការគណនាកម្រិតនៃការប្រើថ្នាំ បើStreptomycinនិងPenicillinត្រូវបានចាក់ដាច់ពីគ្នា ជាជាងការចាក់រួមចូលគ្នា។

***កម្រិតប្រើ*** Penicillin ជាមួយ Streptomycin **សម្រាប់ជំងឺធ្ងន់ធ្ងរ :**

ឲ្យPenicillinដែលមានសកម្មភាពខ្លី យ៉ាងហោចណាស់ ២៥.០០០អ៊ុយនីតេ/គ.ក្រ ៤ដងក្នុង១ថ្ងៃ ហើយStreptomycin មិនឲ្យលើស ៣០-៥០ម.ក្រ/គ.ក្រ/ថ្ងៃ។

ចំពោះទារក ឲ្យPenicillinដែលមានសកម្មភាពខ្លី ៥០.០០០អ៊ុយនីតេ/គ.ក្រ ២ដង ១ថ្ងៃ ជាមួយនឹង Streptomycin ២០ម.ក្រ/ គ.ក្រ ១ដង ១ថ្ងៃ។

| | Penicillinដែលមានសកម្មភាពខ្លី | Streptomycin |
|---|---|---|
| មនុស្សធំ | ១.០០០.០០០ អ៊ុយនីតេ ៤-៦ដង ១ថ្ងៃ | ១ក្រ (ធម្មតា២ ម.ល)១ដង ១ថ្ងៃ |
| កុមារ អាយុពី ៨-១២ឆ្នាំ | ៥០០.០០០ អ៊ុយនីតេ ៤-៦ដង ១ថ្ងៃ | ៧៥០ម.ក្រ (១ ១/២ ម.ល) ១ដង ១ថ្ងៃ |
| កុមារ អាយុពី ៣-៧ឆ្នាំ | ២៥០.០០០ អ៊ុយនីតេ ៤-៦ដង ១ថ្ងៃ | ៥.០០០ម.ក្រ (១ម.ល) ១ដង ១ថ្ងៃ |
| កុមារ អាយុក្រោម៣ឆ្នាំ | ១២៥.០០០ អ៊ុយនីតេ ៤-៦ដង ១ថ្ងៃ | ២៥០ម.ក្រ(១/២ ម.ល) ១ដង ១ថ្ងៃ |
| ទារក | ១២៥.០០០ អ៊ុយនីតេ ២ដង ១ថ្ងៃ | ៦០ម.ក្រ(១/៨ម.ល) ១ដង ១ថ្ងៃ |

**សម្រាប់ជំងឺធ្ងន់ធ្ងរ :** ដូចជា ជំងឺរលាកស្រោមពោះ រលាកខ្នែងពោះវៀន រលាកស្រោមខួរ ឬការបង្ករោគស្រួចស្រាវនៅឆ្អឹង(រលាកឆ្អឹង) ត្រូវឲ្យPenicillin ក្នុងកម្រិតខ្ពស់ ប៉ុន្តែ**ចំពោះ Streptomycin គឺមិនអាចឲ្យលើសពីកម្រិតខាងលើនេះទេ។**

**សម្រាប់ជំងឺមិនសូវធ្ងន់ធ្ងរ** ដែលតម្រូវឲ្យប្រើPenicillin ជាមួយStreptomycinនោះ អាចប្រើProcaine penicillin ជាមួយStreptomycin។ ចំពោះកម្រិតប្រើProcaine penicillin សូមមើលទំ.៣៥៣។ កម្រិតនៃStreptomycinគឺដូចគ្នានឹងកម្រិតខាងលើនេះ។

សូមអាន *គ្រោះថ្នាក់និងការប្រុងប្រយ័ត្ន* ចំពោះPenicillin និងStreptomycinនៅទំ.៣៥១ និង៣៦៣។

## Erythromycin :
## ប្រើជំនួសPenicillin

<u>Erythromycin</u>

ឈ្មោះ:________________________________

ច្រើនតែជា :

ថ្នាំគ្រាប់ ២៥០ម.ក្រ តម្លៃ___សម្រាប់___
ស៊ីរ៉ូ ១២៥ ឬ ២០០ម.ក្រ ក្នុង ៥ម.ល តម្លៃ___សម្រាប់___
ក្រមួនភ្នែក ពី០.៥% ទៅ ១% តម្លៃ___សម្រាប់___

Erythromycinមានប្រសិទ្ធិភាពចំពោះជំងឺទាំងឡាយណាដែលគេប្រើPenicillin និងTetracycline ប៉ុន្តែErythromycin ថ្លៃជាង។ នៅប្រទេសជាច្រើន សព្វថ្ងៃនេះErythromycinមានប្រសិទ្ធភាពជាងPenicillinក្នុងការព្យាបាលជំងឺរលាកសួត និងជំងឺសើស្បែកមួយចំនួនទៀត។

Erythromycinអាចត្រូវបានប្រើជំនួសPenicillin ប្រសិនបើអ្នកជំងឺមានទំនាស់នឹងPenicillin។ វាអាចប្រើចំពោះអ្នកដែលមានប្រតិកម្មនឹងTetracyclineផងដែរ ក៏ដូចជាស្ត្រីមានផ្ទៃពោះ និងកុមារដែលមិនគួរប្រើTetracycline។ ក្នុងករណីខ្លះ: Erythromycinមិនល្អសម្រាប់ប្រើជំនួសTetracyclineនោះទេ។ សូមមើលក្នុងសៀវភៅដែលនិយាយពីជំងឺនីមួយៗ។

Erythromycinមានសុវត្ថិភាពគួរសម ប៉ុន្តែត្រូវមានការប្រុងប្រយ័ត្នក្នុងការប្រើឲ្យត្រូវតាមកម្រិតថ្នាំដែលបានរៀបរាប់ខាងលើ។ មិនត្រូវប្រើErythromycinលើសពី២សប្តាហ៍ទេ ព្រោះអាចបណ្តាលឲ្យកើតលឿង ។

***កម្រិតប្រើ*** Erythromycin :

លេបអារីត្រូមីស៊ីននៅពេលបាយ ដើម្បីកុំឲ្យក្រពះធ្វើទុក្ខ។

ឲ្យ ៤ដងក្នុង ១ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ៥០០ម.ក្រ (២គ្រាប់ ឬ៤ស្លាបព្រាកាហ្វេ)
- កុមារអាយុ៨-១២ឆ្នាំ : ២៥០ម.ក្រ (១គ្រាប់ ឬ២ស្លាបព្រាកាហ្វេ)
- កុមារអាយុ៣-៧ឆ្នាំ : ១៥០ម.ក្រ (១/២គ្រាប់ ឬ១ ស្លាបព្រាកាហ្វេ)
- កុមារអាយុក្រោម៣ឆ្នាំ : ៧៥-១៥០ម.ក្រ (១/៤ ទៅ ១/២គ្រាប់ ឬ ១/២ ទៅ ១ស្លាបព្រាកាហ្វេ)

## Tetracycline :
## អង់ទីប៊ីយ៉ូទិកមានប្រសិទ្ធិភាពទូលំទូលាយ

Tetracycline ( tetracycline HCl, oxytetracycline ។ល។ )
( ម៉ាកដែលធ្លាប់ស្គាល់ ប៉ុន្តែថ្លៃ : *Terramycin* )

ឈ្មោះ:______________________________

ច្រើនជា :

| | | |
|---|---|---|
| ថ្នាំគ្រាប់ ២៥០ម.ក្រ | តម្លៃ______ | សម្រាប់_____ |
| ថ្នាំទឹក ១២៥ម.ក្រ ក្នុង៥ម.ល | តម្លៃ______ | សម្រាប់_____ |
| ក្រមួនភ្នែក ១% | តម្លៃ______ | សម្រាប់_____ |

Tetracyclineជាអង់ទីប៊ីយ៉ូទិកមានប្រសិទ្ធិភាពទូលំទូលាយ។ វាប្រឆាំងនឹងមេរោគច្រើនប្រភេទខុសៗគ្នា។

Tetracyclineគួរត្រូវបានប្រើជាថ្នាំលេប ព្រោះថាវាមានប្រសិទ្ធិភាព ហើយអាចមានបញ្ហាតិចជាងការចាក់។

Tetracyclineអាចត្រូវបានប្រើសម្រាប់ :

- ជំងឺរាក ឬរាកមួលបណ្តាលពីបាក់តេរី ឬអាមីប
- រលាកប្រហោងឆ្អឹងច្រមុះ
- ជំងឺផ្លូវដង្ហើម( រលាកទងសួត ។ល។ )
- ជំងឺរលាកផ្លូវនោម
- ទីហ្វូស
- ជំងឺប្រ៊ុយសេឡូសស
- ជំងឺអាសន្នរោគ
- ជំងឺត្រាកូម
- ជំងឺរលាកប្លោកនោម
- ជំងឺប្រមេះទឹកថ្លា
- ជំងឺប្រមេះទឹកបាយ
- ជំងឺរលាកអាងត្រគាក
- ជំងឺគ្រុនចាញ់( ស៊ាំនឹងថ្នាំChloroquine )

Tetracyclineមិនកបនឹងជំងឺផ្តាសាយទេ។ ចំពោះជំងឺធម្មតាភាគច្រើន TetracyclineមិនកបដូចជាPenicillinឬSulfaទេ។ វាថ្លៃជាង ហើយការប្រើប្រាស់មានកំណត់ទៀត។

### *គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :*

១. ស្ត្រីមានផ្ទៃពោះមិនគួរប្រើTetracyclineទេ ព្រោះវាអាចបំផ្លាញ ឬធ្វើឲ្យធ្មេញទារកមានពណ៌មិនល្អ។ ចំពោះមូលហេតុដដែលនេះ កុមារអាយុក្រោម៨ឆ្នាំគួរប្រើ Tetracyclineតែពេលចាំបាច់បំផុត ហើយប្រើតែមួយរយៈខ្លីប៉ុណ្ណោះ។ ប្រើErythromycinជំនួសវិញ។

២. Tetracyclineអាចបណ្តាលឲ្យរាក ឬធ្វើទុក្ខក្រពះ ជាពិសេសនៅពេលដែលប្រើក្នុងរយៈពេលយូរ។

៣. ជាការគ្រោះថ្នាក់ណាស់ដែលប្រើថ្នាំតែត្រាចាស់ ឬផុតកំណត់ការប្រើប្រាស់។

៤. ដើម្បីឲ្យថ្នាំមានប្រសិទ្ធភាព មិនគួរផឹកទឹកដោះគោ ឬថ្នាំអង់តាស៊ីត( ថ្នាំទប់ការបញ្ចេញជាតិអាស៊ីដក្នុងក្រពះ ) ១ម៉ោងមុន ឬ១ម៉ោងក្រោយពេលលេបថ្នាំទេ។

៥. មនុស្សមួយចំនួនអាចឡើងកន្ទួល ពេលស្ថិតនៅក្រោមកំដៅថ្ងៃ ក្រោយពេលប្រើTetracyclineហើយ។

***កម្រិតប្រើ*** Tetracycline ( ២០-៤០ម.ក្រ/គ.ក្រ/ថ្ងៃ ): គ្រាប់ ២៥០ម.ក្រ និងថ្នាំទឹក១២៥ម.ក្រ ក្នុង៥ម.ល

ឲ្យTetracyclineជាថ្នាំលេប ៤ដងក្នុង១ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ២៥០ម.ក្រ ( ១គ្រាប់ )
- កុមារអាយុ៨-១២ឆ្នាំ : ១២៥ម.ក្រ ( ១/២គ្រាប់ ឬ១ ស្លាបព្រាកាហ្វេ )
- កុមារអាយុក្រោម៨ឆ្នាំ : តាមក្បួនទូទៅ **មិនត្រូវប្រើ tetracyclineទេ** គឺប្រើ cotrimoxazole ឬ erythromycin។ បើគ្មានជម្រើសទេ សូមឲ្យ :
  - កុមារអាយុ៤-៧ឆ្នាំ : ៨០ម.ក្រ ( ១/៣គ្រាប់ ឬ ២/៣ ស្លាបព្រាកាហ្វេ )
  - កុមារអាយុ១-៣ឆ្នាំ : ៦០ម.ក្រ ( ១/៤គ្រាប់ ឬ ១/២ ស្លាបព្រាកាហ្វេ )
  - កុមារអាយុក្រោម១ឆ្នាំ : ២៥ម.ក្រ ( ១/១០គ្រាប់ ឬ ១/៥ ស្លាបព្រាកាហ្វេ )
  - ទារកទើបកើត( ករណីមិនអាចរកអង់ទីប៊ីយ៉ូទិកផ្សេងទៀតបាន ): ៨ម.ក្រ ( ១/៣០គ្រាប់ ឬ ៦ដំណក់ថ្នាំទឹក )

ក្នុងករណីធ្ងន់ធ្ងរ និងចំពោះជំងឺដូចជាជំងឺប្រមេះទឹកបាយ ប្រមេះទឹកថ្លា ជំងឺរលាកអាងត្រគាក ជំងឺអាសន្នរោគ ជំងឺទីហ្វូស និងប្រ៊ុយសេឡូស គួរឲ្យទ្វេរដងនៃកម្រិតខាងលើ ( លើកលែងតែចំពោះកុមារតូចៗ )។

ចំពោះជំងឺភាគច្រើន Tetracyclineគួរបានបន្តប្រើ១ឬ២ថ្ងៃទៀតបន្ទាប់ពីរោគសញ្ញាត្រូវបានបាត់( ជាធម្មតាសរុបគឺ៧ថ្ងៃ ) ។ ជំងឺមួយចំនួនត្រូវការការព្យាបាលយូរ : ទីហ្វូស ៦-១០ថ្ងៃ ប្រ៊ុយសេឡូស ២-៣សប្តាហ៍ ប្រមេះទឹកបាយ ប្រមេះទឹកថ្លា ៧-១០ថ្ងៃ ជំងឺរលាកអាងត្រគាក ១០-១៤ថ្ងៃ។ ជំងឺអាសន្នរោគជាធម្មតាត្រូវការការព្យាបាលខ្លីជាង : ៣-៥ថ្ងៃ។

Doxycyclin ( ម៉ាកដែលធ្លាប់ស្គាល់ : *Vibramycin* )

ឈ្មោះ:______________________________

ច្រើនជា :

| | | |
|---|---|---|
| ថ្នាំគ្រាប់ ១០០ម.ក្រ | តម្លៃ_____ | សម្រាប់____ |
| ជាអំពូល ១០០ម.ក្រ សម្រាប់ចាក់ | តម្លៃ_____ | សម្រាប់____ |

Doxycyclinជាទំរង់Tetracyclineមួយដែលថ្លៃ ដែលវាត្រូវប្រើ២ដងក្នុង១ថ្ងៃ ជាជាង៤ដងក្នុង១ថ្ងៃ។ ពេលដែលអាច វាអាចប្រើចំពោះជំងឺដូចគ្នានឹងTetracyclineដែរ។ Doxycyclin អាចលេបជាមួយអាហារ ឬទឹកដោះគោ។ **គ្រោះថ្នាក់និងការប្រុងប្រយ័ត្នរបស់វា ដូចគ្នានឹងTetracyclineដែរ (មើលទំ. ៣៥៦)។**

***កម្រិតប្រើ*** Doxycyclin : ថ្នាំគ្រាប់ ១០០ម.ក្រ

ឲ្យDoxycyclinជាថ្នាំលេប ២ដងក្នុង១ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ១០០ម.ក្រ (១គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ៥០ម.ក្រ (១/២គ្រាប់)
កុមារអាយុក្រោម៨ឆ្នាំ : **មិនត្រូវប្រើDoxycyclinទេ។**

## Chloramphenicol :
## អង់ទីប៊ីយ៉ូទិកសម្រាប់ជំងឺធ្ងន់ធ្ងរមួយចំនួន

Chloramphenicol *(Chloromycetin)*

ឈ្មោះ:________________________________

ច្រើនជា :

ថ្នាំគ្រាប់ ២៥០ម.ក្រ តម្លៃ______សម្រាប់___
ថ្នាំទឹក ១៥០ម.ក្រ ក្នុង៥ម.ល តម្លៃ______សម្រាប់___
ថ្នាំចាក់ ១.០០០ម.ក្រ ក្នុង១ដប តម្លៃ______សម្រាប់___

អង់ទីប៊ីយ៉ូទិកមានប្រសិទ្ធិភាពទូលំទូលាយនេះ កបនឹងមេរោគច្រើនប្រភេទណាស់។ វាថោក ប៉ុន្តែវាមានគ្រោះថ្នាក់ខ្លះដែរ។ ដោយហេតុនេះហើយ ការប្រើវា គួរតែមានកំណត់។

Chloramphenicolគួរប្រើសម្រាប់តែទីហ្វុស និងជំងឺធ្ងន់ដែលមិនអាចព្យាបាលដោយSulfa, penicillin, tetracycline ឬampicillin ប៉ុណ្ណោះ។ ចំពោះជំងឺដែលគំរាមកំហែងដល់ជីវិត ដូចជា រលាកស្រោមខួរ រលាកស្រោមពោះ របួសចាក់ដល់ពោះវៀន មេរោគក្នុងឈាម ឬគ្រុនក្តៅធ្ងន់ធ្ងរសម្រាប់ទារក Chloramphenicolអាចត្រូវបានប្រើ នៅពេលថ្នាំដែលមានគ្រោះថ្នាក់តិច (ដូចជា cephalosporins)មិនអាចរកបាន។

ជាធម្មតា Ampicillinមានប្រសិទ្ធភាពដូច ឬប្រសើរជាង Chloramphenicol ហើយមានសុវត្ថិភាពជាងទៀត។ តែគួរឲ្យស្តាយ Ampicillinមានតម្លៃថ្លៃ ដូច្នេះមានពេលខ្លះគេត្រូវតែប្រើ Chloramphenicolជំនួសតែម្តង។

***ប្រយ័ត្ន :*** Chloramphenicolធ្វើឲ្យអន្តរាយដល់ឈាមចំពោះមនុស្សមួយចំនួន។ វារឹតតែមានគ្រោះថ្នាក់ទៅទៀតចំពោះទារកទើបនឹងកើត ជាពិសេសទារកកើតមិនគ្រប់ខែ។ **ចំពោះទារកទើបកើត ដែលមានការបង្ករោគធ្ងន់ធ្ងរ ត្រូវប្រើ Ampicillin ជាជាងChloramphenicolបើអាចធ្វើទៅបាន។** ជាក្រិត្យក្រម **សូមកុំប្រើChloramphenicolចំពោះទារកអាយុតិចជាង១ខែ។**

ត្រូវប្រយ័ត្នកុំប្រើChloramphenicolលើសកម្រិតដែលបានណែនាំ។ **ចំពោះទារក កម្រិតនៃការប្រើថ្នាំ គឺតិចតួចប៉ុណ្ណោះ** (មើលខាងក្រោម)។

ចៀសវាងការប្រើថ្នាំនេះយូរអង្វែង ឬដដែលៗ។

ក្នុងការព្យាបាលជំងឺគ្រុនពោះវៀន ត្រូវប្តូរពី Chloramphenicol ទៅAmpicillinភ្លាម បន្ទាប់ពីជំងឺនេះធូរស្បើយហើយ។ (ក្នុងតំបន់ដែលគេដឹងថាជំងឺគ្រុនពោះវៀនបានស៊ាំនឹងChloramphenicolទៅហើយ នោះការព្យាបាលទាំងមូល គួរប្រើប្រើAmpicillin ឬ cotrimoxazole)។

Chloramphenicolប្រើជាថ្នាំលេប ល្អជាងការចាក់ ហើយក៏មានគ្រោះថ្នាក់តិចជាងផងដែរ។ **សូមកុំចាក់Chloramphenicol** លើកលែងតែករណីកម្រណាមួយ ដែលអ្នកជំងឺមិនអាចលេបថ្នាំបាន។

***កម្រិតប្រើ*** Chloramphenicol(៥០-១០០ម.ក្រ/គ.ក្រ/ថ្ងៃ) : ថ្នាំគ្រាប់ ២៥០ម.ក្រ ឬថ្នាំទឹក ១២៥ម.ក្រ ក្នុង៥ម.ល

ឲ្យជាថ្នាំលេប ៤ដងក្នុង១ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ៥០០-៧៥០ម.ក្រ (២-៣គ្រាប់) ចំពោះជំងឺគ្រុនពោះវៀន ជំងឺរលាកស្រោមពោះ និងជំងឺធ្ងន់ផ្សេងទៀត ត្រូវប្រើកម្រិតខ្ពស់ជាងនេះ (៣គ្រាប់ ៤ដង១ថ្ងៃ គឺ ១២គ្រាប់ក្នុង១ថ្ងៃ)

កុមារអាយុពី៨-១២ឆ្នាំ : ២៥០ម.ក្រ(១គ្រាប់ ឬ ២ស្លាបព្រាកាហ្វេថ្នាំទឹក)

កុមារអាយុពី៣-៧ឆ្នាំ : ១២៥ម.ក្រ(១/២គ្រាប់ ឬ ១ ស្លាបព្រាកាហ្វេ)

ទារកអាយុពី១ខែទៅ២ឆ្នាំ : ១២ម.ក្រ(១/២ម.លនៃថ្នាំទឹក ឬ ១/២០ថ្នាំគ្រាប់)សម្រាប់ ១គ.ក្រនៃទម្ងន់ខ្លួន។ (មានន័យថា ទារកទម្ងន់៥គ.ក្រ នឹងត្រូវប្រើ ៦០ម.ក្រ ដែលត្រូវនឹង ១/២ស្លាបព្រាកាហ្វេនៃថ្នាំទឹក ឬ ១/៤ នៃថ្នាំគ្រាប់ ក្នុងកម្រិតនីមួយៗ។ ក្នុង៤កម្រិត គឺមានន័យថាទារកទម្ងន់៥គ.ក ត្រូវទទួល១គ្រាប់ ឬ២ស្លាបព្រាកាហ្វេនៃថ្នាំទឹក ក្នុង១ថ្ងៃ)។

ទារកទើបកើត : *ជាក្រិតក្រម កុំប្រើChloramphenicol។* បើគ្មានជម្រើសទេ ប្រើ៥ម.ក្រ(១/៤ម.ល ឬ ៥ដំណក់ថ្នាំទឹក)សម្រាប់១គ.ក្រនៃទម្ងន់ទារក។ ចំពោះទារក ៣គ.ក្រ ត្រូវ ឲ្យ១៥ម.ក្រ(១៥តំណក់ថ្នាំទឹក) ៤ដង ក្នុង១ថ្ងៃ ឬប្រហែលនឹង១/៤គ្រាប់ ក្នុង១ថ្ងៃ។ កុំឲ្យលើសពីនេះ។

## Sulfa (Sulfonamide) :

## ថ្នាំមានតម្លៃថោក សម្រាប់ជំងឺធម្មតា

Sulfadiazine, sulfisoxazole, sulfadimidine ឬ 'triple sulfa'

ឈ្មោះ________________________________

ច្រើនជា :

ថ្នាំគ្រាប់ ៥០០ម.ក្រ តម្លៃ______សម្រាប់___
ទឹកខាប់ៗ ៥០០ម.ក្រ ក្នុង៥ម.ល តម្លៃ______សម្រាប់___

Sulfa ឬSulfonamide កំចាត់បាក់តេរីបានច្រើនយ៉ាង ប៉ុន្តែវាខ្សោយជាងអង់ទីប៊ីយ៉ូទិកច្រើនផ្សេងទៀត ហើយច្រើនបណ្តាលឲ្យមានប្រតិកម្មទំនាស់(រមាស់) និងបញ្ហាផ្សេងទៀត។ ប៉ុន្តែដោយសារតែវាថោក ហើយអាចប្រើជាថ្នាំលេបបាន វានៅតែមានប្រយោជន៍។

សារប្រយោជន៍សំខាន់ជាងគេនៃការប្រើSulfa គឺសម្រាប់ជំងឺរលាកផ្លូវនោម។ វាក៏អាចត្រូវបានប្រើសម្រាប់ការបង្ករោគក្នុងត្រចៀក ពងបែក និងការបង្ករោគលើស្បែកដែលមានខ្ទុះ។

មិនមែនSulfaទាំងអស់សុទ្ធតែប្រើក្នុងរបៀប ឬកម្រិតតែមួយនោះទេ។ ប្រសិនបើអ្នកមានតែSulfonamide ត្រូវប្រាកដថាប្រើវាឲ្យត្រូវ ហើយតាមកម្រិតរបស់វា។ Sulfathiazoleមានលក្ខណៈប្រហាក់ប្រហែលនឹងSulfaរៀបរាប់ខាងលើ ហើយថោកជាងច្រើន ប៉ុន្តែមិនត្រូវបានណែនាំឲ្យប្រើទេ ព្រោះវាងាយមានផលរំខានណាស់។

Sulfaមិនកបនឹងជំងឺរាកដូចកាលពីមុនទេ ពីព្រោះមេរោគជាច្រើនដែលបណ្តាលឲ្យរាកបានស៊ាំនឹងវាទៅហើយ។ ម្យ៉ាងវិញទៀត ការឲ្យSulfaទៅអ្នកដែលខ្សោះជាតិទឹកបណ្តាលពីរាកអាចធ្វើខូចតម្រងនោម។

***ប្រយ័ត្ន :*** ជាការសំខាន់ណាស់ដែលត្រូវ**ផឹកទឹកឲ្យបានច្រើន** យ៉ាងហោចណាស់ ៨កែវក្នុង១ថ្ងៃ នៅពេលលេបSulfa ដើម្បីបង្ការការខូចតម្រងនោម។

បើប្រើSulfaធ្វើឲ្យឡើងកន្ទួល ក្រហម រមាស់ ឈឺសន្លាក់ គ្រុនក្តៅ ឈឺផ្នែកខាងក្រោមចង្កេះ ឬនោមឈាម ត្រូវ**បញ្ឈប់ថ្នាំនេះ ហើយត្រូវផឹកទឹកឲ្យច្រើន។**

**សូមកុំឲ្យSulfaទៅអ្នកជំងឺដែលខ្សោះទឹកក្នុងខ្លួន ឬទារកអាយុក្រោម១ឆ្នាំឲ្យសោះ។**

**ចំណាំ :** ដើម្បីឲ្យមានប្រសិទ្ធិភាព Sulfaទាំងនេះត្រូវប្រើក្នុងកម្រិតត្រឹមត្រូវ ដែលមានកម្រិតច្រើន។ ឲ្យថ្នាំឲ្យល្មម តែកុំឲ្យច្រើនហួស។

***កម្រិតប្រើ*** Sulfadiazine, sulfisoxazole, sulfadimidine ឬ triple sulfa(២០០ម.ក្រ/គ.ក្រ/ថ្ងៃ): ថ្នាំគ្រាប់៥០០ម.ក្រ ឬ ថ្នាំទឹក ៥០០ម.ក្រក្នុង៥ម.ល

ឲ្យ ៤កម្រិត ក្នុង១ថ្ងៃ **ហើយផឹកទឹកឲ្យបានច្រើន**

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំនិងកុមារអាយុលើស១០ឆ្នាំ : ៣-៤ក្រ. (៦-៨ គ្រាប់)សម្រាប់កម្រិតទី១ បន្ទាប់មក១ក្រ.(២គ្រាប់) សម្រាប់កម្រិតក្រោយៗទៅទៀត។
កុមារអាយុ៦-១០ឆ្នាំ : ៧៥០ម.ក្រ (១ ១/២ គ្រាប់ ឬ១ស្លាបព្រាកាហ្វេ)ចំពោះកម្រិតនីមួយៗ។
ទារកអាយុក្រោម១ឆ្នាំ : **កុំឲ្យSulfa។**

ប្រសិនបើអ្នកគ្មានថ្នាំផ្សេងសម្រាប់ប្រើទេ សូមមើលទំព័របន្ទាប់អំពីកម្រិតថ្នាំសម្រាប់ទារកអាយុក្រោម១ឆ្នាំ។

Cotrimoxazole(Sulfamethoxazole ជាមួយ trimethoprim)
(ម៉ាកដែលធ្លាប់ស្គាល់ : *Bactrim, Septra*)

ឈ្មោះ________________________________

ច្រើនជា :

ថ្នាំគ្រាប់Sulfamethoxazole ១០០ម.ក្រ ជាមួយនឹង trimethoprim២០ម.ក្រ តម្លៃ______សម្រាប់__

ថ្នាំគ្រាប់Sulfamethoxazole ៤០០ម.ក្រ ជាមួយនឹង trimethoprim៨០ម.ក្រ តម្លៃ______សម្រាប់__

ថ្នាំទឹកSulfamethoxazole ២០០ម.ក្រ ជាមួយ trimethoprim៤០ម.ក្រ ក្នុង៥ម.ល តម្លៃ______សម្រាប់___

**ចំណាំ :** ថ្នាំនេះជួនកាលអាចមានជាថ្នាំគ្រាប់ដែលមានកំលាំងទ្វេរដង(*Bactrim DS និងSeptra DS*) ដែលមាន Sulfamethoxazole៨០០ម.ក្រ ជាមួយtrimethoprim ១៦០ ម.ក្រ។ ប្រើតែពាក់កណ្តាលកម្រិតដែលឲ្យខាងក្រោម ប្រសិនបើថ្នាំដែលអ្នកមាន ជាថ្នាំដែលមានកំលាំងទ្វេរដង។

ថ្នាំផ្សំបញ្ចូលគ្នានេះ ប្រឆាំងនឹងបាក់តេរីជាច្រើន ហើយមានតម្លៃថោកជាងAmpicillin។

**ប្រយ័ត្ន : ស្ត្រីដែលមានផ្ទៃពោះខ្លះតែ៣ខែ និងទារកដែលមានអាយុតិចជាង៨សប្តាហ៍ មិនគួរប្រើcotrimoxazoleទេ។ មិនត្រូវឲ្យcotrimoxazoleទៅនរណាម្នាក់ដែលមានប្រតិកម្មនឹងថ្នាំក្នុងស្រឡាយSulfaឲ្យសោះ។**

Cotrimoxazoleអាចត្រូវបានប្រើដើម្បីព្យាបាល :

ជំងឺប្រ៊ុយសេឡូស
ការបង្ករោគក្នុងត្រចៀក
ជំងឺរាកលាយឈាម និងគ្រុនក្តៅ (ស៊ីហ្សេលឡា)
ពងបែក
ជំងឺផ្លូវដង្ហើម(រលាកសួត)

***កម្រិតប្រើ*** cotrimoxazole :

**សំខាន់ :** ឲ្យ២កម្រិតក្នុង១ថ្ងៃ រយៈពេល៥-៧ថ្ងៃ ហើយផឹកទឹកឲ្យច្រើន។ ចំពោះជំងឺគ្រុនពោះវៀន ត្រូវប្រើ១៤ថ្ងៃ។

មនុស្សធំនិងកុមារអាយុលើស១២ឆ្នាំ :
ថ្នាំគ្រាប់Sulfamethoxazole៨០០ម.ក្រ
ជាមួយtrimethoprim១៦០ម.ក្រ
ចំនួន២ដងក្នុង១ថ្ងៃ។

កុមារអាយុ៨សប្តាហ៍-១២ឆ្នាំ ប្រើថ្នាំទឹកខាប់ៗ
(ជាមីលីម៉ែត្រ ចូរអានទំ.៦១ សម្រាប់រង្វាស់របស់វា):
១/២ម.ល/ក.គ្រ ២ដងក្នុង១ថ្ងៃ។

ការប្រើថ្នាំគ្រាប់Sulfamethoxazole៤០០ម.ក្រ ជាមួយ trimethoprim៨០ម.ក្រ :

កុមារអាយុ៩-១២ឆ្នាំ : ២គ្រាប់ ២ដងក្នុង១ថ្ងៃ។
កុមារអាយុ៤-៨ឆ្នាំ : ១គ្រាប់ ២ដងក្នុង១ថ្ងៃ។
កុមារអាយុ៩ខែ-៣ឆ្នាំ : ១/២គ្រាប់ ២ដងក្នុង១ថ្ងៃ។
ទារកអាយុ២-៨ខែ : ១/៤គ្រាប់ ២ដងក្នុង១ថ្ងៃ។

## Gentamicin

Gentamicinជាថ្នាំអង់ទីប៊ីយ៉ូទិកចាក់ ដែលប្រើសម្រាប់ជំងឺស្រួចស្រាល់។ Gentamicinគួរប្រើដោយបុគ្គលិកសុខាភិបាលជំនាញ និងពេលដែលថ្នាំមានសុវត្ថិភាពផ្សេងទៀតមិនអាចរកបានតែប៉ុណ្ណោះ។ ការប្រើថ្នាំនេះខុស អាចធ្វើឲ្យថ្លង់ និងខូចតម្រងនោមយ៉ាងធ្ងន់ធ្ងរ។ យើងមិនបានបញ្ចូលព័ត៌មាននៃកម្រិតប្រើនៅទីនេះទេ ព្រោះថ្នាំនេះមានគ្រោះថ្នាក់បំផុត។ សម្រាប់សុវត្ថិភាពរបស់អ្នក យើងសូមណែនាំឲ្យប្រើថ្នាំណាមួយដែលបានរៀបរាប់ពីទំ.៣៥១ ទៅ៣៦០វិញ។

## Cephalosporin

នេះគឺជាអង់ទីប៊ីយ៉ូទិកដ៏ខ្លាំងថ្មីមួយ ដែលប្រឆាំងនឹងបាក់តេរីជាច្រើនប្រភេទ។ ជាទូទៅវាមានតម្លៃថ្លៃ ហើយពិបាករកផងដែរ។ ដោយហេតុនេះហើយ យើងមិនបានណែនាំឲ្យប្រើថ្នាំនេះជាជម្រើសទីមួយទេ។ ទោះជាយ៉ាងនេះក៏ដោយ ថ្នាំទាំងនេះមានគ្រោះថ្នាក់និងផលរំខានតិចជាងអង់ទីប៊ីយ៉ូទិកផ្សេងៗទៀត ហើយនៅពេលដែលរកវាបាន វាអាចមានប្រយោជន៍ក្នុងការព្យាបាលជំងឺធ្ងន់ធ្ងរមួយចំនួន។

Cephalosporinមានច្រើនប្រភេទ ដូចជា cefazolin ***(Ancef)***, cephalexin ***(Keflex)***, cephradine ***(Velosef)***, cefurazine ***(Ceftin)***, cefoxitin ***(Mefoxin)***, ceftriaxone ***(Rocephin)***, cefotaxime ***(Claforan)***, និង ceftazidime ***(Fortaz, Taxidime, Tazicef)***។ Cephalosporinច្រើនប្រភេទ អាចប្រើជាមួយជំងឺរលាកសួត ការបង្ករោគផ្លូវទឹកនោម គ្រុនពោះវៀន រលាកអាងត្រគាកឬពោះវៀន ការបង្ករោគនៅឆ្អឹង និងរលាកស្រោមខួរ។ ថ្នាំខ្លះទៀតដូចជា ceftriaxone អាចប្រើសម្រាប់ព្យាបាលជំងឺកាមរោគ ដូចជា ទាមទ្បា ជំងឺភ្នែកសម្រាប់ទារក ឬជំងឺប្រមេះទឹកបាយ ដែលវាស៊ាំនឹងPenicillin។

សូមរកការណែនាំអំពីកម្រិតប្រើ និងផលរំខាននានា មុនពេលប្រើថ្នាំទាំងនេះ។ ជាមួយគ្នានេះដែរ សូមកុំប្រើថ្នាំនេះចំពោះជំងឺស្រាល ឬក៏ជំងឺដែលអាចព្យាបាលបានដូចគ្នាដោយអង់ទីប៊ីយ៉ូទិកដែលមានតម្លៃថោកជាង។

# ថ្នាំសម្រាប់ជំងឺប្រមេះទឹកបាយ និងប្រមេះទឹកថ្លា

ជំងឺទាំងនេះមានរោគសញ្ញាដំបូងដូចគ្នា ហើយជាញឹកញាប់វាកើតឡើងជាមួយគ្នា(មើលទំ.២៣៦)។ ដោយសារតែអាចមានការពិបាក ឬមានការចំណាយច្រើនក្នុងការធ្វើតេស្តរកមើលជំងឺប្រមេះទឹកថ្លា ជាការល្អ គួរព្យាបាលជំងឺទាំងពីរនេះក្នុងពេលដំណាលគ្នាតែម្តង។

*ចំពោះជំងឺប្រមេះទឹកបាយ សូមប្រើមួយក្នុងចំណោមថ្នាំទាំងនេះ*

ceftriaxone ថ្នាំចាក់១២៥ម.ក្រ តែមួយដងប៉ុណ្ណោះ

**ឬ**

cefixime ៤០០ម.ក្រជាថ្នាំលេប តែមួយដងប៉ុណ្ណោះ

**ឬ**

spectinomycin ថ្នាំចាក់២ក្រ. តែមួយដងប៉ុណ្ណោះ

**ស្ត្រីមានផ្ទៃពោះ កុមារ និងមនុស្សជំទង់ មិនគួរប្រើថ្នាំ ciprofloxacinទេ។**

**ស្ត្រីមានផ្ទៃពោះ ឬម្តាយកំពុងបំបៅដោះកូន មិនគួរប្រើថ្នាំ spectinomycinទេ។**

*ចំពោះជំងឺប្រមេះទឹកថ្លា សូមប្រើមួយក្នុងចំណោមថ្នាំទាំងនេះ*

Doxycyclin(ទំ.៣៥៦): ១០០ម.ក្រ ជាថ្នាំលេប ២ដងក្នុង១ថ្ងៃ រយៈពេល ៧ថ្ងៃ

**ឬ**

azithromycin ១ក្រ.ជាថ្នាំលេប ១ដងប៉ុណ្ណោះ

**ឬ**

Amoxicillin ៥០០ម.ក្រជាថ្នាំលេប ៣ដងក្នុងមួយថ្ងៃ រយៈពេល៧ថ្ងៃ

**ឬ**

Erythromycin(ទំ.៣៥៥): ៥០០ម.ក្រ ជាថ្នាំលេប ៤ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ។ លេបជាមួយអាហារ។

**ឬ**

Ofloxacin ៤០០ម.ក្រ ជាថ្នាំលេប ២ដងក្នុង១ថ្ងៃ រយៈពេល ៧ថ្ងៃ។

**ឬ**

Tetracycline(ទំ.៣៥៦) : ៥០០ម.ក្រ ជាថ្នាំលេប ៤ដងក្នុង១ថ្ងៃ រយៈពេល ៧ថ្ងៃ។

**សូមកុំលេប Doxycyclin, Tetracycline ឬ Ofloxacin បើអ្នកមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន។** ស្ត្រីមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន អាចប្រើ azithromycin, erythromycin ឬ amoxicillin។

# ថ្នាំសម្រាប់ជំងឺរបេង

ដើម្បីព្យាបាលជំងឺរបេង ជាការសំខាន់ត្រូវ**ប្រើថ្នាំប្រឆាំងជំងឺរបេង ៤ឬ៥មុខក្នុងពេលតែមួយ។** ប្រសិនបើព្យាបាលដោយប្រើថ្នាំតែមួយមុខ មេរោគរបេងនឹងស៊ាំនឹងថ្នាំនេះ ហើយនាំឲ្យជំងឺនេះកាន់តែពិបាកព្យាបាល។

ជំងឺរបេងត្រូវការការព្យាបាលរយៈពេលយូរ ជាធម្មតាពី៦ទៅ៩ខែ ឬយូរជាងនេះ។ រយៈពេលព្យាបាលអាស្រ័យទៅលើការផ្សំនៃថ្នាំដែលបានប្រើ។ ដើម្បីការពារកុំឲ្យជំងឺរបេងលាប់ឡើងវិញ **ការព្យាបាលរយៈពេលយូរពេញលេញ ជាការសំខាន់បំផុត។**

ថ្នាំមួយចំនួនសម្រាប់ព្យាបាលជំងឺរបេង មានតម្លៃថ្លៃ (Rifampicin, Pyrazinamide, Ethambutol) ប្រសិនបើអ្នកទិញនៅតាមឱសថស្ថាន។ ប៉ុន្តែរដ្ឋាភិបាលជាច្រើនមានកម្មវិធីផ្តល់ការធ្វើតេស្តរកជំងឺរបេងនិងផ្តល់ថ្នាំព្យាបាលដោយមិនគិតថ្លៃ ឬក្នុងតម្លៃទាបមួយ។

សូមទាក់ទងមជ្ឈមណ្ឌលជាតិកម្ចាត់រោគរបេង និងហង់សិន តាមរយៈអាសយដ្ឋានលេខ ១ ផ្លូវ២៧៨កែង៩៥ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន ភ្នំពេញ។ ទូរស័ព្ទ : ០២៣ ២១៩ ២៧៤, ០២៣ ២១៩ ២៧៥។

ដំបូន្មានពីអ្នកមានបទពិសោធន៍គឺជាការសំខាន់ ពីព្រោះការព្យាបាលអាចផ្លាស់ប្តូរ មេរោគអាចស៊ាំនឹងថ្នាំ ហើយថ្នាំថ្មីៗអាចនឹងរកបាន។ ដូចគ្នាដែរ មានកម្មវិធីមួយចំនួនឲ្យថ្នាំតែ២ដងក្នុង១សប្តាហ៍ ក្នុងកម្រិតខ្ពស់មួយ។

**Isoniazid (INH)** គួរត្រូវបានប្រើក្នុងការព្យាបាលជំងឺរបេងជានិច្ច។ Rifampicinជាថ្នាំមានប្រសិទ្ធិភាពមួយដែលគួរប្រើនៅពេលដែលមាន ជាពិសេសគួរប្រើរហូតទាល់តែតេស្តកំហាក បង្ហាញលទ្ធផលអវិជ្ជមាន។ **Ethambutol** និង **Streptomycin** ក៏ត្រូវបានប្រើពេលខ្លះដែរ។ ការប្រើ **Pyrazinamide** ជាមួយINH និងRifampicin អាចកាត់បន្ថយពេលវេលាក្នុងការព្យាបាល។ **Thiacetazone** ជាថ្នាំព្យាបាលជំងឺរបេងដែលមានតម្លៃថោក ប៉ុន្តែវាមានផលរំខានញឹកញាប់ដែលមនុស្សជាច្រើនមិនអាចប្រើវាបាន។

ប្រសិនបើថ្នាំធ្វើឲ្យរមាស់ ភ្នែកនិងស្បែកឡើងលឿង (ជំងឺលឿង) ឬឈឺចាប់ក្នុងក្រពះ សូមទៅជួបបុគ្គលិកសុខាភិបាល សួរអំពីការផ្លាស់ប្តូរកម្រិតប្រើថ្នាំ ឬប្តូរថ្នាំប្រើ។ ប្រសិនមានពងបែក ឈប់ប្រើថ្នាំសិន រហូតទាល់អ្នកបានជួបបុគ្គលិកសុខាភិបាល។ ចៀសវាងការផឹកស្រានៅពេលអ្នកប្រើថ្នាំរបេង ជាពិសេស INH។

## វិធីព្យាបាលដែលត្រូវបានណែនាំ

ប្រើថ្នាំផ្សំបញ្ចូលគ្នាណាមួយក្នុងចំណោមថ្នាំខាងក្រោម អាស្រ័យលើចំនួនដែលអាចរកបាន ដែលទិញប្រើបាន និងដែលបានណែនាំឲ្យប្រើក្នុងតំបន់របស់អ្នក :

១. ឲ្យIsoniazid, Rifampicin, Ethambutol និង Pyrazinamide សម្រាប់រយៈពេល២ខែ។ បន្ទាប់មកត្រូវឈប់ប្រើPyrazinamide ប៉ុន្តែត្រូវបន្តប្រើ Rifampicin Isoniazid និងEthambutol រយៈពេល ៤ខែទៀត។

២. ឲ្យIsoniazid, Rifampicin, Ethambutol និង Pyrazinamide សម្រាប់រយៈពេល៩ខែ។

៣. ផ្សំIsoniazid, Rifampicin, Streptomycin និង Pyrazinamide សម្រាប់រយៈពេល២ខែ។ បន្ទាប់មកឲ្យ Isoniazid ជាមួយEthambutol, Streptomycin ឬក៏អាចប្រើThiacetazoneសម្រាប់រយៈពេល៦ខែទៅមុខទៀត។ ការព្យាបាលរបៀបនេះ នឹងបន្ថយការចំណាយព្រោះត្រូវការប្រើRifampicinតិច។

៤. ប្រសិនបើRifampicinមិនអាចរកបាន ឬថ្លៃពេក សូមប្រើIsoniazid, Ethambutol និងStreptomycin សម្រាប់រយៈពេល២ខែ ឬរហូតការធ្វើតេស្តបង្ហាញថាកំហាកអវិជ្ជមាន។ បន្ទាប់មកបន្តប្រើStreptomycin រយៈពេល២ខែទៅមុខទៀត និងឲ្យINH និង Ethambutol រយៈពេល១ឆ្នាំ។

៥. សម្រាប់ស្ត្រីមានផ្ទៃពោះដែលមានជំងឺរបេង គួរស្វែងរកដំបូន្មានពីគ្រូពេទ្យ។ បើមិនអាចទេ សូមប្រើIsoniazid ជាមួយនឹងEthambutol, Rifampicin ឬ Thiacetazoneសម្រាប់រយៈពេល១៨ខែ។ ជាមួយគ្នាដែរ ឲ្យវីតាមីនបេ៦ (Pyridoxine) ៥០ម.ក្រ/ថ្ងៃ។ កុំប្រើPyrazinamide ឬStreptomycin ក្នុងពេលមានផ្ទៃពោះ។

<u>Isoniazid (INH)</u>

ឈ្មោះ________________តម្លៃ_________សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ១០០ម.ក្រ ឬ ៣០០ម.ក្រ

នេះជាថ្នាំប្រឆាំងជំងឺរបេងដ៏សាមញ្ញបំផុត។ ដើម្បីព្យាបាលជំងឺរបេង វាតែងតែត្រូវបានឲ្យជាមួយថ្នាំផ្សេងទៀតយ៉ាងហោច ១មុខ។ សម្រាប់ការបង្ការ វាអាចត្រូវបានផ្តល់តែមួយមុខបាន។

***គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :***

ក្នុងករណីកម្រខ្លះ Isoniazidធ្វើឲ្យមានភាពស្លេកស្លាំង ឈឺសរសៃនៅដៃនិងជើង រមួលសាច់ដុំ ឬថែមទាំងប្រកាច់ទៀតផង ជាពិសេសចំពោះមនុស្សដែលខ្វះអាហារូបត្ថម្ភ។ ផលរំខានទាំងនេះ ជាធម្មតាអាចព្យាបាលបានដោយប្រើPyridoxine (វីតាមីនបេ៦) រៀងរាល់ថ្ងៃចំនួន៥០ម.ក្រជាថ្នាំលេប (ទំ.៣៩៤)។

ជួនកាលIsoniazidអាចបំផ្លាញថ្លើម។ អ្នកដែលចេញរោគសញ្ញារលាកថ្លើម (ភ្នែកនិងស្បែកឡើងលឿង រមាស់ មិនឃ្លាន ឈឺក្នុងពោះ មើលទំ.១៧២) នៅពេលលេបIsoniazid គួរឈប់លេបថ្នាំនេះ។

***កម្រិតប្រើ*** Isoniazid (៥-១០ម.ក្រ/គ.ក្រ/ថ្ងៃ) : ប្រើថ្នាំ១០០ម.ក្រ

ឲ្យIsoniazid១ដងក្នុង១ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :
មនុស្សធំ : ៣០០ម.ក្រ (៣គ្រាប់)
កុមារ : ៥០ម.ក្រ (១/២គ្រាប់) សម្រាប់ទម្ងន់១៥ គ.ក្រ

ចំពោះកុមារដែលមានជំងឺរបេងធ្ងន់ធ្ងរ ឬអ្នកដែលមានរបេងស្ងួត សូមឲ្យទ្វេរដងនៃកម្រិតខាងលើ រហូតមានការធូរស្រាល។

ចំពោះការបង្ការការឆ្លងរោគរបេងទៅសមាជិកគ្រួសារ ជាទូទៅគេប្រើINHក្នុងកម្រិតខាងលើ រយៈពេល៦-៩ខែ។

Rifampicin

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ១៥០ ឬ ៣០០ម.ក្រ

អង់ទីប៊ីយ៉ូទិកមួយនេះមានតម្លៃថ្លៃ ប៉ុន្តែមានប្រសិទ្ធិភាពក្នុងការកម្ចាត់ជំងឺរបេង។ មិនត្រូវប្រើថ្នាំនេះតែឯងទេ បើមិនដូច្នេះទេ ជំងឺរបេងនឹង*ស៊ាំនឹង*ថ្នាំនេះ។ នៅពេលដែលផ្សំជាមួយ Isoniazid និងយ៉ាងហោចថ្នាំ១មុខផ្សេងទៀត វាអាចកាត់បន្ថយពេលវេលាព្យាបាលបានច្រើនខែ។ (Rifampicinក៏ត្រូវបានប្រើសម្រាប់ព្យាបាលជំងឺឃ្លង់ដែរ មើលទំ.៣៦៤)។

ជាការសំខាន់គឺត្រូវលេបRifampicinឲ្យទៀងទាត់ ដោយគ្មានការអាក់ខាន។ សូមចាំថា ត្រូវរកថ្នាំបន្ថែមទៀត មុនពេលដែលថ្នាំរបស់អ្នកអស់។

***គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :***

Rifampicinអាចធ្វើឲ្យខូចថ្លើមយ៉ាងធ្ងន់ធ្ងរ។ អ្នកដែលមានជំងឺថ្លើម ឬអ្នកដែលមានផ្ទៃពោះ គួរប្រើថ្នាំនេះដោយមានការពិភាក្សាជាមួយបុគ្គលិកសុខាភិបាលជំនាញ។

***ផលរំខាន :*** ទឹកនោម ទឹកភ្នែក លាមក ទឹកមាត់ សំបោរស្លេស និងញើស គឺមានពណ៌ទឹកក្រូចក្រហមដោយសារឥទ្ធិពលរបស់ Rifampicin។ ក្នុងករណីតិចតួច Rifampicin អាចធ្វើឲ្យមានគ្រុនក្តៅ បាត់បង់ឬកើនចំណង់អាហារ ក្អួត ចង្អោរ វង្វេង កន្ទួលលើស្បែក និងបញ្ហារដូវ។

Rifampicinកាត់បន្ថយប្រសិទ្ធភាពរបស់ថ្នាំគ្រាប់ពន្យារកំណើត ដូច្នេះស្ត្រីដែលប្រើថ្នាំពន្យារកំណើត គួររកជំបូន្មានពីគ្រូពេទ្យសម្រាប់ការបង្កើនកម្រិតប្រើ។ ឬក៏ប្រើមធ្យោបាយពន្យារកំណើតផ្សេងទៀតដូចជា ស្រោមអនាម័យ កងដាក់ក្នុងស្បូន ឬ ដ្យ៉ាហ្វ្រាម នៅពេលប្រើRifampicin។

***កម្រិតប្រើ*** Rifampicinក្នុងការព្យាបាលរបេង(១០ម.ក្រ/គ.ក្រ/ថ្ងៃ): ថ្នាំគ្រាប់ ១៥០ម.ក្រ ឬ៣០០ម.ក្រ

ឲ្យRifampicin១ដងក្នុង១ថ្ងៃ អាច១ម៉ោងមុន ឬ២ម៉ោងក្រោយបរិភោគអាហារ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ៦០០ម.ក្រ (ថ្នាំ៣០០ម.ក្រ ២គ្រាប់ ឬថ្នាំ ១៥០ម.ក្រ ៤គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ៤៥០ម.ក្រ
កុមារអាយុ៣-៧ឆ្នាំ : ៣០០ម.ក្រ
កុមារក្រោម៣ឆ្នាំ : ១៥០ម.ក្រ

Pyrazinamide

ឈ្មោះ_______________តម្លៃ________សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ៥០០ម.ក្រ។

***គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :***

ស្ត្រីមានផ្ទៃពោះមិនគួរប្រើPyrazinamideទេ។

***ផលរំខាន :*** អាចធ្វើឲ្យហើមឬឈឺសន្លាក់ លែងឃ្លានអាហារ ចង្អោរ និងក្អួត នោមមានការឈឺចាប់ ល្ហិតល្ហៃ និងគ្រុន។

***កម្រិតប្រើ*** Pyrazinamide(២០-៣០ម.ក្រ/គ.ក្រ/ថ្ងៃ): ប្រើថ្នាំគ្រាប់ ៥០០ម.ក្រ

ឲ្យ ១ថ្ងៃ១ដង រយៈពេល២ខែ ដោយឲ្យជាមួយនូវថ្នាំរបេងផ្សេងៗទៀត។ ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ១៥០០-២០០០ម.ក្រ (៣ឬ៤គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ១០០០ម.ក្រ (២គ្រាប់)
កុមារអាយុ៣-៧ឆ្នាំ : ៥០០ម.ក្រ (១គ្រាប់)
កុមារក្រោម៣ឆ្នាំ : ២៥០ម.ក្រ (១/២គ្រាប់)

Ethambutol(ម៉ាកដែលធ្លាប់ស្គាល់ : *Myambutol*)

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ១០០ម.ក្រ ឬ ៤០០ម.ក្រ។

***គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :***

Ethambutolអាចធ្វើឲ្យឈឺ ឬប៉ះពាល់ភ្នែក ប្រសិនបើប្រើច្រើន ហើយយូរ។ គួរបញ្ឈប់ការប្រើថ្នាំនេះ នៅពេលដែលមានបញ្ហាជាមួយភ្នែក ឬការសំឡឹងមើលមានការប្រែប្រួល។ ការប៉ះពាល់ភ្នែកបណ្តាលមកពីEthambutol ជាធម្មតាមានការប្រសើរឡើងវិញក្រោយពេលឈប់ប្រើថ្នាំនេះ។

***កម្រិតប្រើ*** Ethambutol(២៥ម.ក្រ/គ.ក្រ/ថ្ងៃ សម្រាប់២ខដំបូង បន្ទាប់មក ១៥ម.ក្រ/គ.ក្រ/ថ្ងៃ): ថ្នាំគ្រាប់ ១០០ម.ក្រ ឬ ៤០០ម.ក្រ

ឲ្យ ១ថ្ងៃ១ដង។

ក្នុងរយៈពេល២ខែដំបូង ក្នុងកម្រិតនីមួយៗ ឲ្យ :
មនុស្សធំ : ១២០០ម.ក្រ (ថ្នាំ៤០០ម.ក្រ ៣គ្រាប់ ឬថ្នាំ ១០០ម.ក្រ ១២គ្រាប់)
កុមារ : ឲ្យ ១៥ម.ក្រសម្រាប់ទម្ងន់កុមារ១គ.ក្រ។ ប៉ុន្តែ ចំពោះជំងឺរបេងស្ងួត ឲ្យ២៥ម.ក្រសម្រាប់ទម្ងន់កុមារ ១គ.ក្រ។

បន្ទាប់ពី២ខែ ឲ្យ :
មនុស្សធំ : ៨០០ម.ក្រ (ថ្នាំ៤០០ម.ក្រ ២គ្រាប់ ឬថ្នាំ១០០ ម.ក្រ ៨គ្រាប់)
កុមារ: ឲ្យ ១៥ម.ក្រសម្រាប់ទម្ងន់កុមារ១គ.ក្រ។

Streptomycin

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជាដបសម្រាប់ចាក់ ៥០០ម.ក្រ ក្នុង១ម.ល។

Streptomycinនៅតែជាថ្នាំមានប្រយោជន៍សម្រាប់ព្យាបាល ជំងឺរបេង។ វាមានប្រសិទ្ធភាពតិចជាងRifampicinបន្តិច ប៉ុន្តែថោកជាងច្រើន។

***គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :***

ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ដោយមិនឲ្យថ្នាំលើសកម្រិតត្រឹមត្រូវ។ ការប្រើថ្នាំនេះច្រើន ហើយក្នុងរយៈពេលយូរ អាចធ្វើឲ្យថ្លង់។ បើមានការហ៊ឹងត្រចៀក ឬថ្លង់ សូមឈប់លេបថ្នាំ ហើយត្រូវពិគ្រោះនឹងគ្រូពេទ្យ។

ស្ត្រីមានផ្ទៃពោះ ឬអ្នកដែលមានជំងឺតម្រងនោម មិនគួរប្រើថ្នាំនេះទេ។

***កម្រិតប្រើ*** Streptomycin(១៥ម.ក្រ/គ.ក្រ/ថ្ងៃ) : ដប ឬម្សៅសម្រាប់លាយទឹក ១ក្រ.នៃStreptomycin ក្នុង២ម.ល

*សម្រាប់ការព្យាបាលជំងឺរបេង*

**ករណីធ្ងន់ធ្ងរខ្លាំង :** ចាក់១ថ្ងៃ១ម្ជុល រយៈពេល៣-៨ សប្តាហ៍

**ករណីស្រាល :** ចាក់២ឬ៣ម្ជុលក្នុង១សប្តាហ៍ រយៈពេល ២ខែ

ក្នុងការចាក់ម្តងៗ ឲ្យ :
មនុស្សធំ : ១ក្រ. (ឬ២ម.ល)
មនុស្សចាស់អាយុលើស៥០ឆ្នាំ : ៥០០ម.ក្រ(១ម.ល)
កុមារអាយុ៨-១២ឆ្នាំ : ៧៥០ម.ក្រ(១ ១/២ម.ល)
កុមារអាយុ៣-៧ឆ្នាំ : ៥០០ម.ក្រ(១ម.ល)
កុមារអាយុក្រោម៣ឆ្នាំ : ២៥០ម.ក្រ (១/២ម.ល)
ទារកទើបកើត : ឲ្យ២០ម.ក្រសម្រាប់ទម្ងន់១គ.ក្រ ដូច្នេះទារកទម្ងន់៣គ.ក្រ ត្រូវទទួល៦០ម.ក្រ(១/៨ម.ល)

*ការប្រើStreptomycinសម្រាប់ព្យាបាលជំងឺផ្សេងក្រៅពីរបេង*

ក្នុងករណីបន្ទាន់ StreptomycinជាមួយនិងPenicillinអាចប្រើសម្រាប់ព្យាបាលជំងឺធ្ងន់ធ្ងរមួយចំនួនបាន(មើលPenicillin និងstreptomycin ទំ.៣៥៤)។ ទោះជាយ៉ាងនេះក្តី ការប្រើ Streptomycinសម្រាប់ព្យាបាលជំងឺផ្សេងក្រៅពីរបេង គួរមានកំណត់ ព្រោះការប្រើរបៀបនេះយូរៗទៅនឹងធ្វើឲ្យរោគរបេងស៊ាំនឹងថ្នាំនេះ ហើយជាលទ្ធផលគឺពិបាកព្យាបាល។

Thiacetazone

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ៥០ម.ក្រ (ថ្នាំនេះច្រើនតែផ្សំជាមួយនិង Isoniazid ១០០ ឬ១៣៣ម.ក្រ)

***ផលវិបាក :*** អាចធ្វើឲ្យឡើងកន្ទួលនៅលើស្បែក ក្អួតចង្អោរ វិលមុខ ឬមិនឃ្លានបាយ។ **អ្នកដែលមានមេរោគអេដស៍/ ជំងឺអេដស៍ ជាច់ខាតកុំប្រើថ្នាំនេះ។ វាអាចធ្វើឲ្យមានប្រតិកម្មទំនាស់យ៉ាងខ្លាំងរហូតដល់ស្លាប់បាន ហើយអាចធ្វើរបកស្បែក។**

***កម្រិតប្រើ*** Thiacetazone (២,៥ម.ក្រ/គ.ក្រ/ថ្ងៃ) : ថ្នាំគ្រាប់៥០ម.ក្រ លាយ ឬមិនលាយជាមួយIsoniazid

ឲ្យ១ថ្ងៃ១ដង។

ក្នុងកម្រិតនីមួយៗ ឲ្យ :
មនុស្សធំ : ៣គ្រាប់(១៥០ម.ក្រ)
កុមារអាយុ៨-១២ឆ្នាំ : ២គ្រាប់(១០០ម.ក្រ)
កុមារអាយុ៣-៧ឆ្នាំ : ១គ្រាប់(៥០ម.ក្រ)
កុមារអាយុក្រោម៣ឆ្នាំ : ១/២គ្រាប់(២៥ម.ក្រ)

## ថ្នាំសម្រាប់ជំងឺឃ្លង់

នៅពេលព្យាបាលជំងឺឃ្លង់ ចាំបាច់ត្រូវដឹងថាជំងឺឃ្លង់ប្រភេទណាមួយដែលអ្នកជំងឺមាន។ ប្រសិនបើមានសន្លាកពណ៌ស្រាលៗ ដោយមានការបាត់បង់ញាណដឹងដឹង ប៉ុន្តែមិនមានដុំពក ឬស្បែកក្រាស់ទេ នោះវាអាចជាជំងឺឃ្លង់ tuberculoid ហើយវាត្រូវការការព្យាបាលដោយថ្នាំតែ២មុខប៉ុណ្ណោះ។ ប្រសិនបើមានដុំពក នោះវា អាចជាជំងឺឃ្លង់ lepromatous ហើយប្រសើរបំផុតត្រូវប្រើថ្នាំ៣មុខ។ **ប្រសិនបើអាច ថ្នាំព្យាបាលជំងឺឃ្លង់គួរត្រូវបានប្រើដោយមានការណែនាំពីបុគ្គលិកសុខាភិបាល ឬវេជ្ជបណ្ឌិតដែលមានបទពិសោធន៍ ដោយផ្អែកលើផែនការជាតិ។**

សូមទាក់ទងមជ្ឈមណ្ឌលជាតិកម្ចាត់រោគរបេង និងហង់សិន តាមរយៈអាសយដ្ឋានលេខ ១ ផ្លូវ២៧៨កែង៩៥ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន ភ្នំពេញ។ ទូរស័ព្ទ : ០២៣ ២១៩ ២៧៤, ០២៣ ២១៩ ២៧៥។

ជាធម្មតាការព្យាបាលជំងឺឃ្លង់ត្រូវតែបន្តរហូតយ៉ាងតិច៦ខែ ឬពេលខ្លះអាចបន្តអស់មួយជីវិត។ ដើម្បីកុំឲ្យបាក់តេរី(បាក់ស៊ីលី) ដែលបណ្តាលឲ្យមានជំងឺឃ្លង់ ស៊ាំនឹងថ្នាំ ជាការសំខាន់ត្រូវលេបថ្នាំឲ្យទៀងទាត់ ដោយមិនអាក់ខាន។ ត្រូវប្រាកដថាអ្នកបានរកថ្នាំបន្ថែម មុនពេលអស់ថ្នាំ។

**ការព្យាបាលដែលត្រូវបានណែនាំ :**

ចំពោះ ជំងឺឃ្លង់ tuberculoid ចូរប្រើថ្នាំទាំងពីរនេះ យ៉ាងហោចណាស់ ៦ខែ :

Dapsone : រៀងរាល់ថ្ងៃ
Rifampicin : រៀងរាល់ខែ

ចំពោះ ជំងឺឃ្លង់ lepromatous ប្រើថ្នាំទាំងបីមុខនេះ រយៈពេល២ទៅ៥ឆ្នាំ :

Dapsone : រៀងរាល់ថ្ងៃ
Clofazimine : រាល់ថ្ងៃ ហើយបង្កើនកម្រិតប្រើរៀងរាល់ខែ
Rifampicin : រៀងរាល់ខែ

**ចំណាំ :** ទោះបីជាការព្យាបាលជំងឺឃ្លង់ដោយប្រើDapsone ជាមួយនឹងថ្នាំផ្សេងទៀត ធ្វើឲ្យចំណេញពេលព្យាបាលក៏ដោយ ជួនកាលមានតែDapsoneមួយមុខប៉ុណ្ណោះដែលអាចរកបាន។ ជាញឹកញាប់ នៅពេលប្រើវាតែមួយមុខ វាមានលទ្ធផលល្អដែរ ប៉ុន្តែវាប្រើពេលយូរ ហេតុនេះហើយការព្យាបាលអាចប្រើពេលយ៉ាងតិច២ឆ្នាំ ឬអស់មួយជីវិតចំពោះ ជំងឺឃ្លង់ lepromatous។

ក្នុងករណីកម្រ អ្នកជំងឺអាចមានបញ្ហាធ្ងន់ធ្ងរមួយហៅថា "ប្រតិកម្មជំងឺឃ្លង់" នៅពេលដែលគេប្រើថ្នាំព្យាបាលជំងឺឃ្លង់នេះ។ វាអាចមានជាដុំពកៗ និងស្នាមរលាក គ្រុនក្តៅ និងហើមឡើងសរសៃ។ វាក៏អាចធ្វើឲ្យឈឺសន្លាក់ ហើមកូនកណ្តុរ និងពងស្វាស ហើមដៃនិងជើង ឬភ្នែកឈឺនិងក្រហម ដែលអាចបណ្តាលឲ្យងងឹតភ្នែក។

ក្នុងករណីមាន "ប្រតិកម្មជំងឺឃ្លង់" ធ្ងន់ធ្ងរ( ឈឺតាមសរសៃស្ពឹក ឬខ្សោយ ឈឺភ្នែក ឬពងស្វាស ) ជាធម្មតាគឺត្រូវបន្តការព្យាបាលជំងឺឃ្លង់ដដែល ប៉ុន្តែត្រូវបន្ថែមថ្នាំប្រឆាំងរលាក ( cortico-steroid )។ ស្វែងរកដំបូន្មានពីគ្រូពេទ្យជំនាញ អំពីបញ្ហានេះ ព្រោះcortico-steroid ក៏អាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរដែរ។

Dapsone ( diaminodiphenylsulfone, DDS )

ឈ្មោះ:_______________ តម្លៃ_________ សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ៥០ម.ក្រ ឬ១០០ម.ក្រ ។

ជួនកាលDapsoneបណ្តាលឲ្យមានស្លេកស្លាំង ឬកន្ទួលលើស្បែក ដែលអាចនឹងធ្ងន់ធ្ងរទៀតផង។ ប្រសិនបើរបកស្បែកខ្លាំង ត្រូវឈប់លេបថ្នាំ។

***ប្រយ័ត្ន :*** DDS គឺជាថ្នាំដែលមានគ្រោះថ្នាក់។ចូរទុកវាឲ្យឆ្ងាយកុំឲ្យកុមារយកបាន។

***កម្រិតប្រើ*** DDS ( ២ម.ក្រ/គ.ក្រ/ថ្ងៃ ): ថ្នាំគ្រាប់១០០ម.ក្រ លេបមួយថ្ងៃម្តង

មនុស្សធំ : ១០០ម.ក្រ ( ថ្នាំ១០០ម.ក្រ ១គ្រាប់ )
កុមារអាយុ១៣-១៨ឆ្នាំ : ៥០ម.ក្រ( ថ្នាំ១០០ម.ក្រ ១/២គ្រាប់ )
កុមារអាយុ៦-១២ឆ្នាំ : ២៥ម.ក្រ( ថ្នាំ១០០ម.ក្រ ១/៤គ្រាប់ )
កុមារអាយុ២-៥ឆ្នាំ : ២៥ម.ក្រ( ថ្នាំ១០០ម.ក្រ ១/៤គ្រាប់ ) **តែ៣ដងក្នុង១សប្តាហ៍ប៉ុណ្ណោះ។**

Rifampicin

ឈ្មោះ:_______________ តម្លៃ_________ សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ១៥០ម.ក្រ និង៣០០ម.ក្រ ។

Rifampicinជាថ្នាំថ្លៃមួយ ប៉ុន្តែគេត្រូវការវាតែបន្តិចប៉ុណ្ណោះក្នុងការព្យាបាលជំងឺឃ្លង់ ដូច្នេះតម្លៃសរុបនឹងមិនសូវជាអស់ច្រើនទេ។ សូមមើលទំ.៣៦២ និយាយពីផលរំខាន និងគ្រោះថ្នាក់។ ត្រូវសុំដំបូន្មានពីបុគ្គលិកសុខាភិបាល ឬវេជ្ជបណ្ឌិតជំនាញ នៅពេលប្រើRifampicin :

***កម្រិតប្រើ*** Rifampicinសម្រាប់ជំងឺឃ្លង់ ( ១០-២០ម.ក្រ/គ.ក្រ/ថ្ងៃ ): ប្រើថ្នាំគ្រាប់៣០០ម.ក្រ ។

សម្រាប់ជំងឺឃ្លង់ ចូរប្រើRifampicinម្តងក្នុង១ខែ។ គួរលេបវា១ម៉ោងមុន ឬ២ម៉ោងក្រោយពេលទទួលទានអាហារ។

ក្នុងកម្រិតប្រចាំខែនីមួយៗ ឲ្យ :
មនុស្សធំ : ៦០០ម.ក្រ ( ថ្នាំ៣០០ម.ក្រ ២គ្រាប់ )
កុមារអាយុ៨-១២ឆ្នាំ : ៤៥០ម.ក្រ( ថ្នាំ៣០០ម.ក្រ ១ ១/២គ្រាប់ )
កុមារអាយុ៣-៧ឆ្នាំ : ៣០០ម.ក្រ( ថ្នាំ៣០០ម.ក្រ ១គ្រាប់ )
កុមារអាយុក្រោម៣ឆ្នាំ : ១៥០ម.ក្រ( ថ្នាំ៣០០ម.ក្រ ១/២គ្រាប់ )

Clofazimine *( Lamprene )*

ឈ្មោះ:_______________ តម្លៃ_________ សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ៥០ម.ក្រ និង១០០ម.ក្រ

Clofazimineក៏ជាថ្នាំដែលមានថ្លៃដែរ។ ទោះបីជាវាមានប្រសិទ្ធិភាពតិចជាងRifampicin ក្នុងការកម្ចាត់មេរោគឃ្លង់ក៏ដោយ វាមានគុណសម្បត្តិត្រង់ថាវាជួយក្នុងបញ្ឈប់ ប្រតិកម្មជំងឺឃ្លង់ ក្នុងកម្រិតមួយ ជាពិសេសចំពោះ ជំងឺឃ្លង់ lepromatous ។

***ផលវិបាក :*** ធ្វើឲ្យស្បែកប្រែពណ៌ជាក្រហមស្វាយ។ វាគ្រាន់តែជាករណីបណ្តោះអាសន្នទេ ហើយនឹងបាត់ទៅវិញក្នុង១ឬ២ឆ្នាំក្រោយពេលឈប់ប្រើថ្នាំនេះ។ អាចបណ្តាលឲ្យមានបញ្ហាក្រពះ ឬការរំលាយអាហារ។ មិនត្រូវបានណែនាំឲ្យប្រើចំពោះស្ត្រីមានផ្ទៃពោះទេ។

***កម្រិតប្រើ*** Clofazimine (១ម.ក្រ/គ.ក្រ/ថ្ងៃ): ប្រើថ្នាំគ្រាប់ ៥០ម.ក្រ

ឲ្យClofazimine១កម្រិតរាល់ថ្ងៃ ហើយ១ខែម្តងឲ្យថ្នាំក្នុងកម្រិតច្រើនជាងនេះ។

ក្នុងកម្រិតប្រចាំថ្ងៃនីមួយៗ ឲ្យ :
- មនុស្សធំ : ៥០ម.ក្រ (ថ្នាំ៥០ម.ក្រ ១គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ៣៧ម.ក្រ(ថ្នាំ៥០ម.ក្រ ៣/៤គ្រាប់)
- កុមារអាយុ៣-៧ឆ្នាំ : ២៥ម.ក្រ(ថ្នាំ៥០ម.ក្រ ១/២គ្រាប់)
- កុមារអាយុក្រោម៣ឆ្នាំ : ១២ម.ក្រ(ថ្នាំ៥០ម.ក្រ ១/៤គ្រាប់)

ក្នុងកម្រិតប្រចាំខែនីមួយៗ ឲ្យ :
- មនុស្សធំ : ៣០០ម.ក្រ (ថ្នាំ៥០ម.ក្រ ៦គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ២២៥ម.ក្រ(ថ្នាំ៥០ម.ក្រ ៤ ១/២គ្រាប់)
- កុមារអាយុ៣-៧ឆ្នាំ : ១៥០ម.ក្រ(ថ្នាំ៥០ម.ក្រ ៣គ្រាប់)
- កុមារអាយុក្រោម៣ឆ្នាំ : ៧៥ម.ក្រ(ថ្នាំ៥០ម.ក្រ ១ ១/២ គ្រាប់)

**ចំណាំ :** កម្រិតធំនៃClofazimine ដែលអាចត្រូវបានប្រើរាល់ថ្ងៃដើម្បីបញ្ឈប់ ប្រតិកម្មជំងឺឃ្លង់ គឺប្រសើរបំផុតត្រូវប្រើដោយមានការណែនាំពីបុគ្គលិកសុខាភិបាលជំនាញ ឬវេជ្ជបណ្ឌិត។

## ថ្នាំសម្រាប់ជំងឺគ្រុនចាញ់

មានថ្នាំជាច្រើនដែលប្រឆាំងនឹងជំងឺគ្រុនចាញ់។ ជាអកុសល នៅតំបន់ជាច្រើនក្នុងពិភពលោក មេរោគគ្រុនចាញ់បានស៊ាំនឹងថ្នាំគ្រុនចាញ់ដែលខ្លាំងជាងគេទៅហើយ។ ជាពិសេសគឺប្រភេទជំងឺគ្រុនចាញ់ដែលធ្ងន់ធ្ងរជាងគេ(ជំងឺគ្រុនចាញ់ដែលបង្កដោយហ្វាល់ស៊ីប៉ារូម)។ **ជាការសំខាន់គឺត្រូវរៀនពីបុគ្គលិកសុខាភិបាល មណ្ឌលសុខភាពក្នុងស្រុក ឬនាយកដ្ឋានសុខភាព ថាតើថ្នាំគ្រុនចាញ់មួយណាដែលមានប្រសិទ្ធភាពក្នុងតំបន់របស់អ្នក។**

***សំខាន់ :*** ជំងឺគ្រុនចាញ់អាចសម្លាប់មនុស្សបានយ៉ាងឆាប់រហ័ស ប្រសិនបើមិនទាន់ភាពប្រព័ន្ធការពាររាងកាយ។ កុមារ និងអ្នកដែលបានទៅកាន់តំបន់ដែលមានជំងឺគ្រុនចាញ់ ត្រូវទទួលការព្យាបាលភ្លាមៗ។

ថ្នាំសម្រាប់គ្រុនចាញ់អាចត្រូវបានប្រើក្នុងវិធី២យ៉ាង :

១. សម្រាប់ព្យាបាលអ្នកដែលមានជំងឺគ្រុនចាញ់។ ថ្នាំត្រូវបានផ្តល់រៀងរាល់ថ្ងៃ រយៈពេលតែ២ឬ៣ថ្ងៃទេ។

២. សម្រាប់ការបង្ការ : ដើម្បីទប់ស្កាត់មេរោគគ្រុនចាញ់ដែលអាចមាននៅក្នុងឈាម មិនឲ្យបង្កគ្រោះថ្នាក់។ ការបង្ការត្រូវបានធ្វើឡើងក្នុងតំបន់ដែលមានជំងឺគ្រុនចាញ់ញឹកញាប់ ជាពិសេសដើម្បីការពារកុមារដែលខ្សោយ ឬឈឺដោយមូលហេតុផ្សេងៗ។ វាក៏ត្រូវបានប្រើផងដែរសម្រាប់អ្នកដែលទៅកាន់តំបន់ដែលមានជំងឺគ្រុនចាញ់ហើយគាត់គ្មានប្រព័ន្ធការពារខ្លួន។ ជាធម្មតាថ្នាំត្រូវបានផ្តល់មួយសប្តាហ៍ម្តង។ ដើម្បីបង្ការគ្រុនចាញ់ សូមមើលផងដែរនូវវិធីចៀសវាងមូសខាំ នៅទំ.១៩៧។

ថ្នាំគ្រុនចាញ់មួយចំនួន ប្រើសម្រាប់តែព្យាបាលជំងឺគ្រុនចាញ់ប៉ុណ្ណោះ ហើយមួយចំនួនទៀតប្រើសម្រាប់តែបង្ការ។ ថ្នាំផ្សេងទៀត អាចប្រើបានសម្រាប់ទាំងពីរតួនាទី។

ថ្នាំដែលប្រើសម្រាប់ព្យាបាលប្រភេទជំងឺគ្រុនចាញ់ស្រួចស្រាល់ គួរត្រូវបានប្រើផ្សំនឹងថ្នាំផ្សេងទៀត ព្រោះមេរោគបានស៊ាំនឹងថ្នាំជាច្រើនដែលប្រើញឹកញាប់។ ដោយហេតុតែការស៊ាំនឹង**ថ្នាំChloroquine**បានរាយសាយទៅតំបន់ជាច្រើន ដូច្នេះជំងឺគ្រុនចាញ់ស្រួចស្រាល់ គួរព្យាបាលដោយ **Quinine**(ទំ.៣៦៦) ជាមួយ**Fansidar**(ទំ.៣៦៨) ឬ Quinine ជាមួយ **Doxycyclin**(ទំ.៣៥៦)។

**Mefloquine** និង**Proguanil** ជាថ្នាំ២ផ្សេងទៀតដែលប្រើសម្រាប់ព្យាបាលនិងបង្ការជំងឺគ្រុនចាញ់ដែលស៊ាំនឹង Chloroquine។ ជួនកាលក្រោយពីព្យាបាល គេប្រើ **Primaquine** ជាមួយថ្នាំគ្រុនចាញ់ផ្សេងទៀត ដើម្បីការពារមិនឲ្យគ្រុនចាញ់កើតឡើងវិញទៀត។

**Doxycyclin**ត្រូវបានប្រើម្តងម្កាលក្នុងការព្យាបាលនិងបង្ការជំងឺគ្រុនចាញ់(មើលទំ.៣៦៨)។ មានថ្នាំក្រោយមកទៀតឈ្មោះថា **Artemisinin** ដែលចម្រាញ់ពីរុក្ខជាតិដែលមានច្រើននៅអាស៊ី។ វាត្រូវបានប្រើជាមួយថ្នាំគ្រុនចាញ់ផ្សេងទៀត ដើម្បីព្យាបាលគ្រុនចាញ់ដែលស៊ាំនឹងថ្នាំច្រើនមុខ។ ប៉ុន្តែថ្នាំនេះនៅមានតម្លៃថ្លៃ ហើយមិនអាចរកបានទេនៅតំបន់ជាច្រើន។

### Artemisinin *(Artesunate, Artemether, Artemotil)*

ជាធម្មតាថ្នាំស្រឡាយArtemisininត្រូវបានប្រើជាមួយថ្នាំដទៃទៀតក្នុងការព្យាបាលជំងឺគ្រុនចាញ់ដែលបង្កដោយហ្វាល់ស៊ីប៉ារូមនៅតំបន់ដែលគេដឹងថាមេរោគស៊ាំនឹងថ្នាំគ្រុនចាញ់។

***កម្រិតប្រើ***

ឲ្យArtesunate ៣០០ម.ក្រ ជាថ្នាំលេប ១ថ្ងៃម្តង រយៈពេល៧ថ្ងៃ

***និង***

ឲ្យClindamycin ៦០០ម.ក្រ ជាថ្នាំលេប ២ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ

នៅកន្លែងខ្លះ: កម្រិតប្រើនៃArtemisinin និងArtesunate ត្រូវបានបន្ថែមដោយMefloquine ១កម្រិតប្រើ (១៥ម.ក្រ/គ.ក្រ)។

ស្ត្រីមានផ្ទៃពោះក្រោម៣ខែ **មិន**គួរប្រើថ្នាំនេះទេ។ បន្ទាប់ពី៣ខែទៅ ទើបមានសុវត្ថិភាព។

<u>Chloroquine</u>

Chloroquineមាន២ទំរង់ គឺ Chloroquine phosphate និងChloroquine sulfate។ កម្រិតប្រើរបស់វាខុសគ្នា ដូច្នេះ អ្នកត្រូវដឹងថាChloroquineប្រភេទណាដែលអ្នកមាន ហើយ បរិមាណថ្នាំ( ជាតិChloroquine )មានប៉ុន្មាននៅក្នុងថ្នាំ។

ស្ទើរតែគ្រប់កន្លែងក្នុងពិភពលោក គ្រុនចាញ់បានស៊ាំនឹង Chloroquineដែលប្រើតែឯងទៅហើយ។ Chloroquineគួរបាន ប្រើជាមួយថ្នាំផ្សេងទៀត។ ចូរពិភាក្សាជាមួយបុគ្គលិកសុខាភិ បាលអំពីថ្នាំណាដែលមានប្រសិទ្ធភាពបំផុតក្នុងតំបន់របស់អ្នក។

Chloroquineមានសុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះ ឬកំពុង បំបៅដោះកូន ក្នុងការព្យាបាល និងបង្ការជំងឺគ្រុនចាញ់។

Chloroquine phosphate ( ម៉ាកដែលធ្លាប់ស្គាល់ : *Aralen, Resochin, Avlochlor* )

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ២៥០ម.ក្រ( ដែលមានជាតិChloroquine ១៥០ម.ក្រក្នុងនោះ ) ឬ ៥០០ម.ក្រ(មានជាតិ Chloroquine៣០០ម.ក្រក្នុងនោះ )

កម្រិតប្រើ Chloroquine phosphateជាថ្នាំលេប : ប្រើថ្នាំគ្រាប់ ២៥០ម.ក្រ ។

***សម្រាប់ការព្យាបាលជំងឺគ្រុនចាញ់ស្រួចស្រាល់ :***

សម្រាប់កម្រិតប្រើលើកទី១ ឲ្យ :
- មនុស្សធំ : ៤គ្រាប់ ( ១០០០ម.ក្រ )
- កុមារអាយុ១០-១៥ឆ្នាំ : ៣គ្រាប់ ( ៧៥០ម.ក្រ )
- កុមារអាយុ៦-៩ឆ្នាំ : ២គ្រាប់ ( ៥០០ម.ក្រ )
- កុមារអាយុ៣-៥ឆ្នាំ : ១គ្រាប់ ( ២៥០ម.ក្រ )
- កុមារអាយុ១-២ឆ្នាំ : ១/២គ្រាប់ ( ១២៥ម.ក្រ )
- ទារកអាយុក្រោម១ឆ្នាំ : ១/៤គ្រាប់ ( ៦៣ម.ក្រ )

បន្ទាប់មកទៀតឲ្យថ្នាំតាមកម្រិតប្រើដូចខាងក្រោម នៅ៦ ម៉ោងបន្ទាប់ពីកម្រិតប្រើលើកទី១ ១ថ្ងៃបន្ទាប់ពីកម្រិតប្រើលើក ទី១ និង ២ថ្ងៃបន្ទាប់ពីកម្រិតប្រើលើកទី១:

- មនុស្សធំ : ២គ្រាប់ ( ៥០០ម.ក្រ )
- កុមារអាយុ១០-១៥ឆ្នាំ : ១ ១/២គ្រាប់ ( ៣៧៥ម.ក្រ )
- កុមារអាយុ៦-៩ឆ្នាំ : ១គ្រាប់ ( ២៥០ម.ក្រ )
- កុមារអាយុ៣-៥ឆ្នាំ : ១/២គ្រាប់ ( ១២៥ម.ក្រ )
- កុមារអាយុ១-២ឆ្នាំ : ១/៤គ្រាប់ ( ៦៣ម.ក្រ )
- ទារកអាយុក្រោម១ឆ្នាំ : ១/៨គ្រាប់ ( ៣២ម.ក្រ )

*សម្រាប់ការបង្ការជំងឺគ្រុនចាញ់ ( នៅកន្លែងដែលវាមិនស៊ាំនឹង Chloroquine ) :*

១សប្តាហ៍មុនពេលចូលទៅកន្លែងមានជំងឺគ្រុនចាញ់ ឲ្យថ្នាំ ១ដង និងបន្តឲ្យថ្នាំក្នុង១សប្តាហ៍ម្តង រហូតទាល់តែចាកចេញពី តំបន់ដែលមានជំងឺគ្រុនចាញ់បាន៤សប្តាហ៍។

- មនុស្សធំ : ២គ្រាប់ ( ៥០០ម.ក្រ )
- កុមារអាយុ១០-១៥ឆ្នាំ : ១ ១/២គ្រាប់ ( ៣៧៥ម.ក្រ )
- កុមារអាយុ៦-៩ឆ្នាំ : ១គ្រាប់ ( ២៥០ម.ក្រ )
- កុមារអាយុ៣-៥ឆ្នាំ : ១/២គ្រាប់ ( ១២៥ម.ក្រ )
- កុមារអាយុ១-២ឆ្នាំ : ១/៤គ្រាប់ ( ៦៣ម.ក្រ )
- ទារកអាយុក្រោម១ឆ្នាំ : ១/៨គ្រាប់ ( ៣២ម.ក្រ )

Chloroquine sulfate ( ម៉ាកដែលធ្លាប់ស្គាល់ : *Nivaquine* )

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ២០០ម.ក្រ( មានជាតិChloroquine១៥០ ម.ក្រក្នុងនោះ )

***កម្រិតប្រើ*** Chloroquine sulfateជាថ្នាំលេប : ប្រើថ្នាំគ្រាប់ ២០០ម.ក្រ

***សម្រាប់ការព្យាបាលជំងឺគ្រុនចាញ់ស្រួចស្រាល់ :***

សម្រាប់កម្រិតប្រើលើកទី១ ឲ្យ :
- មនុស្សធំ : ៤គ្រាប់ ( ៨០០ម.ក្រ )
- កុមារអាយុ១០-១៥ឆ្នាំ : ៣គ្រាប់ ( ៦០០ម.ក្រ )
- កុមារអាយុ៦-៩ឆ្នាំ : ២គ្រាប់ ( ៤០០ម.ក្រ )
- កុមារអាយុ៣-៥ឆ្នាំ : ១គ្រាប់ ( ២០០ម.ក្រ )
- កុមារអាយុ១-២ឆ្នាំ : ១/២គ្រាប់ ( ១០០ម.ក្រ )
- ទារកអាយុក្រោម១ឆ្នាំ : ១/៤គ្រាប់ ( ៥០ម.ក្រ )

បន្ទាប់មកទៀតឲ្យតាមកម្រិតប្រើដូចខាងក្រោម នៅ៦ម៉ោង បន្ទាប់ពីកម្រិតប្រើលើកទី១ ១ថ្ងៃបន្ទាប់ពីម្រិតប្រើលើកទី១ និង ២ថ្ងៃបន្ទាប់ពីកម្រិតប្រើលើកទី១ :

- មនុស្សធំ : ២គ្រាប់ ( ៤០០ម.ក្រ )
- កុមារអាយុ១០-១៥ឆ្នាំ : ១ ១/២គ្រាប់ ( ៣០០ម.ក្រ )
- កុមារអាយុ៦-៩ឆ្នាំ : ១គ្រាប់ ( ២០០ម.ក្រ )
- កុមារអាយុ៣-៥ឆ្នាំ : ១/២គ្រាប់ ( ១០០ម.ក្រ )
- កុមារអាយុ១-២ឆ្នាំ : ១/៤គ្រាប់ ( ៥០ម.ក្រ )
- ទារកអាយុក្រោម១ឆ្នាំ : ១/៨គ្រាប់ ( ២៥ម.ក្រ )

***សម្រាប់ការបង្ការជំងឺគ្រុនចាញ់ :***

១សប្តាហ៍មុនពេលចូលទៅកន្លែងមានជំងឺគ្រុនចាញ់ ឲ្យថ្នាំ ១ដង និងបន្តឲ្យថ្នាំក្នុង១សប្តាហ៍ម្តង រហូតទាល់តែចាកចេញពី តំបន់ដែលមានជំងឺគ្រុនចាញ់បាន៤សប្តាហ៍។

- មនុស្សធំ : ២គ្រាប់ ( ៤០០ម.ក្រ )
- កុមារអាយុ១០-១៥ឆ្នាំ : ១ ១/២គ្រាប់ ( ៣០០ម.ក្រ )
- កុមារអាយុ៦-៩ឆ្នាំ : ១គ្រាប់ ( ២០០ម.ក្រ )
- កុមារអាយុ៣-៥ឆ្នាំ : ១/២គ្រាប់ ( ១០០ម.ក្រ )
- កុមារអាយុ១-២ឆ្នាំ : ១/៤គ្រាប់ ( ៥០ម.ក្រ )
- ទារកអាយុក្រោម១ឆ្នាំ : ១/៨គ្រាប់ ( ២៥ម.ក្រ )

<u>Quinine ( Quinine sulfate ឬQuinine bisulfate )</u>

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនជាថ្នាំគ្រាប់ ៣០០ម.ក្រ ឬ ៦៥០ម.ក្រ

Quinineត្រូវបានប្រើសម្រាប់ព្យាបាលគ្រុនចាញ់ដែលស៊ាំ នឹងថ្នាំ( គ្រុនចាញ់ដែលមិនព្រមចាញ់ថ្នាំដទៃទៀត ) និងគ្រុន ចាញ់ធ្ងន់ធ្ងរ រួមទាំងគ្រុនចាញ់ដែលប៉ះពាល់ដល់ខួរក្បាល។ ប្រសើរបំផុតគឺត្រូវឲ្យជាថ្នាំលេប។ ប្រសិនបើលេបQuinine ធ្វើ ឲ្យក្អួតចង្អោរ ថ្នាំផ្សេងទៀតដូចជាPromethazineអាចជួយ បាន។

***ផលរំខាន*** : ជួនកាលQuinineធ្វើឲ្យស្បែកហូរញើស ហ៊ឹងត្រចៀក ឬស្តាប់មិនសូវឮ ស្រវាំងភ្នែក វិលមុខ ចង្អោរ និងរាក។

***កម្រិតប្រើ*** Quinineសម្រាប់ព្យាបាលជំងឺគ្រុនចាញ់ស្រួចស្រាល់ : ប្រើថ្នាំគ្រាប់ ៣០០ម.ក្រ។

ឲ្យ៣ដងក្នុង១ថ្ងៃ រយៈពេល៣ថ្ងៃ :

មនុស្សធំ : ២គ្រាប់ (៦០០ម.ក្រ)
កុមារអាយុ១០-១៥ឆ្នាំ : ១ ១/២គ្រាប់ (៤៥០ម.ក្រ)
កុមារអាយុ៦-៩ឆ្នាំ : ១គ្រាប់ (៣០០ម.ក្រ)
កុមារអាយុ៣-៥ឆ្នាំ : ១/២គ្រាប់ (១៥០ម.ក្រ)
កុមារអាយុ១-២ឆ្នាំ : ១/៤គ្រាប់ (៧៥ម.ក្រ)
ទារកអាយុក្រោម១ឆ្នាំ : ១/៨គ្រាប់ (៣៨ម.ក្រ)

**ចំណាំ :** នៅតំបន់ខ្លះក្នុងពិភពលោក ដូចជាអាស៊ីអាគ្នេយ៍ជាដើម ជាការចាំបាច់គឺត្រូវប្រើQuinineរយៈពេល ៧ថ្ងៃ។

**ការចាក់ថ្នាំQuinine ឬChloroquine :**
**ពេលណាដែលត្រូវចាក់ :**

ការចាក់ថ្នាំQuinine ឬChloroquineគួរតែប្រើតិចតួចបំផុតក្នុងករណីបន្ទាន់ខ្លាំង។ ប្រសិនអ្នកណាមានរោគសញ្ញាគ្រុនចាញ់ ឬរស់នៅក្នុងតំបន់ដែលសំបូរជំងឺគ្រុនចាញ់ មានក្អួតប្រកាច់ ឬសញ្ញាផ្សេងទៀតនៃជំងឺរលាកស្រោមខួរ(មើលទំ. ១៨៥) នោះគាត់អាចមានមេរោគគ្រុនចាញ់ក្នុងខួរក្បាល។ **ត្រូវចាក់ថ្នាំQuinineជាបន្ទាន់** (ឬបើអ្នកគ្មានថ្នាំផ្សេងទៀតទេ សូមសាកល្បងចាក់Chloroquine)។ ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការប្រើ**កម្រិតថ្នាំឲ្យត្រឹមត្រូវ។ ត្រូវរកជំនួយពីគ្រូពេទ្យ។**

ការចាក់Quinine Dihydrochloride ៣០០ម.ក្រ ក្នុង២ម.ល :

ការចាក់Quinineគឺត្រូវចាក់យឺតៗបំផុត ហើយមិនត្រូវចាក់ត្រង់ទៅក្នុងសរសៃវ៉ែនទេ វាអាចធ្វើឲ្យគ្រោះថ្នាក់ដល់បេះដូង។ ត្រូវប្រុងប្រយ័ត្នបំផុតចំពោះការចាក់ឲ្យកុមារ។

ចាក់ពាក់កណ្តាលកម្រិតប្រើនេះទៅលើកំបេះគូថសងខាង។ មុនពេលចាក់ថ្នាំបញ្ចូល ត្រូវទាញសឺរ៉ាំងបឺតថយក្រោយ សិនបើមានឈាម ត្រូវចាក់កន្លែងផ្សេងទៀត។ ចាក់តាមកម្រិតប្រើដដែលនេះ នៅ១២ម៉ោងបន្ទាប់ទៀត :

មនុស្សធំ : ៦០០ម.ក្រ (អំពូលចំណុះ២ម.ល ២អំពូល)
កុមារ : ០,៧ម.ល (១/១៥ម.ល ឬ១០ម.ក្រ) សម្រាប់ទម្ងន់កុមារ១គ.ក្រ។ (កុមារអាយុ១ឆ្នាំ ដែលមានទម្ងន់ ១០គ.ក្រ នឹងត្រូវទទួល ០,៧០ម.ល)

ការចាក់Chloroquine ២០០ម.ក្រ ក្នុង៥ម.ល :

ចាក់តែ១កម្រិតប្រើប៉ុណ្ណោះ (ចាក់១/២កម្រិតប្រើ លើកំប៉េះគូថសងខាង):

មនុស្សធំ : ២០០ម.ក្រ (អំពូលចំណុះ៥ម.ល ១អំពូលពេញ)
កុមារ : ០,១ម.ល (១/១០ម.ល)សម្រាប់ទម្ងន់កុមារ ១គ.ក្រ។ (កុមារអាយុ១ឆ្នាំ ដែលមានទម្ងន់១០គ.ក្រ នឹងត្រូវទទួល ១ម.ល)

អាចចាក់១កម្រិតប្រើ ម្តងទៀតនៅថ្ងៃបន្ទាប់ ប្រសិនបើមិនទាន់ធូរស្រាល។

<u>Mefloquine</u> (ម៉ាកដែលធ្លាប់ស្គាល់ : *Lariam*)

ឈ្មោះ_______________តម្លៃ________សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ២៥០ម.ក្រ។

Mefloquineអាចបង្ការ និងបញ្ឈប់ជំងឺគ្រុនចាញ់ស្រួចស្រាល់ដែលស៊ាំនឹងChloroquine។

***ការប្រុងប្រយ័ត្ន និងផលរំខាន :*** Mefloquineមិនគួរផ្តល់ឲ្យអ្នកជំងឺជំងឺឆ្កួតជ្រូក ឬជំងឺផ្លូវចិត្តទេ។ ស្ត្រីមានផ្ទៃពោះអាចប្រើថ្នាំនេះតែក្នុងករណីគាត់មិនអាចប្រើថ្នាំផ្សេងបានប៉ុណ្ណោះ។ អ្នកដែលមានបញ្ហាបេះដូង គួរសុំដំបូន្មានពីបុគ្គលិកសុខាភិបាលជំនាញ មុននឹងប្រើថ្នាំនេះ។ ប្រើថ្នាំនេះជាមួយអាហារយ៉ាងច្រើន។ ជួនកាលMefloquineអាចធ្វើឲ្យមានអាកប្បកិរិយាចំឡែកៗ វង្វេង ធុញថប់ ឬសន្លប់។ **ប្រសិនបើមានសញ្ញាទាំងនេះណាមួយ ត្រូវឈប់ប្រើMefloquineជាបន្ទាន់។** ផលរំខានផ្សេងៗទៀតអាចមានជា វិលមុខ ធ្វើទុក្ខក្នុងក្រពះ ឈឺក្បាល និងបញ្ហាចក្ខុ។ ការប្រើកម្រិតថ្នាំខ្ពស់ នឹងឆាប់ធ្វើឲ្យមានផលរំខាន ហើយច្រើនតែធ្ងន់ធ្ងរ។

**កម្រិតប្រើ** Mefloquine :

*សម្រាប់ការព្យាបាលជំងឺគ្រុនចាញ់ស្រួចស្រាល់ :*

ឲ្យ ១ដង :

មនុស្សធំ : ៥គ្រាប់ (១២៥០ម.ក្រ)
កុមារអាយុ១២-១៥ឆ្នាំ : ៤គ្រាប់ (១០០០ម.ក្រ)
កុមារអាយុ៨-១១ឆ្នាំ : ៣គ្រាប់ (៧៥០ម.ក្រ)
កុមារអាយុ៥-៧ឆ្នាំ : ២គ្រាប់ (៥០០ម.ក្រ)
កុមារអាយុ១-៤ឆ្នាំ : ១គ្រាប់ (២៥០ម.ក្រ)
ទារកអាយុក្រោម១ឆ្នាំ : ១/២គ្រាប់ (១២៥ម.ក្រ)

*សម្រាប់ការបង្ការជំងឺគ្រុនចាញ់ :*

ឲ្យ ១ដង :

មនុស្សធំ : ១គ្រាប់ (២៥០ម.ក្រ)
កុមារទម្ងន់លើសពី៤៥គ.ក្រ : ១គ្រាប់ (២៥០ម.ក្រ)
កុមារទម្ងន់៣១-៤៥គ.ក្រ : ៣/៤គ្រាប់ (១៨៨ម.ក្រ)
កុមារទម្ងន់២០-៣០គ.ក្រ : ១/២គ្រាប់ (១២៥ម.ក្រ)
កុមារទម្ងន់១៥-១៩គ.ក្រ : ១/៤គ្រាប់ (៦៣ម.ក្រ)
កុមារទម្ងន់ក្រោម១៥គ.ក្រ : មិនគួរប្រើទេ។

Pyrimethamine **ជាមួយ** Sulfadoxine *(Fansidar)*

ឈ្មោះ______________តម្លៃ_______សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ផ្សំឡើងដោយ Pyrimethamine ២៥០ម.ក្រ និងSulfadoxine ៥០០ម.ក្រ។

*Fansidar* ត្រូវបានប្រើសម្រាប់ព្យាបាលជំងឺគ្រុនចាញ់ដែលស៊ាំនឹងថ្នាំ។

Fansidar**មិន**ត្រូវបានណែនាំឲ្យប្រើចំពោះស្ត្រីមានផ្ទៃពោះទេ។

***ប្រយ័ត្ន :*** Fansidarមិនគួរប្រើចំពោះអ្នកដែលធ្លាប់មានប្រតិកម្មនឹងថ្នាំSulfaពីមុនមកទេ។ ប្រសិនបើថ្នាំនេះធ្វើឲ្យមានកន្ទួលរមាស់ **ត្រូវផឹកទឹកឲ្យច្រើន ហើយឈប់លេបថ្នាំនេះ។**

*កម្រិតប្រើ* សម្រាប់ការព្យាបាលជំងឺគ្រុនចាញ់ស្រួចស្រាល់ :

ឲ្យ ១ដង :

មនុស្សធំ : ៣គ្រាប់
កុមារអាយុ៩-១៤ឆ្នាំ : ២គ្រាប់
កុមារអាយុ៤-៨ឆ្នាំ : ១គ្រាប់
កុមារអាយុ១-៣ឆ្នាំ : ១/២គ្រាប់
កុមារអាយុក្រោម១ឆ្នាំ : ១/៤គ្រាប់

Proguanil *(Paludrine)*

ឈ្មោះ______________តម្លៃ_______សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ១០០ម.ក្រ។

Proguanilត្រូវបានប្រើជាមួយChloroquineដើម្បីបង្ការកុំឲ្យជំងឺគ្រុនចាញ់ស៊ាំនឹងChloroquine។ Proguanilមិនប្រើសម្រាប់ព្យាបាលគ្រុនចាញ់ស្រួចស្រាល់នោះទេ។

Proguanil**គ្មាន**សុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះទេ។

***កម្រិតប្រើ*** Proguanilសម្រាប់ការបង្ការ :

ឲ្យថ្នាំនេះរាល់ថ្ងៃ ចាប់ពីថ្ងៃដែលបានចូលទៅតំបន់គ្រុនចាញ់ រហូតដល់ ២៨ថ្ងៃ ក្រោយពីចេញពីតំបន់នោះ។

មនុស្សធំ : ២គ្រាប់ (២០០ម.ក្រ)
កុមារអាយុ៩-១៤ឆ្នាំ : ១ ១/២គ្រាប់ (១៥០ម.ក្រ)
កុមារអាយុ៣-៨ឆ្នាំ : ១គ្រាប់ (១០០ម.ក្រ)
កុមារអាយុ១-២ឆ្នាំ : ១/២គ្រាប់ (៥០ម.ក្រ)
ទារកអាយុក្រោម១ឆ្នាំ : ១/៤គ្រាប់ (២៥ម.ក្រ)

Primaquine

ឈ្មោះ______________តម្លៃ_______សម្រាប់______

ច្រើនជាថ្នាំគ្រាប់Primaquine phosphate ២៦,៣ម.ក្រ ដែលមានជាតិPrimaquine ១៥គ.ក្រ។

ជាធម្មតាPrimaquineត្រូវបានប្រើបន្ទាប់ពីបានព្យាបាលជំងឺគ្រុនចាញ់ដោយChloroquine ឬថ្នាំគ្រុនចាញ់ដទៃទៀត ដើម្បីទប់ស្កាត់គ្រុនចាញ់មួយចំនួនមិនឲ្យកើតឡើងវិញ។ ចំពោះគ្រុនចាញ់ស្រួចស្រាល់ Primaquineមិនអាចធ្វើការតែម្នាក់វាបានទេ។

Primaquine**គ្មាន**សុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះ ឬស្ត្រីកំពុងបំបៅដោះកូនទេ។

***ផលរំខាន :*** ចំពោះមនុស្សមួយចំនួន ជាពិសេសអ្នកដែលមានស្បែកខ្មៅ ថ្នាំនេះអាចបណ្តាលឲ្យមានភាពស្លេកស្លាំង។ ចូររកដំបូន្មានពីគ្រូពេទ្យ។

***កម្រិតប្រើ*** Primaquine

ឲ្យថ្នាំនេះ១ថ្ងៃម្តង រយៈពេល១៤ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ១គ្រាប់ (ជាតិPrimaquine ១៥ម.ក្រ)
កុមារអាយុ៨-១២ឆ្នាំ : ១/២គ្រាប់ (ជាតិPrimaquine ៧ម.ក្រ)
កុមារអាយុ៣-៧ឆ្នាំ : ១/៤គ្រាប់ (ជាតិPrimaquine ៤ម.ក្រ)

Doxycyclin

Doxycyclinអាចប្រើសម្រាប់ព្យាបាលគ្រុនចាញ់ស្រួចស្រាល់បាន ប៉ុន្តែត្រូវប្រើជាមួយQuinine និងតែក្នុងតំបន់ដែលគ្រុនចាញ់ស៊ាំនឹងChloroquineប៉ុណ្ណោះ។ អ្នកដែលទៅលេងតំបន់នេះ គេអាចប្រើDoxycyclinរាល់ថ្ងៃដើម្បីការពារ។ មើលទំ.៣៥៦ សម្រាប់កម្រិតប្រើDoxycyclin គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន។

ស្ត្រីមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន **មិន**គួរប្រើថ្នាំនេះទេ។ ថ្នាំនេះក៏**មិន**ត្រូវបានណែនាំឲ្យប្រើចំពោះកុមារអាយុក្រោម៨ឆ្នាំដែរ លើកលែងតែគ្មានជម្រើសប៉ុណ្ណោះ។

## ថ្នាំសម្រាប់អាមីប និងធ្វាដ្យា

**ចំពោះជំងឺរាក ឬរាកមួលដែលបណ្តាលមកពីអាមីប** ជាទូទៅជុះញឹកញាប់ និងមានលាយឈាមនិងសំបោរយ៉ាងច្រើន។ ជារឿយៗមានការឈឺចាប់ក្នុងពោះវៀន ប៉ុន្តែគ្មានឬមានគ្រុនក្តៅបន្តិចបន្តួច។ រាកមួលបណ្តាលមកពីអាមីបនេះអាចព្យាបាលដោយ**Tinidazole**/**Metronidazole** ជាមួយ **Diloxanide furoate** ឬ **Tetracycline**។ **Chloroquine**អាចត្រូវបានប្រើនៅពេលដែលគេរកMetronidazoleមិនបាន ឬក្នុងករណីមានអាប់សែបង្កដោយពួកអាមីប។ **Iodoqulnol** ជាថ្នាំមួយទៀតដែលប្រើសម្រាប់ព្យាបាលរាកមួលបណ្តាលពីអាមីប ប៉ុន្តែវាអាចមានផលរំខានដ៏មានគ្រោះថ្នាក់។

ដើម្បីសម្លាប់អាមីបទាំងអស់នៅក្នុងពោះវៀន គេចាំបាច់ត្រូវព្យាបាលរយៈពេលយូរ (២-៣សប្តាហ៍) ហើយត្រូវចំណាយប្រាក់ច្រើនទៀតផង។ គេគួរតែបញ្ឈប់ការឲ្យថ្នាំ នៅពេលដែលអ្នកជំងឺគ្មានរោគសញ្ញាទៀតទេ ហើយអាមីបដែលនៅសល់តិចតួច គួរទុកឲ្យរាងកាយការពារដោយខ្លួនឯង។ ជាពិសេសក្នុងតំបន់ដែលឱកាសនៃការឆ្លងរោគថ្មី មានកម្រិតខ្ពស់។

ចំពោះរាគបណ្តាលមកពីថ្លាដ្យ៉ា លាមកច្រើនមានពណ៌លឿង ហើយពពុះៗ ប៉ុន្តែគ្មានឈាមឬសំបោរទេ។

Tinidazole

ឈ្មោះ:___________________________________

ច្រើនជា ថ្នាំគ្រាប់ ២៥០ និង ៥០០ម.ក្រ

Tinidazoleគឺជាថ្នាំដែលសាមញ្ញបំផុត និងមានតម្លៃថោកបំផុត សម្រាប់ព្យាបាលការបង្ករោគដោយពពួកអាមីប និងថ្លាដ្យ៉ា។ ដូចMetronidazoleដែរ វាក៏មានសារសំខាន់សម្រាប់ព្យាបាលការបង្ករោគក្នុងទ្វារមាសដោយពពួកទ្រីកូម៉ូណាស។

គ្រាប់ថ្នាំTinidazoleអាចត្រូវបានកិនបំបែក និងលាយជាមួយអាហារ ហើយលេបជាមួយអាហារនោះ។

***ប្រយ័ត្ន*** : (ដូចMetronidazoleដែរ) មិនត្រូវផឹកស្រានៅពេលលេបថ្នាំTinidazoleទេ ព្រោះវាអាចបណ្តាលឲ្យមានការក្អួតយ៉ាងធ្ងន់ធ្ងរ។

***បម្រាម*** : (ដូចMetronidazoleដែរ)។

***កម្រិតប្រើ*** សម្រាប់ការបង្ករោគដោយថ្លាដ្យ៉ា : ឲ្យ Tinidazoleតែម្តងគត់

- មនុស្សធំ ឲ្យ ២ក្រ.
- កុមារអាយុលើសពី៣ឆ្នាំ ឲ្យ ៥០ម.ក្រ/គ.ក្រ រហូតដល់ ២០០០ម.ក្រ

កម្រិតប្រើ សម្រាប់ការបង្ករោគដោយពពួកអាមីប : ឲ្យ Tinidazole ម្តងក្នុងមួយថ្ងៃ រយៈពេល៣ថ្ងៃ :

- មនុស្សធំ ២ក្រ.
- កុមារអាយុលើស៣ឆ្នាំ ៥០ម.ក្រ/គ.ក្រ រហូតដល់ ២ក្រ.

***កម្រិតប្រើ*** សម្រាប់ការបង្ករោគក្នុងទ្វារមាសដោយទ្រីកូម៉ូណាស : ស្ត្រីគួរលេប២ក្រ. តែម្តងគត់ (ជាទូទៅលេប ៥០០ម.ក្រ ចំនួន ៨គ្រាប់)។ គួរព្យាបាលទាំងបុរសនិងស្ត្រីក្នុងពេលជាមួយគ្នា (បុរសក៏ទទួលការព្យាបាលនេះដែរ ទោះបីជាគាត់គ្មានរោគសញ្ញាក៏ដោយ ឬបើមិនដូច្នេះទេ គាត់នឹងអាចចម្លងជំងឺនេះទៅស្ត្រីវិញទៀត)។

Metronidazole (ម៉ាកដែលធ្លាប់ស្គាល់ : *Flagyl*)

ឈ្មោះ:___________________________________

ច្រើនជា :

- ថ្នាំគ្រាប់ ២០០ ២៥០ ឬ ៥០០ម.ក្រ តម្លៃ____សម្រាប់__
- គ្រាប់ដាក់ក្នុងទ្វារ ៥០០ម.ក្រ តម្លៃ____សម្រាប់__

Metronidazoleមានប្រយោជន៍ចំពោះការបង្ករោគក្នុងពោះវៀនដែលបណ្តាលពីអាមីប និងថ្លាដ្យ៉ា ហើយពេលខ្លះចំពោះរាគដែលបណ្តាលមកពីប្រើអង់ទីប៊ីយ៉ូទិកដែលមានប្រសិទ្ធិភាពទូលាយ(ដូចជា Ampicillin)។ វាក៏មានប្រយោជន៍ផងដែរចំពោះការបង្ករោគក្នុងទ្វារមាសដែលបណ្តាលពីទ្រីកូម៉ូណាស ឬដោយបាក់តេរីណាមួយ។

***ប្រយ័ត្ន*** : ហាមពិសារជាតិស្រវឹង ពេលដែលប្រើថ្នាំ Metronidazole ព្រោះថាវានឹងធ្វើឲ្យក្អួតយ៉ាងខ្លាំង។

***បម្រាម*** : Metronidazoleអាចបណ្តាលឲ្យទារកកើតមកមិនគ្រប់លក្ខណៈ។ បើអាច ស្ត្រីមានផ្ទៃពោះគួរតែចៀសវាងប្រើថ្នាំនេះ ជាពិសេសក្នុងរយៈពេល៣ខែដំបូងនៃផ្ទៃពោះ។ ស្ត្រីកំពុងបំបៅដោះកូន ដែលប្រើថ្នាំនេះច្រើន មិនគួរបំបៅកូនក្នុងអំឡុងពេល២៤ម៉ោងក្រោយពីលេបថ្នាំនេះរួច។ អ្នកដែលមានបញ្ហាថ្លើម មិនគួរប្រើថ្នាំនេះទេ។

***កម្រិតប្រើ*** សម្រាប់ការបង្ករោគដែលបណ្តាលមកពីថ្លាដ្យ៉ា :

ឲ្យMetronidazole ៣ដងក្នុង១ថ្ងៃ រយៈពេល៥ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ២៥០ម.ក្រ (១គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ២៥០ម.ក្រ (១គ្រាប់)
- កុមារអាយុ៣-៧ឆ្នាំ : ១២៥ម.ក្រ (១/២គ្រាប់)
- កុមារអាយុក្រោម៣ឆ្នាំ : ៦២ម.ក្រ (១/៤ម.ក្រ)

កម្រិតប្រើ សម្រាប់ការបង្ករោគក្នុងទ្វារមាសដែលបណ្តាលមកពី **ទ្រីកូម៉ូណាស** :

ស្ត្រីគួរលេប ៨គ្រាប់(២ក្រ.) ក្នុង១កម្រិតប្រើ។ ឬបើការបង្ករោគមិនសូវជាធ្ងន់ទេ គាត់អាចប្រើថ្នាំសុលតាមទ្វារមាស ២គ្រាប់ (៥០០ម.ក្រ) ២ដង ក្នុង១ថ្ងៃ រយៈពេល១០ថ្ងៃ។ ទាំងបុរសនិងស្ត្រីគួរទទួលការព្យាបាលទ្រីកូមីណាសជាមួយគ្នា ក្នុងពេលតែមួយ។ (បុរសគួរធ្វើបែបនេះ ទោះជាគាត់មិនមានរោគសញ្ញាក៏ដោយ បើមិនដូច្នោះទេ គាត់នឹងចម្លងទៅស្ត្រីវិញជាមិនខាន)។

កម្រិតប្រើ សម្រាប់ការបង្ករោគក្នុងទ្វារមាសដែលបណ្តាលមក **ពីបាក់តេរី**

ស្ត្រីគួរលេបMetronidazole ២គ្រាប់(៥០០ម.ក្រ) ២ដងក្នុង១ថ្ងៃ រយៈពេល៥ថ្ងៃ។ ប្រសិនបើការបង្ករោគនោះកើតម្តងទៀត នោះទាំងបុរសនិងស្ត្រីគួរទទួលការព្យាបាលជាមួយគ្នាក្នុងពេលតែមួយ។

កម្រិតប្រើ សម្រាប់**រាគមួលបណ្តាលមកពីអាមីម** (២៥ ទៅ ៥០ម.ក្រ/គ.ក្រ/ថ្ងៃ) : ប្រើថ្នាំគ្រាប់ ២៥០ម.ក្រ។

ឲ្យMetronidazole ៣ដងក្នុង១ថ្ងៃ រយៈពេល៥-១០ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ៧៥០ម.ក្រ (៣គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ៥០០ម.ក្រ (២គ្រាប់)
- កុមារអាយុ៤-៧ឆ្នាំ : ៣៧៥ម.ក្រ (១ ១/២គ្រាប់)
- កុមារអាយុ២-៣ឆ្នាំ : ២៥០ម.ក្រ (១គ្រាប់
- កុមារអាយុក្រោម២ឆ្នាំ : ៨០-១២៥ម.ក្រ (១/៣ - ១/២ម.ក្រ)

ក្នុងការព្យាបាលរោគមូលបណ្តាលពីអាមីប គេគួរតែប្រើ MetronidazoleជាមួយDiloxanide furoate ឬ Tetracycline។

Diloxanide furoate *( Furamide )*

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជា :

ថ្នាំគ្រាប់ ៥០០ម.ក្រ និងស៊ីរ៉ូ ១២៥ម.ក្រ ក្នុង៥ម.ល

ផលរំខាន : ករណីកម្រខ្លះវាអាចបណ្តាលឲ្យធ្លល់ពោះ ឈឺចាប់ក្នុងក្រពះ ឬចង្អោរ។

កម្រិតប្រើ Diloxanide furoate (២០ម.ក្រ/គ.ក្រ/ថ្ងៃ): ថ្នាំគ្រាប់ ៥០០ម.ក្រ។

ឲ្យ ៣ដងក្នុង១ថ្ងៃ ជាមួយអាហារ។ សម្រាប់ការព្យាបាលឲ្យចប់សព្វគ្រប់ ត្រូវលេបរយៈពេល១០ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ១គ្រាប់ (៥០០ម.ក្រ)
កុមារអាយុ៨-១២ឆ្នាំ : ១/២គ្រាប់ (២៥០ម.ក្រ)
កុមារអាយុ៣-៧ឆ្នាំ : ១/៤គ្រាប់ (១២៥ម.ក្រ)
កុមារអាយុក្រោម៣ឆ្នាំ : ១/៨គ្រាប់ (៦២ក្រ.) ឬតិចជាងនេះ អាស្រ័យលើទម្ងន់កុមារ

Tetracycline (មើលទំ.៣៥៦)

Chloroquine សម្រាប់ការព្យាបាលអាប់សែថ្លើម ដែលបណ្តាលពីអាមីប ត្រូវប្រើថ្នាំគ្រាប់Chloroquine phosphate ២៥០ម.ក្រ ឬថ្នាំChloroquine sulfate ២០០ម.ក្រ :

មនុស្សធំ : ៣ឬ៤គ្រាប់ ២ដងក្នុង១ថ្ងៃ រយៈពេល២ថ្ងៃ បន្ទាប់មកឲ្យ ១ ១/២គ្រាប់ ឬ២គ្រាប់រាល់ថ្ងៃ រយៈពេល ៣សប្តាហ៍។ ចំពោះកុមារ ត្រូវឲ្យតិចជាងនេះ អាស្រ័យតាមអាយុ ឬទម្ងន់(មើលទំ.៣៦៦)។

Quinacrine ( mepacrine )
(ម៉ាកដែលធ្លាប់ស្គាល់ : *Atabrine*)

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ១០០ម.ក្រ។

Quinacrineអាចប្រើសម្រាប់ព្យាបាលថ្លាដ្យ៉ា គ្រុនចាញ់ និងព្រូនទំពក់ ប៉ុន្តែវាមិនមែនជាថ្នាំដែលល្អបំផុតសម្រាប់ជំងឺទាំងនេះទេ។ គេប្រើវាព្រោះវាមានតម្លៃថោក។ Quinacrineច្រើនតែធ្វើឲ្យឈឺក្បាល វិលមុខ និងក្អួត។

***កម្រិតប្រើ*** Quinacrineសម្រាប់ការព្យាបាល**ថ្លាដ្យ៉ា** :

ឲ្យ Quinacrine ៣ដងក្នុង១ថ្ងៃ រយៈពេល១សប្តាហ៍។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ១គ្រាប់ (១០០ម.ក្រ)
កុមារអាយុក្រោម១០ឆ្នាំ : ៥០ម.ក្រ (១/២គ្រ.)



***កម្រិតប្រើ*** Quinacrineសម្រាប់ការព្យាបាល**ព្រូនទំពក់** :

(នៅកន្លះម៉ោងមុននឹងឲ្យQuinacrine ត្រូវឲ្យ Antihistamine ដូចជា **Promethazine** ដើម្បីកុំឲ្យក្អួត)។

ឲ្យតែ ១កម្រិតធំប៉ុណ្ណោះ :

មនុស្សធំ : ១ក្រ. (១០គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ៦០០ម.ក្រ (៦គ្រាប់)
កុមារអាយុ៣-៧ឆ្នាំ : ៤០០ម.ក្រ (៤គ្រាប់)

**គ្រោះថ្នាក់! ហាមប្រើ!**

Hydroxyquinolines ( clioquinol, iodoquinol, di-iodohydroxyquinoline, halquinol, broxyquinoline )
(ម៉ាកដែលធ្លាប់ស្គាល់ : *Diodoquin, Amicline, Floraquin, Enteroquinol, Chlorambin, Nivembin, Quogyl, Entero-Vioform,* និងប្រភេទជាច្រើនទៀត)

ថ្នាំទាំងនេះធ្លាប់ត្រូវបានប្រើញឹកញាប់ក្នុងការព្យាបាលជំងឺរាក។ សព្វថ្ងៃ គេរកឃើញថាវាអាចបណ្តាលឲ្យខ្វិនអស់មួយជីវិត ងងឹតភ្នែក ហើយអាចដល់ស្លាប់។ សូមកុំប្រើថ្នាំដែលគ្រោះថ្នាក់ទាំងនេះឲ្យសោះ(មើលទំ.៥១)។

## ការបង្ករោគក្នុងទ្វារមាស

ការធ្លាក់ស រមាស់ និងភាពមិនស្រួល កើតបណ្តាលមកពីការបង្ករោគផ្សេងៗគ្នា តែការបង្ករោគដែលកើតមានញឹកញាប់ជាងគេគឺ ទ្រីកូម៉ូណាស និងរោគផ្សិត(មេរោគផ្សិត ម៉ូនីលីយ៉ាស៊ីស) និងបាក់តេរី ។ ការសម្អាត និងលាងយោនីដោយទឹកខ្មេះ អាចជួយបង្ការការបង្ករោគជាច្រើន។ ថ្នាំសម្រាប់ការបង្ករោគទាំងនេះ មួយចំនួនត្រូវបានរៀបរាប់ខាងក្រោមនេះ។

**ទឹកខ្មេះសម្រាប់លាងទ្វារមាស :**

តម្លៃ___________សម្រាប់________

លាយទឹកខ្មេះ ២ឬ៣ស្លាបព្រាបាយ និងទឹកឆ្អិន១លីត្រ។ ដូចបានបង្ហាញនៅទំ.២៤១ លាង១ទៅ៣ដងក្នុង១ថ្ងៃ រយៈពេល១សប្តាហ៍ បន្ទាប់ពីនោះមក លាង១ដងក្នុង១ថ្ងៃ។ វិធីនេះមានប្រសិទ្ធភាពជាពិសេសចំពោះការបង្ករោគក្នុងទ្វារមាស ដែលបង្កដោយបាក់តេរី។

Metronidazole ជាថ្នាំគ្រាប់សម្រាប់លេប និងថ្នាំសម្រាប់ដាក់ក្នុងទ្វារមាស (មើលទំ.៣៦៩):

សម្រាប់ការបង្ករោគក្នុងទ្វារមាសបង្កដោយទ្រីកូម៉ូណាស និងបាក់តេរី។ (ចូរប្រើតែMetronidazoleប៉ុណ្ណោះសម្រាប់ការបង្ករោគដោយបាក់តេរី ប្រសិនបើការលាងសម្អាតដោយទឹកខ្មេះនិងទឹក គ្មានប្រសិទ្ធភាព)។

Nystatin ឬ Miconazole ជាថ្នាំគ្រាប់ ក្រែម និងថ្នាំដាក់ក្នុងទ្វារមាស (មើលទំ.៣៧៣): សម្រាប់ការបង្ករោគក្នុងទ្វារមាសបង្កដោយមេរោគផ្សិត។

Gentian violet (crystal violet) ជាទឹកលាយថ្នាំ ១ភាគរយ (មើលទំ. ៣៧១):

តម្លៃ____________សម្រាប់_________

សម្រាប់ព្យាបាលការបង្ករោគក្នុងទ្វារមាសបណ្តាលមកពីមេរោគផ្សិត។

លាបថ្នាំនេះ ១ថ្ងៃម្តង រយៈពេល៣សប្តាហ៍។

Povidone iodine *(Betadine)*

តម្លៃ____________សម្រាប់_________

សម្រាប់ព្យាបាលការបង្ករោគក្នុងទ្វារមាសបណ្តាលមកពីបាក់តេរី។

លាយ Povidone iodine ២ស្លាបព្រាបាយ និងទឹកក្តៅឧណ្ហៗ ១លីត្រដែលដាំពុះហើយ។ ដូចបានបង្ហាញនៅទំ.២៤១ លាង១ថ្ងៃម្តង រយៈពេល១០-១៤ថ្ងៃ។

# សម្រាប់ជំងឺសើស្បែក

ការលាងសម្អាតដៃ និងដុតទឹកញឹកញាប់ដោយដុះសាប៊ូ ជួយការពារការបង្ករោគជាច្រើន ទាំងសើស្បែក និងលើពោះវៀន។ ដំបៅត្រូវលាងឲ្យស្អាតនឹងទឹកឆ្អិនជាមួយសាប៊ូ មុននឹងបិទឬរុំបង់។

ការដុសលាងជាញឹកញាប់ជាមួយសាប៊ូនិងទឹក ភាគច្រើនជាមធ្យោបាយតែមួយគត់ដែលចាំបាច់សម្រាប់កំចាត់អង្កែ ខ្លាញ់រងើម ពងលើស្បែក ពងបែកកម្រិតស្រាល ក៏ដូចជាជំងឺស្រែងរមាស់ និងការបង្ករោគផ្សេងៗទៀតលើស្បែកនិងក្បាលដែលបង្កឡើងដោយមេរោគផ្សិត។ ដោយបញ្ហាទាំងនេះ ជាការប្រសើរប្រសិនបើសាប៊ូដែលយើងប្រើមានជាតិអង់ទីសិបទិក ដូចiodine ដូចជា Povidone iodine *(Betadine)*។ ប៉ុន្តែ *Betadine* អាចធ្វើឲ្យរមាស់ជាលិកា និងមិនគួរប្រើនៅស្បែកផ្ទាល់ដោយចំហនោះទេ។

Sulfur

ច្រើនមានជាម្សៅពណ៌លឿង

តម្លៃ____________________សម្រាប់__________

ក៏មានជាប្រេងលាបស្បែក និងក្រមួនផងដែរ។

Sulfurមានប្រយោជន៍ក្នុងការព្យាបាលជំងឺសើស្បែកច្រើនប្រភេទ :

១. សម្រាប់កុំឲ្យកើតតឹកកែ តឹកកែខ្សាច់ ចៃពស់ ស្រមើលចៃ។ មុននឹងចូលទៅក្នុងចំការ ឬព្រៃដែលសំបូរសត្វល្អិតទាំងនេះ សូមលាបSulfurនេះ ជាពិសេសនៅជើង កជើង កដៃ ចង្កេះ និងក។

២. ជួយព្យាបាលកមរមាស់ ដំបៅមកពីចៃ ឬសត្វដូចរៀបរាប់ខាងលើ។ ធ្វើថ្នាំក្រមួន : លាយSulfur ១ភាគ១០ នៃប្រេងរំអិល*(Vaseline)* ឬខ្លាញ់ ហើយលាបលើស្បែក (មើលទំ.២០០)។

៣. ចំពោះស្រែង ជំងឺផ្សេងៗដែលបង្កដោយមេរោគផ្សិត ចូរប្រើថ្នាំក្រមួនដដែល ៣ឬ៤ដង ក្នុង១ថ្ងៃ ឬប្រើប្រេងលាបស្បែកធ្វើពីSulfur និងទឹកខ្មេះ (មើលទំ.២០៥)។

៤. ចំពោះអង្កែ ខ្លាញ់រងើមស្បែក អាចប្រើថ្នាំក្រមួនដដែល ឬលាបSulfurលើស្បែកក្បាល។

Gentian violet (crystal violet)

ច្រើនមានជាដុំពណ៌ខៀវក្រមៅ តម្លៃ_____សម្រាប់____

Gentian violetជួយកំចាត់ជំងឺសើស្បែកមួយចំនួន រួមមានពងបែក ដំបៅមានខ្ទុះ។ វាក៏អាចប្រើក្នុងការព្យាបាលការបង្ករោគដោយជាតិផ្សិត នៅក្នុងមាត់ យោនី និងតាមផ្នត់ស្បែក។

លាយGentian violet ១ស្លាបព្រាកាហ្វេ ជាមួយទឹកកន្លះលីត្រ។ ធ្វើដូចនេះនឹងទទួលបានទឹកលាយថ្នាំ ២ភាគរយ។ លាបលើស្បែក ក្នុងមាត់ និងលើបបូរយោនី។

**ក្រមួនអង់ទីប៊ីយ៉ូទិក**

ឈ្មោះ_______________តម្លៃ________សម្រាប់_______

ថ្នាំនេះមានតម្លៃថ្លៃ ហើយភាគច្រើនក៏គ្មានប្រសិទ្ធិភាពជាង Gentian violetដែរ។ ទោះជាយ៉ាងនេះក៏ដោយ ថ្នាំនេះមិនបណ្តាលឲ្យប្រឡាក់ស្បែក ឬសំលៀកបំពាក់ទេ ហើយវាអាចប្រើបានសម្រាប់ព្យាបាលជំងឺសើស្បែកតូចតាច ដូចជាពងបែក។ ថ្នាំក្រមួនដែលល្អគឺមានជាតិneomycin លាយជាមួយ polymyxin (ឧ. *Neosporin* ឬ *Polysporin*)។ ថ្នាំក្រមួន Tetracyclineក៏អាចប្រើបានដែរ។

**ក្រមួន ឬ ប្រេង Cortico-steroid**

ឈ្មោះ______________តម្លៃ________សម្រាប់______

ថ្នាំនេះសម្រាប់ប្រើចំពោះការចេញទឹករងៃ ឬរមាស់លើស្បែកយ៉ាងខ្លាំងបណ្តាលមកពីសត្វល្អិតខាំ ឬប៉ះនឹងរុក្ខជាតិពុល និងវត្ថុអ្វីផ្សេងទៀត។ វាក៏មានប្រយោជន៍ក្នុងការព្យាបាលជំងឺរើមធ្ងន់ធ្ងរ (មើលទំ.២១៦) និងស្រែង (មើលទំ.២១៦)។ ប្រើ ៣ទៅ៤ដងក្នុង១ថ្ងៃ។ ចៀសវាងប្រើវាក្នុងរយៈពេលយូរ ឬលាបលើបរិវេណស្បែកធំពេក។

**ចាហ៊ួយរំអិល (petrolatum, *Vaseline*)**

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនប្រើសម្រាប់ធ្វើថ្នាំក្រមួន ឬសម្រាប់រុំ នៅក្នុងការព្យាបាល

- កមររមាស់(មើលទំ.១៩៩ និង៣៧៣)
- ស្រែង(មើលទំ.៣៧២
- រមាស់ដោយសារព្រូនទំពក់(មើលទំ.១៤១
- រលាក(មើលទំ.៩៦ និង៩៧)
- ដំបៅទ្រូង(មើលទំ.៩១)។

## សម្រាប់ស្រែង និងការបង្ករោគដោយមេរោគផ្សិតផ្សេងៗទៀត

ការបង្ករោគដោយមេរោគផ្សិតជាច្រើនប្រភេទ មានការពិបាកក្នុងការព្យាបាលណាស់។ ដើម្បីបញ្ឈប់វាទាំងស្រុង ការព្យាបាលត្រូវបន្តច្រើនថ្ងៃ ឬច្រើនសប្តាហ៍ បន្ទាប់ពីរោគសញ្ញាបាត់អស់ទៅ។ ការងូតទឹក និងដុសលាងសម្អាត ក៏ជាការសំខាន់ដែរ។

**ថ្នាំក្រមួនមានជាតិអាស៊ីតundecylenic, benzoic, ឬ salicylic acid**

ឈ្មោះ______________តម្លៃ________សម្រាប់______

ថ្នាំក្រមួនដែលមានជាតិអាស៊ីតទាំងនេះ អាចប្រើសម្រាប់ព្យាបាលជំងឺស្រែង កមររមាស់ និងការបង្ករោគលើស្បែកដោយមេរោគផ្សិតផ្សេងទៀត។ ជាញឹកញាប់វាអាចត្រូវបានផ្សំជាមួយនឹងSulfur។ ថ្នាំក្រមួនដែលផ្សំជាមួយអាស៊ីតsalicylic និង Sulfur ក៏អាចប្រើសម្រាប់ព្យាបាលកមររមាស់បានដែរ។

ថ្នាំក្រមួនWhitfield's ផ្សំឡើងដោយ អាស៊ីតsalicylic និងអាស៊ីតbenzoic។ វាមានប្រយោជន៍សម្រាប់ព្យាបាលការបង្ករោគដោយមេរោគផ្សិត រួមទាំងភ្លឺផងដែរ។ លាប១ថ្ងៃ២ដង រយៈពេល២ទៅ៤សប្តាហ៍។

អ្នកនឹងចំណាយអស់តិចបើអ្នកធ្វើក្រមួន ឬប្រេងដោយខ្លួនឯង។ ចូរលាយអាស៊ីតsalicylic ៣ភាគ និង/ឬ អាស៊ីត benzoic ៦ភាគ ជាមួយ***វ៉ាសឺលីន*** ១០០ភាគ ប្រេងកាតប្រេងរ៉ែ ខ្លាញ់ជ្រូក ឬអាល់កុល ៤០ភាគរយ។ លាបលើស្បែក ៣ទៅ៤ដងក្នុង១ថ្ងៃ។

**Sulfur និងទឹកខ្មេះ**

ប្រេងដែលផ្សំដោយSulfur ៥ភាគ និងទឹកខ្មេះ ១០០ភាគ ជួយកំចាត់ការបង្ករោគលើស្បែកដែលបណ្តាលមកពីដោយមេរោគផ្សិត។ ទុកវាឲ្យស្ងួតលើស្បែក។ ថ្នាំក្រមួនក៏អាចផ្សំដោយស្ពាន់ធ័រមួយភាគ នឹងខ្លាញ់ជ្រូក ១០ភាគបានដែរ។

**Sodium thiosulfate ('hypo')**

ច្រើនមានជាដុំពណ៌ស ឈ្មោះ 'hypo' ដែលមានលក់នៅហាងលក់ម៉ាស៊ីនថតរូប។ តម្លៃ________សម្រាប់______

ប្រើសម្រាប់**ជំងឺភ្លឺ** (មើលទំ.២០៦)។

លាយថ្នាំនេះ ១ស្លាបព្រាបាយនឹងទឹកកន្លះពែង ហើយលាបស្បែកដោយប្រើសំឡី ឬក្រណាត់។ រួចដុសស្បែកនឹងសំឡីជ្រលក់ទឹកខ្មេះ។ ធ្វើដូចនេះ ២ដង១ថ្ងៃ រហូតដល់បាត់ចំណុចភ្លឺអស់ បន្ទាប់មកលាប១ដងរៀងរាល់២សប្តាហ៍ ដើម្បីកុំឲ្យវាកើតឡើងវិញ។

**Sodium thiosulfate (*Selsun, Exsel*)**

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាប្រេងដែលមានselenium sulfide ១ ឬ ២,៥%។

ប្រេងដែលមានselenium sulfide មានប្រយោជន៍ក្នុងការព្យាបាលជំងឺភ្លឺ។ លាបលើកន្លែងដែលកើត ហើយលាងទឹកចេញ នៅ៣០នាទីបន្ទាប់។ លាប១ថ្ងៃម្តង រយៈពេល១សប្តាហ៍។

**Tolnaftate (*Tinactin*)**

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាក្រែម ម្សៅ និងទឹកលាយថ្នាំដែលមានTolnaftate ១%។

ថ្នាំនេះអាចមានប្រយោជន៍សម្រាប់កម្ចាត់មេរោគដែលធ្វើឲ្យចេញស្រែងនៅតាមជើង ក្បែរប្រដាប់ភេទ លលាដ៏ក្បាល ដៃ និងតាមដងខ្លួន។ លាប២ដងក្នុង១ថ្ងៃ។ បន្ទាប់ពីបាត់រោគសញ្ញាអស់ ត្រូវបន្តលាបរយៈពេល២សប្តាហ៍ទៀត។

**Griseofulvin**

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ២៥០ ឬ៥០០ម.ក្រ។

ថ្នាំជាទំរង់គ្រាប់ "តូចៗ" គឺជាការល្អបំផុត។

ថ្នាំនេះមានតម្លៃថ្លៃណាស់ ហើយគួរប្រើសម្រាប់ព្យាបាលការបង្ករោគលើស្បែកដោយមេរោគផ្សិតធ្ងន់ធ្ងរ និងរោគរមាស់តាមស្រទាប់ជ្រៅនៃលលាដ៏ក្បាលប៉ុណ្ណោះ។ វាក៏ត្រូវបានប្រើផងដែរសម្រាប់ព្យាបាលរោគផ្សិតក្រចក ប៉ុន្តែវាត្រូវការពេលវេលាច្រើនខែ ហើយមិនប្រាកដថាជាទេ។ ស្ត្រីមានផ្ទៃពោះគួរចៀសវាងប្រើGriseofulvin។

***កម្រិតប្រើ*** Griseofulvin (១៥ម.ក្រ/គ.ក្រ/ថ្ងៃ): សម្រាប់ថ្នាំគ្រាប់ ២៥០ម.ក្រ។

ចូរឲ្យ១ថ្ងៃម្តង រយៈពេលយ៉ាងតិច១ខែ :

- មនុស្សធំ : ៥០០-១០០០ម.ក្រ (២-៤គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ២៥០-៥០០ម.ក្រ (១-២គ្រាប់)
- កុមារអាយុ៣-៧ឆ្នាំ : ១២៥-២៥០ម.ក្រ (១/២-១គ្រាប់)
- កុមារអាយុក្រោម៣ឆ្នាំ : ១២៥ម.ក្រ (១/២គ្រាប់)

Gentian violet សម្រាប់ជ្រាំង (មើលទំ.៣៧១)។

Nystatin ឬ Miconazole

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជាទឹកលាយថ្នាំ ម្សៅម៉ត់ គ្រាប់សុលតាមទ្វារមាស ក្រមួន និងក្រែម។

ប្រើសម្រាប់ព្យាបាលជ្រាំងនៅក្នុងមាត់ ទ្វារមាស ឬនៅតាមផ្នត់ស្បែក។ Nystatin កបនឹងជំងឺដែលបង្កដោយមេរោគផ្សិតប៉ុណ្ណោះ ប៉ុន្តែ Miconazole ក៏កបនឹងមេរោគផ្សិតផ្សេងៗទៀតផងដែរ។

***កម្រិតប្រើ*** Nystatin និងMiconazole ប្រើដូចគ្នាទាំងកុមារ និងមនុស្សធំ :

**ជ្រាំងក្នុងមាត់** : បៀមថ្នាំទឹក១ម.លក្នុងមាត់ យ៉ាងតិច១នាទី មុននឹងលេប។ ធ្វើយ៉ាងនេះ៣ឬ៤ដងក្នុង១ថ្ងៃ។

**ការបង្ករោគនៅលើស្បែកដោយមេរោគផ្សិត** : ប្រើម្សៅ ឬក្រមួនNystatin ឬ Miconazole លាបលើស្បែកដែលស្ងួត ៣ទៅ៤ដងក្នុង១ថ្ងៃ។

**ការបង្ករោគផ្សិតនៅក្នុងទ្វារមាសដោយមេរោគផ្សិត** : លាបថ្នាំក្រែមក្នុងទ្វារមាស ២ដងក្នុង១ថ្ងៃ ឬប្រើថ្នាំគ្រាប់ដាក់ក្នុងទ្វារមាសរៀងរាល់យប់ រយៈពេល១០ទៅ១៤ថ្ងៃ។

## សម្រាប់កមរមាស់ និងចៃ ថ្នាំសម្លាប់សត្វល្អិត

Gamma benzene hexachloride (lindane)
(ឈ្មោះពាណិជ្ជកម្ម: *Kwell, Gammezane*)

ឈ្មោះ______________តម្លៃ________សម្រាប់______

ថ្នាំនេះមានតម្លៃថ្លៃសម្រាប់មនុស្ស និងតម្លៃថោកសម្រាប់សត្វពាហនៈដែលវាមានប្រសិទ្ធិភាពចំពោះមនុស្សដូចគ្នាដែរ។ ថ្នាំដំណក់lindaneដែលប្រើសម្រាប់ចៀម ឬសត្វស្រុកផ្សេងទៀត មានតម្លៃថោក ប៉ុន្តែវាច្រើនមានជាតិហាប់សូលុយស្យុង ១៥% ហើយត្រូវលាយទឹករហូតនៅសល់១%។ លាយកំហាប់ lindane១៥% ចំនួន១ភាគ ជាមួយនឹងទឹកឬ ***វ៉ាសឺលីន***១៥ភាគ រួចលាបលើកមរមាស់ ដូចបានបង្ហាញនៅក្នុងទំ.១៩៩។ សម្រាប់ចៃក្បាល មើលទំ.២០០។

*ប្រយ័ត្ន :* lindaneមានជាតិពុល ហើយអាចបណ្តាលឲ្យមានផលរំខានដ៏គ្រោះថ្នាក់ ដូចជាប្រកាច់ ជាពិសេសចំពោះទារក។ កុំប្រើlindaneលើសកម្រិតឲ្យសោះ។ លាបតែម្តងបានហើយ ឬបើចាំបាច់ លាបម្តងទៀតនៅសប្តាហ៍បន្ទាប់។

Benzyl benzoate **ជាក្រែមលាប ឬប្រេងលាបស្បែក**

ឈ្មោះ______________តម្លៃ________សម្រាប់______

ប្រើដូចគ្នានឹងក្រែមលាប ឬប្រេងលាបស្បែក gamma benzene hexachloride (lindane) ដែរ។

Sulfur**ជាចាហ៊ួយរំអិល *(វ៉ាសឺលីន)* ឬខ្លាញ់**

ប្រើសម្រាប់កមរមាស់ បើរកថ្នាំខាងលើមិនបានទេ។

លាយSulfur១ភាគ នឹងវ៉ាសឺលីន ឬប្រេងរ៉ៃ ឬខ្លាញ់ ២០ភាគ ដើម្បីទទួលបានជាក្រមួនSulfur ៥%។

Pyrethrins **ជាមួយនឹង** piperonyl *(RID)*

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជាថ្នាំទឹកសម្រាប់លាយ ដែលមានPyrethrins និងpiperonyl butoxide។

មានប្រសិទ្ធិភាពចំពោះគ្រប់ប្រភេទចៃ និងមានសុវត្ថិភាពជាងgamma benzene hexachloride (lindane)។ កុំលាយទឹកបន្ថែម រួចលាបលើសក់ដែលបានសម្ងួតហើយ រហូតទាល់សើមជោគសព្វកន្លែង។ (កុំលាបលើចិញ្ចើម ឬត្របកភ្នែក)។ ទុក១០នាទី ហើយកុំឲ្យយូរជាងនេះ។ លាងសក់ចេញនឹងទឹកក្តៅឧណ្ឌៗជាមួយសាប៊ូ។ លាបម្តងទៀតនៅសប្តាហ៍បន្ទាប់។ ផ្លាស់ប្តូរសំលៀកបំពាក់ពូកខ្នើយក្រោយពេលព្យាបាលរួច។ ចំពោះការកំចាត់ពងចៃ មើលទំ.២០០។

Crotamiton *(Eurax)*

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាក្រែមលាប ឬប្រេងលាបស្បែក ដែលមានជាតិ Crotamiton ១០%។

Crotamiton ប្រើសម្រាប់ព្យាបាលកមរមាស់ប៉ុណ្ណោះ មិនមែនចៃទេ។ ក្រោយពេលងូតទឹករួច លាបពេញខ្លួនទាំងអស់ចាប់ពីចង្ការដល់មេជើង។ កុំរំលងកន្លែងផ្នត់ឬជ្រួញ! អាចលាបម្តងទៀតនៅថ្ងៃបន្ទាប់។ ងូតទឹកនៅ២ថ្ងៃក្រោយបន្ទាប់ពីលាបលើកចុងក្រោយ ដើម្បីជំរះឲ្យអស់នូវក្រែម ឬប្រេងលាប។ គួរផ្លាស់ប្តូរសំលៀកបំពាក់ពួកខ្នើយនាពេលនេះ។

## សម្រាប់ការដុះដុំសាច់លើប្រដាប់ភេទ (សេមាន់)

Podophyllin

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំទឹក ដែលមានPodophyllin ១០-២៥% ជាមួយbenzoin។

វាប្រើសម្រាប់បង្រួញសេមាន់។ Podophyllinធ្វើឲ្យក្រហាយដល់ស្បែកដែលមិនមានជំងឺ ដូច្នេះត្រូវប្រើដោយប្រយ័ត្ន។ មុនពេលលាប គួរការពារស្បែកជុំវិញសេមាន់នោះ ដោយចាហ្វ៊ុយរំអិល (*វ៉ាសឺលីន*) ឬក្រមួនជាតិប្រេងផ្សេងទៀត។ លាបថ្នាំទឹកនេះលើសេមាន់ ហើយទុកវាឲ្យស្ងួតទាំងស្រុង។ (វាជាការសំខាន់ណាស់ ជាពិសេសចំពោះស្បែកធម្មតាដែលវាអាចប៉ះនឹងដុំសាច់នេះ ដូចជាស្បែកលិង្គ)។ លាងទឹកចេញឲ្យស្អាតបន្ទាប់ពី៤ទៅ៦ម៉ោង។ អាចលាបម្តងទៀតនៅសប្តាហ៍បន្ទាប់។ ជាធម្មតាគេត្រូវការព្យាបាលច្រើនសប្តាហ៍។

***ប្រយ័ត្ន :*** ប្រសិនបើមានការក្រហាយដល់ស្បែកយ៉ាងខ្លាំង ចូរឈប់លាបវា។ Podophyllin មិនគួរលាបនៅលើសេមាន់ដែលមានហូរឈាមទេ។ ស្ត្រីមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន មិនគួរប្រើPodophyllinទេ។

Trichloroacetic acid

ឈ្មោះ______________តម្លៃ________សម្រាប់______

មានជាថ្នាំទឹកគ្មានពណ៌។

ប្រសិនបើមិនអាចរកPodophyllinបានទេ គេអាចប្រើ Trichloroacetic acidដើម្បីបង្រួញសេមាន់។ វាក៏ធ្វើឲ្យប៉ះពាល់ដល់ស្បែកធម្មតាដែរ ដូច្នេះត្រូវតែប្រើដោយប្រយ័ត្នបំផុត។ ការពារស្បែកដែលនៅជុំវិញសេមាន់ដោយវ៉ាសឺលីន ឬក្រមួនជាតិប្រេងផ្សេងទៀត។ កាត់ស្បែកដែលងាប់ចេញពីសេមាន់ដែលធំឬក្រាស់ដោយប្រុងប្រយ័ត្ន។ ប្រើឈើចាក់ធ្មេញជ្រលក់ថ្នាំនេះ រួចលាបលើសេមាន់នោះថ្នមៗ។ អាចលាបច្រើនសារក្នុងការព្យាបាលនេះ ហើយលាបមួយសប្តាហ៍ម្តង។

***ប្រយ័ត្ន :*** អាស៊ីដមួយនេះអាចធ្វើឲ្យរលាកយ៉ាងធ្ងន់ធ្ងរ។ ចូរការពារដៃនិងស្បែកធម្មតា កុំឲ្យប៉ះនឹងអាស៊ីដនេះ ហើយលាងទឹកចេញជាបន្ទាន់ប្រសិនបើអាស៊ីដប៉ះនឹងស្បែក។

## សម្រាប់ព្រូន

ថ្នាំពេទ្យតែមួយមុខមិនគ្រប់គ្រាន់ដើម្បីកម្ចាត់ព្រូនក្នុងរយៈពេលវែងទេ។ ត្រូវអនុវត្តតាមគោលការណ៍ណែនាំអំពីអនាម័យផ្ទាល់ខ្លួន និងតាមទីសាធារណៈថែមទៀត។ នៅពេលដែលមានមនុស្សម្នាក់ក្នុងគ្រួសារមួយកើតព្រូន គួរព្យាបាលក្រុមគ្រួសារទាំងមូលតែម្តង។

Mebendazole *(Vermox)* សម្រាប់ព្រូនច្រើនប្រភេទ

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ១០០ម.ក្រ។

ថ្នាំនេះសម្រាប់កំចាត់ព្រូនទំពក់ ព្រូនមូលធំៗ ព្រូនមូល និងព្រូនផ្សេងទៀតដែលហៅថា Strongyloides។ មានប្រសិទ្ធភាពចំពោះមេរោគច្រើនប្រភេទ។ វាអាចកបផងដែរ ក្នុងករណីមានtrichinosis។ នៅពេលព្យាបាលការបង្ករោគធ្ងន់ធ្ងរដោយសារព្រូនវានឹងអាចធ្វើឲ្យមានការឈឺពោះវៀន ឬរាក ប៉ុន្តែផលរំខានមិនសូវជាមានទេ។

***ប្រយ័ត្ន :*** មិនត្រូវឲ្យថ្នាំMebendazoleទៅស្ត្រីមានផ្ទៃពោះ ឬកុមារអាយុក្រោម២ឆ្នាំទេ។

***កម្រិតប្រើ*** Mebendazole : ប្រើថ្នាំគ្រាប់ ១០០ម.ក្រ។

ប្រើបរិមាណស្មើគ្នាសម្រាប់កុមារ និងមនុស្សធំ។

ចំពោះព្រូនមូល : ១សប្តាហ៍១គ្រាប់ រយៈពេល៣សប្តាហ៍។

ចំពោះព្រូនមូល (Ascaris), ព្រូនមូលធំៗ (Trichuris) ព្រូនទំពក់ និង Strongyloides : ១គ្រាប់ ២ដងក្នុង១ថ្ងៃ (ព្រឹកនិងយប់) រយៈពេល៣ថ្ងៃ (សរុប៦គ្រាប់)។

Albendazole (Zentel) សម្រាប់ព្រូនច្រើនប្រភេទ

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ២០០ និង៤០០ម.ក្រ។

ថ្នាំនេះប្រហាក់ប្រហែលនឹងMebendazoleដែរ ប៉ុន្តែច្រើនតែថ្លៃជាង។ វាកបនឹងព្រូនទំពក់ ព្រូនមូលធំៗ Strongyloides និងព្រូនមូល។ កម្រមានផលរំខានណាស់។

***ប្រយ័ត្ន :*** មិនត្រូវឲ្យAlbendazoleទៅស្ត្រីមានផ្ទៃពោះ ឬកុមារអាយុក្រោម២ឆ្នាំនោះទេ។

***កម្រិតប្រើ*** Albendazole ប្រើថ្នាំគ្រាប់ ២០០ម.ក្រ

ឲ្យថ្នាំក្នុងកម្រិតស្មើគ្នាទាំងចំពោះកុមារ និងមនុស្សធំ។

ចំពោះព្រូនទំពក់ ព្រូនមូល, ព្រូនមូលធំៗ, និងព្រូនទំពក់ : ២គ្រាប់ (៤០០ម.ក្រ) ១ដង។

ចំពោះ Strongyloides : ២គ្រាប់ (៤០០ម.ក្រ) ២ដង ក្នុង១ថ្ងៃ រយៈពេល៣ថ្ងៃ ហើយលេបម្តងទៀតនៅសប្តាហ៍បន្ទាប់។

<u>Piperazine</u> សម្រាប់ព្រូនមូល (Ascaris) និង (threadworm, Enterobius)

ឈ្មោះ______________តម្លៃ________សម្រាប់______

មានដូចជា piperazine citrate, tartrate, hydrate, adipate, ឬ phosphate :

ច្រើនមានជាថ្នាំគ្រាប់ ៥០០ម.ក្រ តម្លៃ____សម្រាប់___
ថ្នាំទឹក ៥០០ម.ក្រ ក្នុង ៥ម.ល តម្លៃ____សម្រាប់___

ត្រូវប្រើកម្រិតធំមួយ រយៈពេល២ថ្ងៃ ដើម្បីព្យាបាលព្រូនមូល។ អាចប្រើកម្រិតតូចរាល់ថ្ងៃ រយៈពេល១សប្តាហ៍បានដែរ។ ថ្នាំនេះមានផលរំខានបន្តិចបន្តួចទេ។

***កម្រិតប្រើ*** Piperazineសម្រាប់**ព្រូនមូល** (Ascaris) (៧៥ ម.ក្រ/គ.ក្រ/ថ្ងៃ): ថ្នាំគ្រាប់ ៥០០ម.ក្រ ឬថ្នាំទឹក ៥០០ម.ក្រ ក្នុង៥ម.ល

ឲ្យ១ថ្ងៃ១កម្រិត រយៈពេល២ថ្ងៃ

- មនុស្សធំ : ៣៥០០ម.ក្រ (៧គ្រាប់ ឬ៧ស្លាបព្រាកាហ្វេ)
- កុមារអាយុ៨-១២ឆ្នាំ : ២៥០០ម.ក្រ (៥គ្រាប់ ឬ៥ស្លាបព្រាកាហ្វេ)
- កុមារអាយុ៣-៧ឆ្នាំ : ១៥០០ម.ក្រ (៣គ្រាប់ ឬ៣ ស្លាបព្រាកាហ្វេ)
- កុមារអាយុ១-៣ឆ្នាំ : ១០០០ម.ក្រ (២គ្រាប់ ឬ២ ស្លាបព្រាកាហ្វេ)
- កុមារអាយុក្រោម១ឆ្នាំ : ៥០០ម.ក្រ (១គ្រាប់ ឬ១ស្លាបព្រាកាហ្វេ)

***កម្រិតប្រើ*** Piperazineសម្រាប់**ព្រូនមូល** (Enterobius) (៤០ ម.ក្រ/គ.ក្រ/ថ្ងៃ):

ឲ្យ១ថ្ងៃ២កម្រិត រយៈពេល១សប្តាហ៍

- មនុស្សធំ : ១០០០ម.ក្រ (២គ្រាប់ ឬ២ស្លាបព ព្រាកាហ្វេ)
- កុមារអាយុ៨-១២ឆ្នាំ : ៧៥០ម.ក្រ (១ ១/២គ្រាប់ ឬ១ ១/២ ស្លាបព្រាកាហ្វេ)
- កុមារអាយុ៣-៧ឆ្នាំ : ៥០០ម.ក្រ (១គ្រាប់ ឬ១ ស្លាបព្រាកាហ្វេ)
- កុមារអាយុក្រោម៣ឆ្នាំ : ២៥០ម.ក្រ (១/២គ្រាប់ ឬ១/២ស្លាបព្រាកាហ្វេ)

<u>Thiabendazole</u> សម្រាប់ព្រូនច្រើនប្រភេទ

ឈ្មោះ______________តម្លៃ________សម្រាប់______

ជាមានជាថ្នាំគ្រាប់ ៥០០ម.ក្រ ឬថ្នាំទឹក១ក្រ. ក្នុង៥ម.ល

ដោយសារតែThiabendazoleធ្វើឲ្យមានផលរំខានច្រើនជាងMebendazole ឬ Albendazole វាគួរតែត្រូវប្រើសម្រាប់ព្រូននៅពេលដែលមិនអាចរកថ្នាំទាំងនេះបាន ឬប្រើចំពោះតែព្រូនដែលនៅក្រៅពោះវៀន។

វាអាចប្រើសម្រាប់កំចាត់ព្រូនទំពក់ ព្រូនមូលធំៗ (Trichuris) និង Strongyloides ។ វាក៏អាចកំចាត់ព្រូនមូលបានដែរ ប៉ុន្តែPiperazineមានផលរំខានតិចជាង។ វាអាចមានប្រយោជន៍ក្នុងការព្យាបាល guinea worm ហើយក៏អាចមានប្រសិទ្ធភាពផងដែរ ក្នុងករណីមាន trichinosis ។

***ប្រយ័ត្ន :*** Thiabendazoleអាចធ្វើឲ្យព្រូនមូល (Ascaris) វារឡើងមកបំពង់ក។ ពេលនោះវាអាចធ្វើឲ្យស្ទះដង្ហើម។ ដូច្នេះប្រសិនបើអ្នកសង្ស័យថាអ្នកណាម្នាក់មានព្រូនមូល និងព្រូនផ្សេងទៀត ជាការប្រសើរអ្នកគួរតែព្យាបាលនឹងPiperazineសិន មុននឹងឲ្យThiabendazole។

***ផលរំខាន :*** Thiabendazoleភាគច្រើនបណ្តាលឲ្យអស់កំលាំង ឈឺ និងជួលកាលក្អួតផង។

***កម្រិតប្រើ*** Thiabendazole (២៥ម.ក្រ/គ.ក្រ/ថ្ងៃ) : ថ្នាំគ្រាប់ ៥០០ម.ក្រ ឬថ្នាំទឹក១ក្រ. ក្នុង៥ម.ល

ឲ្យ១ថ្ងៃ២ដង រយៈពេល៣ថ្ងៃ។ ត្រូវទំពារថ្នាំឲ្យម៉ត់។

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ១៥០០ម.ក្រ (៣គ្រាប់ ឬ ១ ១/២ ស្លាបព្រាកាហ្វេ)
- កុមារអាយុ៨-១២ឆ្នាំ : ១០០ម.ក្រ (២គ្រាប់ ឬ១ស្លាបព្រាកាហ្វេ)
- កុមារអាយុ៣-៧ឆ្នាំ : ៥០០ម.ក្រ (១គ្រាប់ ឬ១/២ ស្លាបព្រាកាហ្វេ)
- កុមារអាយុក្រោម៣ឆ្នាំ : ២៥០ម.ក្រ (១/២គ្រាប់ ឬ១/៤ ស្លាបព្រាកាហ្វេ)

<u>Pyrantel *(Antiminth, Cobrantril, Helmex)*</u>

ឈ្មោះ______________តម្លៃ________សម្រាប់______

មានមកជា pamoate ឬ embonate

ច្រើនជា
ថ្នាំគ្រាប់ ២៥០ម.ក្រ តម្លៃ_____សម្រាប់____
ថ្នាំទឹក ២៥០ម.ក្រ ក្នុង ៥ម.ល តម្លៃ_____សម្រាប់____

ថ្នាំនេះមានប្រសិទ្ធិភាពចំពោះព្រូនទំពក់ ព្រូនមូល ប៉ុន្តែវាមានតម្លៃថ្លៃ។ ក្នុងករណីកម្រ Pyrantelបណ្តាលឲ្យក្អួត វិលមុខ ឬ ឈឺក្បាល។

***កម្រិតប្រើ*** Pyrantel (១០ម.ក្រ/គ.ក្រ): ប្រើថ្នាំគ្រាប់ ២៥០ម.ក្រ

ឲ្យ១ដង ចំពោះព្រូនទំពក់ និងព្រូនមូល។ ចំពោះព្រូនទំពក់ត្រូវឲ្យម្តងទៀត នៅ២សប្តាហ៍ក្រោយ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ៧៥០ម.ក្រ (៣គ្រាប់)
កុមារអាយុ១០-១៤ឆ្នាំ : ៥០០ម.ក្រ (២គ្រាប់)
កុមារអាយុ៦-៩ឆ្នាំ : ២៥០ម.ក្រ (១គ្រាប់)
កុមារអាយុ២-៥ឆ្នាំ : ១២៥ម.ក្រ (១/២គ្រាប់)
កុមារអាយុក្រោម២ឆ្នាំ : ៦២ម.ក្រ (១/៤គ្រាប់)

## សម្រាប់តេនញ៉ា

តេនញ៉ាមានច្រើនប្រភេទ។ Niclosamide មានប្រសិទ្ធិភាពជាងគេក្នុងការកំចាត់តេនញ៉ាច្រើនប្រភេទ បន្ទាប់មកគឺ Praziquantel។

<u>Niclosamide *(Yomesan)*</u> សម្រាប់តេនញ៉ា

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ទំពារ ៥០០ម.ក្រ

Niclosamideទំនងជាថ្នាំល្អបំផុតសម្រាប់កំចាត់តេនញ៉ា។ វាកបនឹងតេនញ៉ាស្ទើរគ្រប់ប្រភេទនៅក្នុងពោះវៀន ប៉ុន្តែមិនកបនឹងគីសដែលនៅក្រៅពោះវៀនទេ។

***កម្រិតប្រើ*** Niclosamideសម្រាប់តេនញ៉ា ថ្នាំគ្រាប់៥០០ម.ក្រ :

ទំពារឲ្យម៉ត់ល្អ ហើយលេប១កម្រិតប៉ុណ្ណោះ។ មិនត្រូវពិសារអ្វីទេ នៅ២ម៉ោង មុនពេល និងក្រោយពេលលេបថ្នាំ។ ការឲ្យថ្នាំបញ្ចុះ អាចជួយក្នុងការកំចាត់តេនញ៉ាបាន។

មនុស្សធំ និងកុមារអាយុលើស៨ឆ្នាំ : ២ក្រ. (៤គ្រាប់)
កុមារអាយុ២-៨ឆ្នាំ : ១ក្រ. (២គ្រាប់)
កុមារអាយុក្រោម២ឆ្នាំ : ៥០០ម.ក្រ (១គ្រាប់)

<u>Praziquantel *(Biltricide, Droncit)*</u>

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនជាថ្នាំគ្រាប់ ១៥០ម.ក្រ និង ៦០០ម.ក្រ

Praziquantel មានឥទ្ធិពលពលក្នុងការកំចាត់តេនញ៉ាស្ទើរគ្រប់ប្រភេទ ប៉ុន្តែវាមានតម្លៃថ្លៃជាងNiclosamide។

***ប្រយ័ត្ន :*** ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម៤ឆ្នាំ មិនគួរប្រើ Praziquantelទេ។ ស្ត្រីកំពុងបំបៅដោះកូន ត្រូវឈប់បំបៅពេលប្រើថ្នាំនេះ និងឈប់បំបៅរយៈពេល៧២ម៉ោងក្រោយពេលប្រើថ្នាំ(ប្របាច់យកទឹកដោះចេញ ហើយចោលវា)។

***ផលរំខាន :*** Praziquantelអាចធ្វើឲ្យអស់កំលាំង វិលមុខ ឈឺក្បាល មិនឃ្លានបាយ ប៉ុន្តែផលរំខានទាំងនេះមិនសូវជាមានទេ បើប្រើត្រឹមកម្រិតទាបត្រឹមកំចាត់តេនញ៉ានោះ។

***កម្រិតប្រើ*** Praziquantel សម្រាប់តេនញ៉ាស្ទើរគ្រប់ប្រភេទ រួមទាំងតេនញ៉ាពីសាច់គោ និងសាច់ជ្រូក (១០-២០ម.ក្រ/គ.ក្រ): ប្រើថ្នាំគ្រាប់ ៦០០ម.ក្រ

ប្រើតែ១ដងគត់។

មនុស្សធំ : ៦០០ម.ក្រ (១គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ៣០០ក្រ. (១/២គ្រាប់)
កុមារអាយុ៤-៧ឆ្នាំ : ១៥០ក្រ. (១/៤គ្រាប់)

ចំពោះការព្យាបាលតេនញ៉ា dwarf (*H. nana*) ទាមទារឲ្យប្រើប្រើថ្នាំក្នុងកម្រិតខ្ពស់ជាងនេះ :

ប្រើតែ១ដងគត់។

មនុស្សធំ : ១៥០០ម.ក្រ (២ ១/២គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ៦០០-១២០០ម.ក្រ (១-២គ្រាប់)
កុមារអាយុ៤-៧ឆ្នាំ : ៣០០-៦០០ម.ក្រ (១/២-១គ្រាប់)

<u>Quinacrine (mepacrine, *Atabrine*)</u> សម្រាប់តេនញ៉ា
មើលទំ.៣៧០

# សម្រាប់ស៊ីស្តូសូម៉្វា
# (មេរោគក្នុងឈាម, ប៊ីឡាហ្សា)

ក្នុងតំបន់ផ្សេងៗពីគ្នាក្នុងពិភពលោក មានស៊ីស្តូសូម៉្វាច្រើនប្រភេទ ដែលទាមទារការព្យាបាលខុសៗគ្នាដែរ។ Praziquantel ជាថ្នាំដែលប្រឆាំងនឹងជំងឺគ្រប់ប្រភេទ។ Metrifonate និងOxamniquine មានប្រសិទ្ធិភាពចំពោះជំងឺដែលបង្កមេរោគ ស៊ីស្តូសូម៉្វាមួយចំនួន។ ថ្នាំទាំងនេះគួរប្រើក្រោមការណែនាំពីបុគ្គលិកសុខាភិបាលជំនាញ។

<u>Praziquantel *(Biltricide, Droncit)*</u>

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ១៥០ម.ក្រ ឬ៦០០ម.ក្រ

***ប្រយ័ត្ន :*** ស្ត្រីមានផ្ទៃពោះមិនគួរប្រើថ្នាំនេះទេ។ ស្ត្រីកំពុងបំបៅដោះកូន គួរឈប់បំបៅកូន ពេលដែលប្រើថ្នាំនេះ និង៧២ម៉ោងក្រោយពេលប្រើថ្នាំ(ច្របាច់ទឹកដោះចោល)។ ហាមប្រើថ្នាំPraziquantel ចំពោះកុមារអាយុក្រោម៤ឆ្នាំ។

***ផលរំខាន :*** ជាញឹកញាប់ Praziquantelធ្វើឲ្យអស់កំលាំង ឈឺក្បាល វិលមុខ មិនឃ្លានបាយ ប៉ុន្តែមិនគួរបញ្ឈប់ការព្យាបាលទេ ប្រសិនបើមានផលរំខានទាំងនេះ។ ដើម្បីកាត់បន្ថយផលរំខាន ប្រសើរបំផុតគឺប្រើPraziquantelក្នុងពេលបាយ។

***កម្រិតប្រើ*** Praziquantel សម្រាប់ស៊ីស្តូសូម៉្វា (៤០ម.ក្រ/គ.ក្រ) : ប្រើគ្រាប់ ៦០០ម.ក្រ

ដើម្បីព្យាបាលស៊ីស្តូសូម៉្វា ដែលធ្វើឲ្យមានឈាមក្នុងទឹកនោម ចូរឲ្យក្នុង១កំរិត :

- មនុស្សធំ : ២៤០០ ទៅ៣០០០ម.ក្រ (៤ ឬ៥គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ១២០០-១៨០០ម.ក្រ (២ ឬ៣គ្រាប់)
- កុមារអាយុ៤-៧ឆ្នាំ : ៦០០ម.ក្រ (១គ្រាប់)

កម្រិតប្រើខាងលើនេះ ក៏អាចប្រើក្នុងការព្យាបាលស៊ីស្តូសូម៉្វាមួយប្រភេទដែលរកឃើញក្នុងអាហ្វ្រិកភាគកណ្តាលនិងខាងកើត និងអាមេរិកខាងត្បូង ដែលវាបណ្តាលឲ្យមានឈាមក្នុងលាមក(ស៊ីស្តូសូម៉្វា ម៉ាន់សូនី)។ ប៉ុន្តែនៅអាស៊ីភាគខាងកើតវិញ ស៊ីស្តូសូម៉្វាដែលធ្វើឲ្យមានឈាមក្នុងលាមក (ស៊ីស្តូសូម៉្វា ហ្សាប៉ូនីកូម) ទាមទារការប្រើថ្នាំក្នុងកម្រិតធំមួយ(៦០ម.ក្រ/គ.ក្រ) :

ឲ្យក្នុង១ថ្ងៃ :

- មនុស្សធំ : ៣៦០០ ទៅ៤២០០ម.ក្រ (៦ ឬ៧គ្រាប់)
- កុមារអាយុ៨-១២ឆ្នាំ : ១៨០០ ទៅ២៤០០ម.ក្រ (៣ ឬ៤គ្រាប់)
- កុមារអាយុ៤-៧ឆ្នាំ : ៩០០ម.ក្រ (១ ១/២គ្រាប់)

(ដើម្បីកាត់បន្ថយផលរំខាន កម្រិតថ្នាំដ៏ច្រើននេះ អាចចែកជា៣ពេលបាន ហើយប្រើក្នុង១ថ្ងៃដដែល)។

<u>Metrifonate (Metrifonate, *Bilarcil*)</u>

Metrifonateជាថ្នាំដែលមានតម្លៃថោកមួយ ដែលអាចប្រើសម្រាប់ព្យាបាលស៊ីស្តូសូម៉្វា ដែលធ្វើឲ្យមានឈាមក្នុងទឹកនោម (ស៊ីស្តូសូម៉្វា អេម៉ាតូប្យូម)។ ស្ត្រីមានផ្ទៃពោះ មិនគួរប្រើថ្នាំនេះទេ។

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ១០០មក្រ

***កម្រិតប្រើ*** Metrifonateសម្រាប់ព្យាបាលស៊ីស្តូសូម៉្វា (៧,៥ទៅ១០ម.ក្រ/គ.ក្រ សម្រាប់កម្រិតនីមួយៗ): គ្រាប់ ១០០ម.ក្រ

ឲ្យ ៣កម្រិត ក្នុងចន្លោះពេល ២សប្តាហ៍។

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ៤០០ ទៅ៦០០ម.ក្រ (៤ ទៅ៦គ្រាប់)
- កុមារអាយុ៦-១២ឆ្នាំ : ៣០០ម.ក្រ (៣គ្រាប់)
- កុមារអាយុ៣-៥ឆ្នាំ : ១០០ម.ក្រ (១គ្រាប់)

<u>Oxamniquine *(Vansil, Mansil)*</u>

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ២៥០ម.ក្រ តម្លៃ_____សម្រាប់___
សេរ៉ូ ២៥០ម.ក្រ ក្នុង៥ម.ល តម្លៃ_____សម្រាប់___

នៅអាមេរិកភាគកណ្តាលនិងខាងត្បូង គេប្រើ Oxamniquineសម្រាប់ព្យាបាលស៊ីស្តូសូម៉្វា ដែលបណ្តាលឲ្យមានឈាមក្នុងលាមក(ស៊ីស្តូសូម៉្វា ម៉ាន់សូនី)។ (ដើម្បីព្យាបាលស៊ីស្តូសូម៉្វា ម៉ាន់សូនី ដែលរកឃើញនៅអាហ្វ្រិកវិញ គេត្រូវការប្រើកម្រិតថ្នាំច្រើនជាងនេះ។ សូមរកការណែនាំក្នុងការប្រើ)។ ថ្នាំនេះគួរតែប្រើក្រោយពេលបាយទើបប្រសើរ។

***ប្រយ័ត្ន :*** ស្ត្រីមានផ្ទៃពោះមិនគួរប្រើថ្នាំនេះទេ។ ថ្នាំនេះអាចបណ្តាលឲ្យមានការវិលមុខ ងងុយដេក និងប្រកាច់(ករណីកម្រ)។ អ្នកដែលមានជំងឺឆ្កួតជ្រូក គួរប្រើថ្នាំនេះតែនៅពេលប្រើថ្នាំឆ្កួតជ្រូកដែរប៉ុណ្ណោះ។

***កម្រិតប្រើ*** Oxamniquine (មនុស្សធំ : ១៥ម.ក្រ/គ.ក្រ/ថ្ងៃ កុមារ : ១០ម.ក្រ/គ.ក្រ/២ដងក្នុង១ថ្ងៃ): គ្រាប់ ២៥០ម.ក្រ

ឲ្យតែ១ថ្ងៃប៉ុណ្ណោះ :

មនុស្សធំ : ឲ្យ ៧៥០-១០០០ម.ក្រ (៣ឬ៤គ្រាប់) ក្នុង១កម្រិត

ចំពោះកុមារ ឲ្យកម្រិតខាងក្រោមនេះ២ដងក្នុង១ថ្ងៃ :

- កុមារអាយុ៨-១២ឆ្នាំ : ២៥០ម.ក្រ (១គ្រាប់)
- កុមារអាយុ៤-៧ឆ្នាំ : ១២៥ម.ក្រ (១/២គ្រាប់)
- កុមារអាយុ១-៣ឆ្នាំ : ៦៣ម.ក្រ (១/៤គ្រាប់)



**ព័ត៌មានអំពីថ្នាំព្យាបាលជំងឺ river blindness ត្រូវបានដកចេញនៅក្នុងការបោះពុម្ពថ្មីនេះ។**

## សម្រាប់ភ្នែក

**<u>ក្រមួនភ្នែកអង់ទីប៊ីយ៉ូទិក</u>** សម្រាប់ជំងឺភ្នែកក្រហម
( ការរលាកផ្ទៃកសនៃភ្នែក )

ដូចជាក្រមួនភ្នែកOxytetracycline ឬChlortetracycline ។

ឈ្មោះ_______________តម្លៃ_______សម្រាប់_______

ថ្នាំក្រមួនភ្នែកទាំងនេះអាចប្រើសម្រាប់ព្យាបាលជំងឺភ្នែកក្រហមបណ្តាលមកពីបាក់តេរី និងសម្រាប់ព្យាបាលជំងឺត្រាកូម។ ដើម្បីព្យាបាលត្រាកូមឲ្យបានទាំងស្រុង គួរលេបថ្នាំ Tetracycline (ទំ.៣៥៦) ឬ Erythromycin (ទំ.៣៥៥) ថែមទៀត។

ដើម្បីឲ្យក្រមួនភ្នែកមានប្រសិទ្ធភាព ត្រូវដាក់ថ្នាំនៅ**ខាងក្នុង**ត្របកភ្នែក មិនមែនខាងក្រៅទេ។ ដាក់ភ្នែក៣ទៅ៤ដងក្នុង១ថ្ងៃ។

ប្រើថ្នាំក្រមួនភ្នែក**Tetracycline១%** ឬ **Erythromycin 0,៥%** ទៅ**១%** ដើម្បីការពារភ្នែករបស់ទារកពីជំងឺប្រមេះទឹកបាយ និងប្រមេះទឹកថ្លា។ (មើលទំ.២២១ ពីព័ត៌មាននៃការព្យាបាលជំងឺទាំងនេះចំពោះទារកទើបកើត)។ ប្រសិនបើគ្មានក្រមួនភ្នែកអង់ទីប៊ីយ៉ូទិកទេ អ្នកអាចបន្តក់**សូលុយស្យុង Povidone-iodine ២៥%** ចំនួន១ដំណក់ ឬ**សូលុយស្យុង Silver nitrate ១%** ចំនួន១ដំណក់ ចូលទៅក្នុងភ្នែកទាំងសងខាង។ ទឹកថ្នាំដាក់ភ្នែកSilver nitrate (ឬថ្នាំភ្នែក"ទឹកប្រាក់" ផ្សេងទៀត) បង្ការជំងឺភ្នែកដែលបង្កដោយជំងឺប្រមេះទឹកបាយ ប៉ុន្តែមិនអាចបង្ការជំងឺភ្នែកដែលបណ្តាលមកពីប្រមេះទឹកថ្លាបានទេ។

***ប្រយ័ត្ន :*** មិនត្រូវប្រើទឹកថ្នាំដាក់ភ្នែកSilver nitrate ដែលខាប់ (ដោយវាបានហួត) ទេ ព្រោះវាអាចធ្វើឲ្យរលាកភ្នែកទារក។

## សម្រាប់ការឈឺចាប់ : ថ្នាំបំបាត់ការឈឺចាប់

**ចំណាំ :** ថ្នាំបំបាត់ការឈឺចាប់មានច្រើនប្រភេទខុសៗគ្នា ដែលថ្នាំជាច្រើនមានគ្រោះថ្នាក់ណាស់ (ជាពិសេសថ្នាំដែលមានជាតិ**Dipyrone**)។ សូមប្រើថ្នាំណាដែលអ្នកប្រាកដថាវាមានសុវត្ថិភាព ដូចជាថ្នាំ**Aspirin Paracetamol (Acetaminophen)** ឬ **Ibuprofen** (ទំ.៣៨០)។ ចំពោះថ្នាំបំបាត់ការឈឺចាប់ដែលខ្លាំងជាងនេះ សូមមើល **Codeine** (ទំ.៣៨៤)។

<u>Aspirin (Acetylsalicylic acid)</u>

ច្រើនមានជា :

ថ្នាំគ្រាប់ ៣០០ម.ក្រ តម្លៃ______សម្រាប់___
ថ្នាំគ្រាប់ ៧៥ម.ក្រ សម្រាប់កុមារ តម្លៃ______សម្រាប់___
(ឬAspirinសម្រាប់កុមារ)

Aspirinជាថ្នាំបំបាត់ការឈឺចាប់ ឬថ្នាំស្ពឹកដែលមានតម្លៃថោកមានប្រយោជន៍មួយ។ វាជួយសម្រាលការឈឺចាប់ បន្ថយកំដៅ និងបន្ថយការរលាក។ វាក៏ជួយខ្លះដែរ ក្នុងការកាត់បន្ថយការក្អកនិងរមាស់។

មានថ្នាំជាច្រើនដែលមានជាតិAspirin ត្រូវបានលក់សម្រាប់បំបាត់ការឈឺចាប់ រលាកសន្លាក់ ឬផ្តាសាយ ប៉ុន្តែវាមានតម្លៃថ្លៃ ហើយជាញឹកញាប់មិនមានប្រសិទ្ធិភាពល្អជាងAspirinតែឯងទេ។

***គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន :***

១. មិនត្រូវប្រើAspirinសម្រាប់ការឈឺក្រពះ ឬការពិបាករំលាយអាហារទេ។ Aspirinគឺជាជាតិអាស៊ីដ ហើយអាចធ្វើឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ។ ក្នុងហេតុផលដដែលនេះ **អ្នកដែលមានដំបៅក្រពះ មិនត្រូវប្រើ Aspirinឡើយ។**

២. ចំពោះមនុស្សមួយចំនួន Aspirinធ្វើឲ្យឈឺក្រពះ ឬក្រហាយចុងដង្ហើម ។ ដើម្បីចៀសវាងបញ្ហានេះ ត្រូវលេបAspirinជាមួយទឹកដោះគោ សូដាប៊ីកាបូណាតបន្តិចបន្តួច ឬជាមួយទឹកដ៏ច្រើន ឬលេបនៅពេលពិសារបាយ។

៣. សូមកុំប្រើAspirinឲ្យលើសពី១កម្រិតឲ្យសោះ ចំពោះអ្នកខ្សោះជាតិទឹកក្នុងខ្លួន រហូតដល់អ្នកនោះចាប់ផ្តើមនោមធម្មតាវិញ។

៤. ជាការប្រសើរ មិនគួរឲ្យAspirinទៅកុមារអាយុក្រោម១២ឆ្នាំទេ ជាពិសេសទារក (Paracetamolមានសុវត្ថិភាពជាង) ឬអ្នកដែលមានជំងឺហឺត (វាអាចនឹងបណ្តាលឲ្យធ្វើទុក្ខ)។

៥. សូមទុកដាក់Aspirinឲ្យឆ្ងាយពីដៃកុមារ។ ថ្នាំច្រើន អាចធ្វើឲ្យកុមារពុលបាន។

៦. មិនត្រូវឲ្យថ្នាំនេះទៅស្ត្រីមានផ្ទៃពោះទេ។

***កម្រិតប្រើ*** Aspirin សម្រាប់បំបាត់ការឈឺចាប់ និងគ្រុនក្តៅ : ថ្នាំគ្រាប់ ៣០០ម.ក្រ

លេប១ដង រាល់៤ទៅ៦ម៉ោងម្តង (ឬ ៤ទៅ៦ដងក្នុង១ថ្ងៃ)

មនុស្សធំ : ១ឬ២គ្រាប់ (៣០០ ទៅ ៦០០ម.ក្រ)

(កម្រិតនេះអាចប្រើទ្វេរដងបាន ចំពោះការឈឺចាប់ពេលមករដូវ ជំងឺរលាកសន្លាក់ធ្ងន់ធ្ងរ ឬគ្រុនរលាកសន្លាក់។ ឬឲ្យ ១០០ម.ក្រ/គ.ក្រ/ថ្ងៃ។ បើមានការហ៊ឹងត្រចៀក ត្រូវបន្ថយកម្រិតប្រើ។)

ថ្នាំគ្រាប់Aspirinសម្រាប់កុមារ ៧៥ម.ក្រ

ឲ្យAspirinទៅកុមារ ៤ដងក្នុង១ថ្ងៃ :

កុមារអាយុ៨-១២ឆ្នាំ : ៤គ្រាប់ (៣០០ម.ក្រ)
កុមារអាយុ៣-៧ឆ្នាំ : ២-៣គ្រាប់(១៥០-២២៥ម.ក្រ)
កុមារអាយុ១-២ឆ្នាំ : ១គ្រាប់(៧៥ម.ក្រ)
មិនត្រូវឲ្យAspirinទៅកុមារអាយុក្រោម១ឆ្នាំទេ។

Paracetamol (Acetaminophen) សម្រាប់ការឈឺចាប់ និងគ្រុនក្តៅ

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ៥០០ម.ក្រ ក៏មានជាសេរ៉ូផងដែរ

សម្រាប់កុមារ Paracetamol(Acetaminophen) មានសុវត្ថិភាពជាងAspirin។ វាមិនធ្វើឲ្យឈឺក្រពះទេ ដូច្នេះវាអាចប្រើជំនួសAspirin សម្រាប់អ្នកដែលមានដំបៅក្រពះ។ វាក៏អាចប្រើសម្រាប់ស្ត្រីដែលមានផ្ទៃពោះបានដែរ។

***កម្រិតប្រើ*** Paracetamol សម្រាប់ការឈឺចាប់ និងគ្រុនក្តៅ : ថ្នាំគ្រាប់ ៥០០ម.ក្រ

ឲ្យParacetamolជាថ្នាំលេប ៤ដងក្នុង១ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ៥០០ម.ក្រទៅ១ក្រ. (១ឬ២គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ៥០០ម.ក្រ (១គ្រាប់)
កុមារអាយុ៣-៧ឆ្នាំ : ២៥០ម.ក្រ (១/២គ្រាប់)
កុមារអាយុ១-២ឆ្នាំ : ១២៥ម.ក្រ(១/៤គ្រាប់)
កុមារអាយុក្រោម១ឆ្នាំ : ៦២ម.ក្រ(១/៨គ្រាប់)

Ibuprofen

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : គ្រាប់ ២០០ម.ក្រ ឬ៤០០ម.ក្រ

Ibuprofenមានប្រសិទ្ធភាពក្នុងការបំបាត់សាច់ដុំប៉ោង និងការឈឺចាប់ ឈឺសន្លាក់បណ្តាលមកពីការរលាកសន្លាក់ ឈឺចាប់ពេលមានរដូវ ឈឺក្បាល និងបន្ថយគ្រុនក្តៅ។ វាមានតម្លៃថ្លៃជាងAspirin។

***ប្រយ័ត្ន :*** Ibuprofenមិនគួរប្រើចំពោះអ្នកដែលប្រតិកម្មនឹងAspirinទេ។ ស្ត្រីមានផ្ទៃពោះក៏មិនគួរប្រើIbuprofenដែរ។

***កម្រិតប្រើ*** Ibuprofen សម្រាប់ការឈឺចាប់ និងគ្រុនក្តៅ : ថ្នាំគ្រាប់ ២០០ម.ក្រ

ឲ្យIbuprofenជាថ្នាំលេប រាល់៤ឬ៦ម៉ោងម្តង។

**ត្រូវលេបIbuprofenជាមួយបាយ ឬទឹកមួយកែវធំ។**

ក្នុងកម្រិតនីមួយៗ ឲ្យ :
មនុស្សធំនិងកុមារអាយុចាប់ពី១២ឆ្នាំ : ២០០ម.ក្រ (១គ្រាប់)
កុមារអាយុក្រោម១២ឆ្នាំ : មិនត្រូវប្រើទេ

ប្រសិនបើប្រើថ្នាំ១គ្រាប់មិនអាចបន្ថយការឈឺចាប់ឬគ្រុនក្តៅទេ គួរប្រើ២គ្រាប់។ មិនត្រូវលេបថ្នាំលើសពី៦គ្រាប់ ក្នុង ២៤ម៉ោងទេ។

**Ergotamine ជាមួយ** caffeine *(Cafergot)* សម្រាប់ការឈឺក្បាលប្រកាំង

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : គ្រាប់Ergotamine ១ម.ក្រ

***កម្រិតប្រើ*** Ergotamine ជាមួយcaffeine សម្រាប់ការឈឺក្បាលប្រកាំង :

មនុស្សធំ : លេប២គ្រាប់នៅពេលមានរោគសញ្ញាដំបូង បន្ទាប់មកលេប១គ្រាប់នៅរាល់កន្លះម៉ោងម្តង រហូតបាត់ឈឺ។ ប៉ុន្តែមិនត្រូវប្រើលើសពី៦គ្រាប់ទេ។

***ប្រយ័ត្ន :*** មិនត្រូវប្រើថ្នាំនេះញឹកញាប់ពេកទេ។ ហាមប្រើចំពោះស្ត្រីមានផ្ទៃពោះ។

Codeine សម្រាប់ការឈឺចាប់ធ្ងន់ធ្ងរ មើលទំ.៣៨៤។

## ចំពោះបំបាត់ការឈឺចាប់ នៅពេលដេរមុខរបួស : ថ្នាំស្ពឹក

Lidocaine *(xylocaine)* ២% (លាយឬមិនលាយ Epinephrine)

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : អំពូល ឬដបសម្រាប់ចាក់។

Lidocaineអាចត្រូវបានចាក់នៅជុំវិញមុខរបួសមុននឹងដេរវា ដើម្បីឲ្យស្ពឹកនៅកន្លែងនោះ ដូច្នេះវានឹងមិនធ្វើឲ្យឈឺចាប់។

ចាក់ក្នុងនិងចាក់ក្រោមស្បែកច្រើនកន្លែងដែលឃ្លាតឆ្ងាយពីគ្នាប្រហែល១ស.ម។ ត្រូវប្រាកដថាបានទាញស្នប់សឺរ៉ាំងមើលសិន មុននឹងចាក់ថ្នាំបញ្ចូល(មើលទំ.៧៣)។ ចាក់យឺតៗ។ ចូរប្រើថ្នាំស្ពឹក១ម.លសម្រាប់ផ្ទៃស្បែក២ស.ម។ (មិនត្រូវប្រើសរុបទាំងអស់លើសពី២០ម.លទេ)។ បើមុខរបួសនោះស្អាត អ្នកអាចចាក់លើមុខរបួសតែម្តង។ បើមុខរបួសមិនស្អាត ត្រូវចាក់តាមស្បែក(បន្ទាប់ពីសម្អាត)ជុំវិញរបួស បន្ទាប់មក**លាងរបួសដោយប្រុងប្រយ័ត្ន**មុននឹងដេរភ្ជិត។

**សូមប្រើLidocaineមានEpinephrine សម្រាប់ដេររបួសភាគច្រើន។** Epinephrineធ្វើឲ្យស្ពឹកបានយូរ ហើយជួយឃាត់ឈាមផង។

**សូមប្រើLidocaineដែលគ្មានលាយEpinephrine សម្រាប់មុខរបួសនៅម្រាមដៃ ម្រាមជើង លិង្គ ត្រចៀក និងច្រមុះ។** នេះជាការសំខាន់ណាស់ ព្រោះEpinephrineអាចបញ្ឈប់ដំណើរឈាមរត់នៅកន្លែងនោះ ហើយបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។

ការប្រើLidocaineមានលាយEpinephrineក្នុងគោលបំណងផ្សេងទៀត : **សម្រាប់ការឈាមច្រមុះធ្ងន់ធ្ងរ** ចូរយកសំឡីជ្រលក់នឹងថ្នាំស្ពឹកនេះ ហើយញាត់ក្នុងរន្ធច្រមុះ។ Epinephrineនឹងធ្វើឲ្យសរសៃវ៉ែនរួម និងជួយឃាត់មិនឲ្យឈាមហូរបាន។

## សម្រាប់ការឈឺចាប់ក្នុងពោះវៀន

### Antispasmodics

<u>Belladonna (មានឬគ្មាន Phenobarbital)</u>

ឈ្មោះ______________ តម្លៃ________ សម្រាប់______

ច្រើនមានជា : គ្រាប់ ៨ម.ក្រ Belladonna

ថ្នាំAntispasmodics មានច្រើនប្រភេទ។ ភាគច្រើនមានជាតិBelladonna ឬជាតិដែលដូចនឹងBelladonna (atropine, hyoscyamine) និងជាញឹកញាប់មានជាតិPhenobarbital។ ថ្នាំទាំងនេះមិនគួរយកប្រើជាទូទៅទេ ប៉ុន្តែគួរប្រើម្តងម្កាលសម្រាប់ព្យាបាលការឈឺចុកចាប់ក្នុងពោះវៀនឬក្រពះ។ វាអាចជួយសម្រាលការឈឺចាប់នៃជំងឺរលាកប្លោកនោម ឬរលាកថង់ប្រមាត់។ ជួនកាលគេប្រើវាដើម្បីព្យាបាលជំងឺដំបៅក្រពះ។

***កម្រិតប្រើ*** Belladonna សម្រាប់ការចុកចាប់ក្នុងពោះវៀន : ថ្នាំគ្រាប់Belladonna ៨ម.ក្រ

មនុស្សធំ : ១គ្រាប់ ៣-៦ដងក្នុង១ថ្ងៃ
កុមារអាយុ៨-១២ឆ្នាំ : ១គ្រាប់ ២ឬ៣ដងក្នុង១ថ្ងៃ
កុមារអាយុ៥-៧ឆ្នាំ : ១/២គ្រាប់ ២ឬ៣ដងក្នុង១ថ្ងៃ
មិនត្រូវឲ្យថ្នាំនេះទៅកុមារអាយុក្រោម៥ឆ្នាំទេ។

***ប្រយ័ត្ន :*** ថ្នាំនេះនឹងទៅជាពុល កាលណាប្រើច្រើនពេក។ សូមទុកដាក់ឲ្យឆ្ងាយពីដៃកុមារ។

អ្នកដែលមានកើតជំងឺគ្លូកូម មិនគួរប្រើថ្នាំដែលមានជាតិ Belladonna ឬatropineទេ។

## សម្រាប់ការមិនរំលាយអាហារ ក្រហាយចុងដង្ហើម និងដំបៅក្រពះ

<u>*Aluminum hydroxide ឬ Magnesium hydroxide (ទឹកដោះMagnesia)*</u>

ឈ្មោះ______________ តម្លៃ________ សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ៥០០ ទៅ ៧៥០ម.ក្រ ឬជាថ្នាំទឹក ៣០០ ទៅ ៥០០ម.ក្រ ក្នុង៥ម.ល។

ជួនកាលថ្នាំទាំងនេះត្រូវបានលាយជាមួយMagnesium trisilicate។ ប្រសិនបើបានបន្ថែមSimethicone វានឹងជួយបញ្ឈប់ឆ្អល់ពោះ។

ថ្នាំប្រឆាំងជាតិអាស៊ីតក្នុងក្រពះទាំងនេះត្រូវបានប្រើម្តងម្កាលសម្រាប់ការមិនរំលាយអាហារ ឬក្រហាយចុងដង្ហើម ឬប្រើជាផ្នែកមួយក្នុងការព្យាបាលដំបៅក្រពះ។ ពេលវេលាដែលល្អបំផុតក្នុងការលេបថ្នាំប្រឆាំងជាតិអាស៊ីតក្នុងក្រពះគឺ១ម៉ោងក្រោយពេលហូបបាយ និងពេលដេក។ ទំពារ ២ឬ៣គ្រាប់។ ចំពោះដំបៅក្រពះធ្ងន់ធ្ងរ អាចត្រូវប្រើ៣ទៅ៦គ្រាប់ (ឬស្លាបព្រាកាហ្វេ) រៀងរាល់ម៉ោង។

***ប្រយ័ត្ន :*** មិនត្រូវលេបថ្នាំនេះទេ ប្រសិនបើអ្នកកំពុងប្រើថ្នាំ Tetracyclineដែរ។ ជួនកាលថ្នាំប្រឆាំងជាតិអាស៊ីតក្នុងក្រពះដែលមានជាតិMagnesium អាចធ្វើឲ្យរាក ហើយថ្នាំមានជាតិ Aluminum អាចធ្វើឲ្យទល់លាមក។

<u>Sodium bicarbonate (ប៊ីកាបូណាតសូដា, សូដា)</u>

មានជាម្សៅពណ៌ស តម្លៃ_____ សម្រាប់_______

**ដោយសារវាជាថ្នាំបន្សាបជាតិអាស៊ីដ** គួរប្រើវាឲ្យមានកំណត់ នៅពេលម្តងម្កាលមានការធ្វើទុក្ខក្រពះ ក្រហាយចុងដង្ហើម ឬការមិនរំលាយអាហារ។ **មិនគួរប្រើវាសម្រាប់ព្យាបាលជំងឺមិនរំលាយអាហារ ឬជំងឺរលាកក្រពះ ដែលរ៉ាំរ៉ៃទេ។** ទោះជាថ្នាំនេះហាក់ដូចជាជួយសម្រាលការចុកចាប់នៅលើកដំបូងក៏ដោយ វាបណ្តាលឲ្យក្រពះបញ្ចេញជាតិអាស៊ីដច្រើនទៀត ដែលនឹងបណ្តាលឲ្យមានបញ្ហាកាន់តែខ្លាំងឡើង។ សូដាក៏មានប្រយោជន៍ដែរក្នុងការសម្រាលការឈឺក្បាលធីងធោង ចំពោះអ្នកដែលផឹកស្រវឹងកាលពីយប់។ ក្នុងបំណងនេះ(ប៉ុន្តែមិនមែនសម្រាប់ការមិនរំលាយអាហារទេ) វាអាចត្រូវបានប្រើជាមួយ Acetaminophen ឬAspirin។ *Alka-Seltzer* ជាបន្សំរវាង Sodium bicarbonate និងAspirin។ បើចង់ប្រើថ្នាំប្រឆាំងជាតិអាស៊ីតក្នុងក្រពះ**ម្តងម្កាល** ចូរលាយSodium bicarbonate កន្លះស្លាបព្រាកាហ្វេ ជាមួយទឹក ហើយពិសារ។ ចូរកុំប្រើវាញឹកញាប់។

**ដើម្បីសម្អាតធ្មេញ** សូដា ឬសូដាលាយអំបិល អាចប្រើជំនួសថ្នាំដុសធ្មេញបាន (មើលទំ.២៣២)។

***ប្រយ័ត្ន : អ្នកដែលមានជំងឺខ្សោយបេះដូង ហើមជើង ឬហើមមុខ មិនគួរប្រើSodium bicarbonate ឬផលិតផលផ្សេងទៀតដែលមានជាតិSodiumខ្ពស់ទេ(ដូចជាអំបិល)។***

Calcium carbonate

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ៣៥០ម.ក្រ ទៅ៨៥០ម.ក្រ

ថ្នាំនេះធ្វើការយឺតជាងsodium bicarbonate។ វាមានប្រសិទ្ធិភាពខ្លាំងសម្រាប់ការមិនរំលាយអាហារ ឬក្រហាយចុងដង្ហើមម្តងម្កាល ប៉ុន្តែមិនគួរប្រើរយៈពេលយូរ ឬសម្រាប់ព្យាបាលដំបៅក្រពះទេ។ ទំពារគ្រាប់៨៥០ម.ក្រ ចំនួន១គ្រាប់ ឬគ្រាប់៣៥០ម.ក្រ ចំនួន២គ្រាប់ នៅពេលមានរោគសញ្ញា។ ទំពារម្តងទៀតនៅ២ម៉ោងក្រោយ បើចាំបាច់។

Ranitidine ( Zantac )

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ១៥០ម.ក្រ ឬ៣០០ម.ក្រ

Ranitidineអាចបន្ថយការឈឺចាប់ និងជួយព្យាបាលដំបៅក្រពះ។ ប៉ុន្តែត្រូវប្រាកដថាបានធ្វើតាមការណែនាំនៅទំ.១២៨ និង១២៩ អំពីការព្យាបាល និងបង្ការដំបៅក្រពះ។

***កម្រិតប្រើ*** Ranitidine សម្រាប់ការព្យាបាលជំងឺដំបៅក្រពះ : គ្រាប់១៥០ម.ក្រ ២ដងក្នុង១ថ្ងៃ ឬគ្រាប់៣០០ម.ក្រ ពេលបាយល្ងាច រយៈពេល៦ទៅ៨សប្តាហ៍។

***កម្រិតប្រើ*** សម្រាប់បង្ការជំងឺដំបៅពោះវៀនមិនឲ្យកើតឡើងវិញ :

គ្រាប់១៥០ម.ក្រ ( ១គ្រាប់ថ្នាំ១៥០ម.ក្រ ) នៅពេលដេក រយៈពេល ៦ទៅ៨សប្តាហ៍។

Famotidine ( Pepcid )

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ 20ម.ក្រ ឬ 40ម.ក្រ

Famotidineមានលក្ខណៈស្រដៀងនឹងranitidineដែរ។ វាអាចជួយបន្ថយការឈឺចាប់ និងជួយព្យាបាលដំបៅក្រពះ។

***កម្រិតប្រើ*** famotidine សម្រាប់ព្យាបាលដំបៅក្រពះ :

លេបគ្រាប់២០ម.ក្រ ២ដងក្នុង១ថ្ងៃ ឬលេបគ្រាប់៤០ម.ក្រ ១ថ្ងៃម្តង ពេលបាយល្ងាច រយៈពេល ៦ទៅ៨សប្តាហ៍។

***កម្រិតប្រើ*** សម្រាប់បង្ការដំបៅពោះវៀនកុំឲ្យកើតឡើងវិញ :

លេបគ្រាប់២០ម.ក្រ ១ថ្ងៃម្តង ពេលបាយល្ងាច រយៈពេល ៦ទៅ៨សប្តាហ៍។

## សម្រាប់ការខ្សោះជាតិទឹក : ទឹកអូរ៉ាលីត

ការពន្យល់អំពីការធ្វើទឹកអូរ៉ាលីត ដោយប្រើគ្រាប់ធញ្ញជាតិ ឬស្ករធម្មតា មាននៅទំ.១៥២។

នៅប្រទេសមួយចំនួន កញ្ចប់ស្ករធម្មតា(គ្លុយកូស)និងអំបិល សម្រាប់ធ្វើទឹកអូរ៉ាលីត មានលក់នៅកន្លែងចែកចាយថ្នាំពេទ្យនានា។ ទោះជាកញ្ចប់ទាំងនេះអាចរកទិញបានក៏ដោយ ក៏យើងអាចលាយវានៅផ្ទះដោយខ្លួនឯង ដោយប្រើគ្រាប់ធញ្ញជាតិ(បានបង្ហាញនៅទំ.១៥២) ក៏អាចព្យាបាលរាគបានល្អដែរ ឬប្រសើរជាងផង។ ទឹកអូរ៉ាលីតដែលធ្វើខ្លួនឯងដោយលាយស្ករនិងអំបិលក៏មានប្រសិទ្ធភាពល្អដែរ។ ជាការប្រសើរគួរលាយវាដោយខ្លួនឯង ហើយទុកលុយនោះទិញអាហារល្អៗបន្ថែមវិញ។ ត្រូវប្រាកដថាបាន**បន្តការបំបៅដោះកូន**ដែលកំពុងមានជំងឺរាក។ ហើយ**ចាប់ផ្តើមឲ្យអាហារភ្លាម ពេលណាវាព្រមញ៉ាំ។** ការឲ្យអាហារនិងទឹកអូរ៉ាលីត ជាមួយគ្នា ប្រឆាំងនឹងការខ្សោះជាតិទឹកបានល្អជាង ហើយជួយការពារកុមារនោះកុំឲ្យខ្សោយ។

***ប្រយ័ត្ន :*** នៅប្រទេសខ្លះ កញ្ចប់អូរ៉ាលីតត្រូវបានលក់ក្នុងរបៀបផ្សេងៗគ្នា ដែលទាមទារឲ្យប្រើបរិមាណទឹកខុសគ្នាដែរ។ **ប្រសិនបើអ្នកប្រើកញ្ចប់អូរ៉ាលីត អ្នកត្រូវដឹងឲ្យច្បាស់ពីបរិមាណទឹកដែលត្រូវលាយជាមួយវា។** ការប្រើទឹកតិចពេកអាចធ្វើឲ្យមានគ្រោះថ្នាក់។

***ប្រយ័ត្ន :*** ប្រសិនបើអ្នកចង់យកកុមារដែលមានជំងឺរាកទៅមន្ទីរពេទ្យ ត្រូវឲ្យវាផឹកទឹកឲ្យបានច្រើន ឬបើអាច ត្រូវធ្វើទឹកអូរ៉ាលីតឲ្យវាផឹកសិន មុននឹងចេញដំណើរ។ ហើយប្រសិនបើអាច ត្រូវយកទឹកអូរ៉ាលីតខ្លះ (បើគ្មាន ត្រូវយកទឹកធម្មតា)តាមខ្លួនអ្នក ក្នុងពេលធ្វើដំណើរទៅមន្ទីរពេទ្យ និងពេលរង់ចាំវេនរបស់អ្នក។ បញ្ចុកទឹកកុមារឲ្យបានញឹកញាប់ តាមដែលវាអាចផឹកបាន។ ប្រសិនបើកុមារក្អួត បញ្ចុកតិចៗ រៀងរាល់នាទី។ ទឹកមួយចំនួន នឹងនៅក្នុងខ្លួនកុមារ ហើយក៏ជួយបន្ថយការក្អួតដែរ។

# សម្រាប់លាមករឹង (ការទល់លាមក) : ថ្នាំបញ្ចុះលាមក

ការពិភាក្សាអំពីការប្រើប្រាស់ត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃថ្នាំបញ្ចុះលាមក និងថ្នាំបន្ទន់ មាននៅទំ.១៥។ កន្លងមក ថ្នាំបញ្ចុះលាមកត្រូវបានប្រើច្រើនពេកហើយ។ វាគួរត្រូវបានប្រើ**ម្តងម្កាល**ដើម្បីបន្ទន់លាមកដែលរឹងហើយឈឺ(ទល់លាមក)។ **ហាមប្រើថ្នាំបញ្ចុះលាមកជាមួយអ្នកជំងឺរាក ឈឺពោះវៀន ឬអ្នកដែលខ្សោះជាតិទឹកក្នុងខ្លួន។** មិនត្រូវប្រើថ្នាំនេះចំពោះកុមារដែលមានអាយុតិចជាង២ឆ្នាំឡើយ។

ជាទូទៅអ្វីដែលបន្ទន់លាមកបានល្អជាងគេ គឺអាហារដែលមានសរសៃច្រើន ដូចជាកន្ទក់ ឬក្តួច។ ការផឹកទឹកឲ្យបានច្រើន (យ៉ាងហោច៨កែវក្នុង១ថ្ងៃ) និងហូបផ្លែឈើឲ្យបានច្រើន ក៏អាចជួយបានដែរ។

<u>**ទឹកដោះ**Magnesia (Magnesium hydroxide)</u>

ជាថ្នាំបញ្ចុះលាមក និងថ្នាំប្រឆាំងជាតិអាស៊ីតក្នុងក្រពះ

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំទឹកដូចទឹកដោះ

ក្រឡុកឲ្យបានល្អ មុននឹងប្រើ។ ផឹកទឹកខ្លះផង រាល់ពេលប្រើថ្នាំនេះ។

***កម្រិតប្រើ*** ទឹកដោះMagnesia :

**ប្រើជាថ្នាំប្រឆាំងជាតិអាស៊ីតក្នុងក្រពះ :**

- មនុស្សធំនិងកុមារអាយុលើស១២ឆ្នាំ : ១-៣ស្លាបព្រាកាហ្វេ ៣ឬ៤ដងក្នុង១ថ្ងៃ
- កុមារអាយុ១-១២ឆ្នាំ : ១/២ ទៅ ១ស្លាបព្រាកាហ្វេ ៣ឬ៤ដងក្នុង១ថ្ងៃ

**ប្រើជាថ្នាំបញ្ចុះលាមកកម្រិតស្រាល** ឲ្យ១កម្រិតប្រើនៅពេលដេក :

- មនុស្សធំនិងកុមារអាយុលើស១២ឆ្នាំ : ២-៤ស្លាបព្រាកាហ្វេ
- កុមារអាយុ៦-១១ឆ្នាំ : ១-២ស្លាបព្រាកាហ្វេ
- កុមារអាយុ២-៥ឆ្នាំ : ១/៣ ទៅ ១ស្លាបព្រាកាហ្វេ
- មិនត្រូវប្រើថ្នាំនេះចំពោះកុមារអាយុក្រោម២ឆ្នាំទេ។

<u>**អំបិល**Magnesium sulfate</u> ជាថ្នាំបញ្ចុះលាមក និងសម្រាប់រមាស់

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជាថ្នាំម្សៅឬជាដុំពណ៌ស

***កម្រិតប្រើ*** អំបិលMagnesium sulfate :

**ជាថ្នាំបញ្ចុះលាមក** លាយអំបិលជាតិMagnesium sulfate តាមបរិមាណខាងក្រោម ជាមួយនឹងទឹក១កែវ (ល្អបំផុតគឺផឹកពេលពោះទទេរ):

- មនុស្សធំ : ២ស្លាបព្រាកាហ្វេ
- កុមារអាយុ៦-១២ឆ្នាំ : ១/២ ទៅ ១ស្លាបព្រាកាហ្វេ
- កុមារអាយុ២-៥ឆ្នាំ : ១/៤ ទៅ ១/២ស្លាបព្រាកាហ្វេ
- មិនត្រូវប្រើថ្នាំនេះចំពោះកុមារអាយុក្រោម២ឆ្នាំទេ។

**ប្រើសម្រាប់ជួយបញ្ឈប់ការរមាស់** លាយអំបិលជាតិ Magnesium sulfate ៨ស្លាបព្រាកាហ្វេ ជាមួយនឹងទឹក១លីត្រ ហើយលាបលើកន្លែងរមាស់ ជាកុំប្រេស។

<u>**ប្រេងរ៉ៃ**</u> ប្រើជាថ្នាំបញ្ចុះលាមក

ឈ្មោះ______________តម្លៃ________សម្រាប់______

ថ្នាំនេះជួនកាលប្រើចំពោះអ្នកកើតឫសដូងបាត ដែលមានលាមករឹងនិងឈឺ។ ទោះជាយ៉ាងនេះក៏ដោយ ថ្នាំនេះមិនប្រាកដថាជួយឲ្យលាមកទន់ទេ វាគ្រាន់តែធ្វើឲ្យរអិលប៉ុណ្ណោះ។ អាហារដែលមានជាតិសរសៃៗច្រើន ដូចជាកន្ទក់ ក្តួចជាដើម ជាការល្អណាស់។

***កម្រិតប្រើ*** ប្រេងរ៉ៃ ជាថ្នាំបញ្ចុះលាមក :

មនុស្សធំនិងកុមារអាយុចាប់ពី១២ឆ្នាំ : ១-៣ស្លាបព្រាកាហ្វេ យ៉ាងហោច១ម៉ោង បន្ទាប់ពីហូបបាយល្ងាចហើយ។ សូមកុំប្រើថ្នាំនេះពេលបាយ ពីព្រោះជាតិប្រេងនឹងទាញយកជីវជាតិខ្លះពីអាហារ។

***ប្រយ័ត្ន :*** មិនត្រូវឲ្យថ្នាំនេះទៅកុមារអាយុតិចជាង១២ឆ្នាំ ស្ត្រីមានផ្ទៃពោះឬបំបៅដោះកូន អ្នកដែលមិនអាចក្រោកបាន ឬអ្នកដែលមានបញ្ហាក្នុងការលេប។

<u>**ប្រេងរអិលបញ្ចុះលាមក** *(Dulcolax)*</u>

ឈ្មោះ______________តម្លៃ________សម្រាប់______

វាជាថ្នាំរាងដូចគ្រាប់កាំភ្លើង ប្រើសម្រាប់ញាត់ចូលក្នុងរន្ធគូថ។ វាជំរុញពោះវៀនឲ្យធ្វើការបញ្ចេញលាមកមកក្រៅ។

***កម្រិតប្រើ*** ប្រេងរអិលបញ្ចុះលាមក :

មនុស្សធំនិងកុមារអាយុលើស១២ឆ្នាំ : ញាត់ថ្នាំនេះចូលទៅក្នុងរន្ធគូថ ហើយទុកវាប្រហែល ១៥ទៅ៣០នាទី។ កាលណាអ្នកទុកថ្នាំនេះក្នុងរន្ធគូថកាន់តែយូរ វាមានប្រសិទ្ធិភាពកាន់តែប្រសើរ។

# សម្រាប់ជំងឺរាកកម្រិតស្រាល : ថ្នាំប្រឆាំងជំងឺរាក

Kaolin ជាមួយនឹង Pectin *( Kaopectate )*

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនមានជាថ្នាំទឹកដូចទឹកដោះគោ។

ថ្នាំនេះអាចប្រើដើម្បីធ្វើឲ្យជំងឺរាកកម្រិតស្រាល មានលាមករឹង( ទឹកតិច ) និងកាត់បន្ថយបញ្ហារាក។ **វាមិនមែនព្យាបាលមូលហេតុនៃជំងឺរាកទេ ហើយក៏មិនជួយការពារ ឬព្យាបាលការខ្សោះជាតិទឹកក្នុងខ្លួនដែរ។** ថ្នាំនេះមិនមែនជាថ្នាំចាំបាច់ក្នុងការព្យាបាលជំងឺរាកទេ។ ហើយការចូលចិត្តប្រើថ្នាំនេះ គឺជាការខ្ជះខ្ជាយលុយកាក់ប៉ុណ្ណោះ។ **វាមិនត្រូវប្រើថ្នាំនេះចំពោះមនុស្សឈឺធ្ងន់ ឬកុមារតូចៗទេ។ យើងបញ្ចូលថ្នាំនេះនៅទីនេះ គឺគ្រាន់តែព្រមានពីការប្រើថ្នាំនេះប៉ុណ្ណោះ។**

***កម្រិតប្រើ*** KaolinជាមួយនឹងPectin សម្រាប់**ជំងឺរាកកម្រិតស្រាល**ប៉ុណ្ណោះ :

សូមប្រើថ្នាំទឹកទូទៅ ដូចជាKaopectate។

ឲ្យ១កម្រិតប្រើក្រោយពេលជុះ ឬប្រើ ៤ទៅ៥ដងក្នុង១ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ២-៨ស្លាបព្រាបាយ
កុមារអាយុ៦-១២ឆ្នាំ : ១-២ស្លាបព្រាបាយ
កុមារអាយុក្រោម៦ឆ្នាំ : ហាមប្រើ

# សម្រាប់ការតឹងច្រមុះ

ជាញឹកញាប់ ដើម្បីជួយឲ្យធូរច្រមុះ អ្វីដែលចាំបាច់គឺគ្រាន់តែហិតទឹកធម្មតា លាយជាមួយអំបិលបន្តិច ដូចបានបង្ហាញនៅទំ.១៦៤។ ម្តងម្កាលថ្នាំបន្តក់ច្រមុះអាចប្រើបានខាងក្រោម :

ថ្នាំបន្តក់ច្រមុះមានជាតិEphedrine ឬ Phenylephrine *( Neo-Synephrine )*

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ថ្នាំនេះអាចប្រើសម្រាប់ការតឹងច្រមុះ ឬហៀរសំបោរ ជាពិសេសបើអ្នកនោះមាន (ឬឧស្សាហ៍មាន )ការបង្ករោគក្នុងត្រចៀក។

***កម្រិតប្រើ*** ថ្នាំបន្តក់ច្រមុះ :

បន្តក់ ១ទៅ២ដំណក់ក្នុងរន្ធច្រមុះ ដូចបង្ហាញនៅទំ.១៦៤។ បន្តក់ ៤ដងក្នុង១ថ្ងៃ។ **សូមកុំប្រើថ្នាំនេះលើសពី៣ថ្ងៃ** ឬទម្លាប់ប្រើថ្នាំនេះ។

ចំពោះថ្នាំបន្តក់ច្រមុះធ្វើពីថ្នាំគ្រាប់Ephedrine សូមអានទំ.៣៨៥។

# សម្រាប់ការក្អក

ការក្អកជាមធ្យោបាយមួយរបស់រាងកាយ ក្នុងការសម្អាតបំពង់ខ្យល់ដែលនាំចូលទៅសួត និងបង្ការមេរោគនិងស្លេសដែលនៅក្នុងបំពង់ខ្យល់ កុំឲ្យចូលទៅក្នុងសួត។ ដោយសារការក្អកគឺជាមធ្យោបាយការពារមួយផ្នែកនៃរាងកាយ ដូចនេះថ្នាំដែលបំបាត់ឬបន្ថយការក្អក ជួនកាលផ្តល់ផលអាក្រក់ច្រើនជាងល្អ។ **ថ្នាំបន្ថយការក្អក**ទាំងនេះ គួរប្រើតែចំពោះការក្អកស្ងួតដែលអ្នកជំងឺមិនអាចដេកបាន។ មានថ្នាំផ្សេងៗទៀតដែលហៅថា **ថ្នាំជួយឲ្យក្អក** ដែលជួយឲ្យអ្នកជំងឺងាយស្រួលក្នុងការក្អកស្លេសចេញមក។

តាមការពិត ស៊ីរ៉ូក្អកទាំង២យ៉ាងនេះ (បំបាត់ក្អក និងជួយឲ្យក្អក ) ត្រូវបានប្រើច្រើនជាងតម្រូវការទៅទៀត។ ថ្នាំស៊ីរ៉ូក្អកជាច្រើនដែលគេនិយមប្រើ មានប្រសិទ្ធិភាពបន្តិចបន្តួច ឬគ្មានតែម្តង ហើយការប្រើថ្នាំនេះគឺជាការខ្ជះខ្ជាយប្រាក់កាសប៉ុណ្ណោះ។

**ថ្នាំក្អកដែលសំខាន់ជាងគេបំផុតនោះគឺទឹក។** ការផឹកទឹកច្រើន និងហិតស្រូបផ្សែងទឹកក្តៅ ធ្វើឲ្យរលាយស្លេស ហើយជួយបន្ថយការក្អកបានច្រើនជាងការប្រើស៊ីរ៉ូក្អកទៅទៀត។ សម្រាប់សេចក្តីណែនាំ សូមអានទំ.១៦៨។ ហើយការពន្យល់ពីការធ្វើស៊ីរ៉ូក្អកដោយខ្លួនឯង ក៏មាននៅទំ.១៧១ ផងដែរ។

ថ្នាំបន្ថយការក្អក : Codeine

ឈ្មោះ_______________តម្លៃ_________សម្រាប់_______

ច្រើនមានជា : ថ្នាំស៊ីរ៉ូ ឬថ្នាំទឹក។ ក៏មានជាថ្នាំគ្រាប់ ៣០ម.ក្រ ឬ ៦០ម.ក្រផងដែរ ដែលផ្សំ ឬមិនផ្សំជាមួយAspirin ឬ Acetaminophen។

Codeine គឺជាថ្នាំបំបាត់ការឈឺចាប់ដ៏ខ្លាំងមួយ ហើយក៏ជាថ្នាំបន្ថយការក្អកដ៏មានប្រសិទ្ធិភាពមួយដែរ ប៉ុន្តែដោយសារវាធ្វើឲ្យធ្លាប់ ( ជាតិ narcotic ) ប្រហែលជាមានការពិបាកក្នុងការរកវា។ វាច្រើនមានជាស៊ីរ៉ូ ឬថ្នាំគ្រាប់។ ចំពោះកម្រិតប្រើ ចូរមើលសេចក្តីណែនាំដែលភ្ជាប់ជាមួយថ្នាំ។ ការប្រើថ្នាំនេះដើម្បីបន្ថយការក្អក គឺត្រូវលេបតិចជាងការបំបាត់ការឈឺចាប់។ **ដើម្បីបន្ថយការក្អក**ចំពោះមនុស្សធំ Codeine ពី ៧ ទៅ១៥ម.ក្រ គឺគ្រប់គ្រាន់។ ចំពោះកុមារ គួរប្រើឲ្យតិចជាងកម្រិតនេះ អាស្រ័យតាមអាយុ ឬទម្ងន់( មើលទំ.៦២ )។ **ចំពោះការឈឺចាប់ខ្លាំង** មនុស្សធំអាចប្រើCodeineពី ៣០ទៅ៦០ម.ក្រ រៀងរាល់៤ម៉ោងម្តង។

***ប្រយ័ត្ន :*** Codeine ជាថ្នាំធ្វើឲ្យធ្លាប់( ជាតិ narcotic ) ដូច្នេះត្រូវប្រើវា ២ឬបីថ្ងៃប៉ុណ្ណោះ។

# សម្រាប់ជំងឺហឺត

ដើម្បីបង្ការ និងថែទាំព្យាបាលជំងឺហឺតឲ្យបានត្រឹមត្រូវ សូមមើលទំ.១៦៧។ អ្នកដែលមានជំងឺហឺត គួរមានថ្នាំទុកនៅផ្ទះ។ ចាប់ផ្ដើមប្រើថ្នាំនៅពេលមានសញ្ញាដំបូងដោយដកដង្ហើមឮសូរ ឬតឹងទ្រូង។

Ephedrine

ឈ្មោះ_______________តម្លៃ_________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ ១៥ម.ក្រ (ឬ ២៥ម.ក្រដែរ)

Ephedrine មានប្រយោជន៍សម្រាប់បញ្ឈប់ការធ្វើទុក្ខស្រាលៗនៃជំងឺហឺត និងការពារមិនឲ្យជំងឺធ្វើទុក្ខខ្លាំង។ ថ្នាំនេះជួយបើកបំពង់ខ្យល់ ដើម្បីឲ្យខ្យល់ចេញចូលទៅក្នុងសួតបានងាយស្រួល។ វាក៏ត្រូវបានប្រើនៅពេលមានការពិបាកដកដង្ហើមដែលបណ្ដាលមកពីជំងឺរលាកសួត ឬរលាកទងសួត។

Ephedrine ច្រើនផ្សំជាមួយ**Theophylline** ឬ **Aminophylline** និងជួនកាលជាមួយ**Phenobarbital**។ សូមចៀសវាងការប្រើថ្នាំផ្សំនេះ លើកលែងតែអ្នកមិនអាចរកថ្នាំជំងឺហឺតតែឯងបាន។

***កម្រិតប្រើ*** Ephedrineសម្រាប់ជំងឺហឺត (១ម.ក្រ/គ.ក្រ/៣ដងក្នុង១ថ្ងៃ នៅពេលចាប់ផ្ដើមមានរោគសញ្ញា):

ប្រើថ្នាំគ្រាប់១៥ម.ក្រ

ឲ្យថ្នាំលេប ៣ដងក្នុង១ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ១៥-៦០ម.ក្រ (១-៤គ្រាប់)
កុមារអាយុ៥-១០ឆ្នាំ : ១៥-៣០ម.ក្រ (១ឬ២គ្រាប់)
កុមារអាយុ១-៤ឆ្នាំ : ១៥ម.ក្រ (១គ្រាប់
កុមារអាយុក្រោម១ឆ្នាំ : មិនត្រូវឲ្យថ្នាំនេះទេ

ចំពោះការតឹងច្រមុះ អាចប្រើថ្នាំបន្តក់ច្រមុះEphedrine បាន។ គេអាចធ្វើវាបានដោយកិនថ្នាំនេះ ១គ្រាប់ លាយក្នុងទឹក ១ស្លាបព្រាកាហ្វេ។

Theophylline ឬ Aminophylline

ឈ្មោះ_______________តម្លៃ_________សម្រាប់______

ច្រើនមានជាថ្នាំគ្រាប់ និងស៊ីរ៉ូ ដែលមានកម្លាំងខុសៗគ្នា។

សម្រាប់បញ្ឈប់ជំងឺហឺត និងបង្ការការធ្វើទុក្ខ។

***កម្រិតប្រើ*** (៣ទៅ៥ម.ក្រ/គ.ក្រ រាល់ ៦ម៉ោងម្ដង): ប្រើថ្នាំគ្រាប់ ១០០ម.ក្រ

ឲ្យរាល់ ៦ម៉ោងម្ដង :

មនុស្សធំ : ២គ្រាប់
កុមារអាយុ៧-១២ឆ្នាំ : ១គ្រាប់
កុមារអាយុក្រោម៧ឆ្នាំ : ១/២គ្រាប់
ទារក : មិនត្រូវឲ្យថ្នាំនេះទេ

ក្នុងករណីធ្ងន់ធ្ងរ ឬបើវិធីខាងលើនេះមិនអាចបញ្ឈប់ជំងឺហឺតបានទេ អាចប្រើទ្វេរដងនៃកម្រិតប្រើខាងលើ ប៉ុន្តែកុំឲ្យលើសពីនេះ។ បើអ្នកជំងឺមិនអាចនិយាយបាន សូមរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

Salbutamol (Albuterol)

ឈ្មោះ_______________តម្លៃ_________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ៤ម.ក្រ និងស៊ីរ៉ូ ២ម.ក្រក្នុង៥ម.ល

សម្រាប់បញ្ឈប់ជំងឺហឺត និងបង្ការការធ្វើទុក្ខ។ Salbutamol អាចប្រើដាច់តែវា ឬប្រើជាមួយTheophylline។

***កម្រិតប្រើ*** Salbutamol (0,១ម.ក្រ/គ.ក្រ រៀងរាល់ ៦-៨ ម៉ោងម្ដង):

ប្រើថ្នាំគ្រាប់ ៤ម.ក្រ ឬស៊ីរ៉ូ ២ម.ក្រ ក្នុង១ស្លាបព្រាកាហ្វេ

ឲ្យរាល់ ៦-៨ម៉ោងម្ដង :

មនុស្សធំ : ១គ្រាប់ ឬ ២ស្លាបព្រាកាហ្វេ
កុមារអាយុ៦-១២ឆ្នាំ : ១/២គ្រាប់ ឬ ១ស្លាបព្រាកាហ្វេ
កុមារអាយុ២-៥ឆ្នាំ : ១/៤គ្រាប់ ទៅ ១/២គ្រាប់ ឬ ១/២ ទៅ ១ស្លាបព្រាកាហ្វេ
ទារក : មិនត្រូវឲ្យថ្នាំនេះទេ

ក្នុងករណីធ្ងន់ធ្ងរ ឬបើវិធីប្រើខាងលើនេះមិនអាចបញ្ឈប់ជំងឺហឺតបានទេ អាចបង្កើនកម្រិតប្រើបន្តិចម្ដងៗ រហូតដល់ទ្វេរដង។

Adrenaline (Epinephrine, *Adrenaline*)

ឈ្មោះ_______________តម្លៃ_________សម្រាប់______

ច្រើនមានជាអំពូល ១ម.ក្រ ក្នុង១ម.ល

Adrenaline គួរប្រើសម្រាប់ :

១. **ការធ្វើទុក្ខយ៉ាងខ្លាំងនៃជំងឺហឺត** នៅពេលមានបញ្ហាក្នុងការដកដង្ហើម។

២. **ប្រតិកម្មទំនាស់ធ្ងន់ធ្ងរ** ឬប្រតិកម្មអាល់ឡែស៊ី ដោយសារការចាក់Penicillin ថ្នាំAntitoxinsតេតាណូស ឬថ្នាំប្រឆាំងពិសផ្សេងៗទៀត ដែលធ្វើពីសេរ៉ូមសេះ (មើលទំ.៧០)។

***កម្រិតប្រើ*** Adrenalineសម្រាប់**ជំងឺហឺត** : ប្រើថ្នាំអំពូល ១ម.ក្រ ក្នុងទឹក១ម.ល

ដំបូងត្រូវវាស់ជីពចរសិន។ បន្ទាប់មកចាក់នៅក្រោមស្បែក (មើលទំ.១៦៧) :

មនុស្សធំ : ១/៣ម.ល
កុមារអាយុ៧-១២ឆ្នាំ : ១/៥ម.ល
កុមារអាយុ១-៦ឆ្នាំ : ១/១០ម.ល
កុមារអាយុក្រោម១ឆ្នាំ : មិនត្រូវឲ្យថ្នាំនេះទេ

***កម្រិតប្រើ*** Adrenalineសម្រាប់**ប្រតិកម្មអាល់ឡែស៊ី** : ប្រើថ្នាំអំពូល ១ម.ក្រ ក្នុងទឹក១ម.ល

ចាក់ទៅក្នុងសាច់ដុំ :

មនុស្សធំ : ១/២ម.ល
កុមារអាយុ៧-១២ឆ្នាំ : ១/៣ម.ល
កុមារអាយុ១-៦ឆ្នាំ : ១/៤ម.ល
កុមារអាយុក្រោម១ឆ្នាំ : មិនត្រូវឲ្យថ្នាំនេះទេ

បើចាំបាច់ អាចចាក់ម្តងទៀតនៅកន្លះម៉ោងបន្ទាប់ និងលើកទី៣នៅកន្លះម៉ោងក្រោយទៀត។ មិនត្រូវចាក់ឲ្យលើស៣ដងទេ។ សូមកុំចាក់បន្ថែមទៀត ប្រសិនបើជីពចរលោតលឿនជាង ៣០ដងក្នុង១នាទីបន្ទាប់ពីចាក់លើកទី១។

**ក្នុងការប្រើAdrenaline សូមប្រយ័ត្នកុំឲ្យលើសពីកម្រិតដែលបានណែនាំខាងលើនេះ។**

## សម្រាប់ប្រតិកម្មទំនាស់ និងការក្អួត :

### ថ្នាំAntihistamine

ថ្នាំAntihistamine ជាថ្នាំដែលប៉ះពាល់ដល់រាងកាយ តាមរបៀបផ្សេងៗ :

១. វាជួយបន្ថយ ឬបង្ការប្រតិកម្មទំនាស់ ដូចជា កន្ទួលរមាស់ ដុំពកលើស្បែក បន្ទាលត្រអាក ជំងឺរលាកច្រមុះ និងប្រតិកម្មអាល់ឡែស៊ី។

២. វាជួយបង្ការ ឬបញ្ឈប់ការពុលពេលធ្វើដំណើរតាមយានយន្ត ឬការក្អួត។

៣. វាច្រើនធ្វើឲ្យងងុយដេក។ នៅពេលប្រើថ្នាំ Antihistamine ចូរចៀសវាងធ្វើការងារដែលមានគ្រោះថ្នាក់ បញ្ជាគ្រឿងម៉ាស៊ីន ឬផឹកស្រា។

**Promethazine** *(Phenergan)* និង **Diphenhydramine** *(Benadryl)* ជាថ្នាំAntihistamineកម្រិតខ្លាំង ដែលបណ្តាលឲ្យងងុយដេក។ **Dimenhydrinate** *(Dramamine)* មានលក្ខណៈប្រហែលនឹងDimenhydrinateដែរ ហើយគេនិយមប្រើសម្រាប់ការពុលពេលធ្វើដំណើរតាមយានយន្ត។ ទោះជាយ៉ាងនេះក៏ដោយ ការក្អួតដែលបណ្តាលមកពីមូលហេតុផ្សេងទៀត Promethazineច្រើនមានប្រសិទ្ធភាពល្អជាង។

**Chlorpheniramine** គឺជាAntihistamineដែលមានតម្លៃថោកជាង និងបណ្តាលឲ្យងងុយដេកតិចតួចជាង។ ដូចនេះហើយបានជាជួនកាល គេប្រើChlorpheniramine ដើម្បីបន្ថយការរមាស់នៅពេលថ្ងៃ។ Promethazine មានប្រយោជន៍នៅពេលយប់ ព្រោះវាធ្វើឲ្យងងុយដេក និងធ្វើឲ្យបាត់រមាស់ក្នុងពេលជាមួយគ្នា។

គ្មានភស្តុតាងណាបង្ហាញថាថ្នាំAntihistamine ប្រើកបនឹងជំងឺផ្តាសាយធម្មតានោះទេ។ វាត្រូវបានប្រើលើសពីអ្វីដែលវាគួរប្រើ។ មិនគួរប្រើថ្នាំនេះច្រើនពេកទេ។

ថ្នាំAntihistamine **មិនគួរ**ប្រើចំពោះជំងឺហឺតទេ ព្រោះវាធ្វើឲ្យស្លេសកាន់តែស្អិត និងធ្វើឲ្យរឹតតែពិបាកដកដង្ហើម។

គួរមានថ្នាំAntihistamineតែមួយប្រភេទនៅក្នុងប្រអប់ថ្នាំពេទ្យ គឺគ្រប់គ្រាន់។ Promethazine ជាជម្រើសដ៏ល្អមួយ។ ដោយសារមិនអាចរកថ្នាំPromethazine បានរៀងរាល់ពេល ទើបយើងបានដាក់បង្ហាញពីកម្រិតប្រើថ្នាំAntihistamineដទៃទៀត ក្នុងសៀវភៅនេះ។

តាមក្បួនទូទៅ **ប្រសើរបំផុតគួរប្រើថ្នាំAntihistamineជាថ្នាំលេប។** ការចាក់ថ្នាំនេះ គួរធ្វើដើម្បីតែបញ្ឈប់ការក្អួតធ្ងន់ធ្ងរ ឬមុនពេលឲ្យថ្នាំAntitoxinsប៉ុណ្ណោះ (គេតាណូស ពស់ចឹក ។ល។) នៅពេលដែលមានគ្រោះថ្នាក់នៃប្រតិកម្មអាល់ឡែស៊ី។ ចំពោះកុមារ ជាការល្អគួរប្រើថ្នាំសុលតាមរន្ធគូថ។

<u>Promethazine (Phenergan)</u>

ឈ្មោះ:______________ តម្លៃ________ សម្រាប់______

ច្រើនមានជា :

គ្រាប់ ១២,៥ម.ក្រ តម្លៃ_______ សម្រាប់______
អំពូលសម្រាប់ចាក់ ២៥ម.ក្រក្នុង១ម.ល
តម្លៃ_______ សម្រាប់______
ថ្នាំសុល ១២,៥ម.ក្រ ២៥ម.ក្រ និង៥០ម.ក្រ
តម្លៃ_______ សម្រាប់______

***ប្រយ័ត្ន :*** ស្ត្រីមានផ្ទៃពោះគួរប្រើPromethazineនៅពេលដែលចាំបាច់ប៉ុណ្ណោះ។

***កម្រិតប្រើ*** Promethazine (១ម.ក្រ/គ.ក្រ/ថ្ងៃ): ប្រើថ្នាំគ្រាប់ ១២,៥ម.ក្រ

ឲ្យថ្នាំលេប ២ដងក្នុង១ថ្ងៃ

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ២៥-៥០ម.ក្រ (២-៤គ្រាប់)
កុមារអាយុ៧-១២ឆ្នាំ : ១២,៥-២៥ម.ក្រ (១ឬ២គ្រាប់)
កុមារអាយុ២-៦ឆ្នាំ : ៦-១២ម.ក្រ (១/២-១គ្រាប់)
ទារកអាយុ១ឆ្នាំ : ៤ម.ក្រ (១/៣គ្រាប់)
ទារកអាយុក្រោម១ឆ្នាំ : ៣ម.ក្រ (១/៤គ្រាប់)

ប្រើថ្នាំចាក់តាមសាច់ដុំ ២៥ម.ក្រ ក្នុង១ម.ល

ចាក់ម្តង ហើយបើចាំបាច់អាចចាក់ម្តងទៀតនៅ ២ឬ៤ម៉ោងបន្ទាប់។

ក្នុង១កម្រិត ចាក់ :

មនុស្សធំ : ២៥-៥០ម.ក្រ (១ ទៅ ២ម.ល)
កុមារអាយុ៧-១២ឆ្នាំ : ១២,៥ ទៅ ២៥ម.ក្រ (១/២ ទៅ ១ម.ល)
កុមារអាយុក្រោម៧ឆ្នាំ : ៦-១២ម.ក្រ (១/៤ ទៅ ១/២ម.ល)
ទារកអាយុ១ឆ្នាំ : ២,៥ម.ក្រ (០,១ម.ល)

ប្រើថ្នាំសុលតាមរន្ធគូថ ២៥ម.ក្រ

សុលចូលរន្ធគូថ ហើយបើចាំបាច់អាចសុលម្តងទៀតនៅ ៤ទៅ៦ម៉ោងបន្ទាប់។

ក្នុងកម្រិតនីមួយៗ សុល :

មនុស្សធំនិងកុមារអាយុលើស១២ឆ្នាំ : ២៥ម.ក្រ (១ គ្រាប់សុល)
កុមារអាយុ៧-១២ឆ្នាំ : ១២,៥ម.ក្រ (១/២ គ្រាប់សុល)
កុមារអាយុ២-៦ឆ្នាំ : ៦ម.ក្រ (១/៤ គ្រាប់សុល)

Diphenhydramine (Benadryl)

ឈ្មោះ_____________________

ច្រើនមានជា :
ថ្នាំគ្រាប់ ២៥ម.ក្រ និង៥០ម.ក្រ
តម្លៃ_______សម្រាប់_______
អំពូលសម្រាប់ចាក់ ១០ម.ក្រ ឬ៥០ម.ក្រ ក្នុង១ម.ល
តម្លៃ_______សម្រាប់_______

***ប្រយ័ត្ន :*** សូមកុំប្រើDiphenhydramineចំពោះទារកទើបកើត ឬស្ត្រី បំបៅដោះកូន។ ល្អបំផុតមិនគួរប្រើចំពោះស្ត្រីមានផ្ទៃពោះទេ លើកលែងតែចាំបាច់បំផុត។

***កម្រិតប្រើ*** ហ្វេនីដពូមីន (៥ម.ក្រ/គ.ក្រ/ថ្ងៃ): ប្រើថ្នាំគ្រាប់ ២៥ម.ក្រ

ឲ្យ ៣ឬ៤ដង ក្នុង១ថ្ងៃ :

មនុស្សធំ : ២៥-៥០ម.ក្រ (១ឬ២គ្រាប់)
កុមារអាយុ៨-១២ឆ្នាំ : ២៥ម.ក្រ (១គ្រាប់)
កុមារអាយុ២-៧ឆ្នាំ : ១២,៥ម.ក្រ (១/២គ្រាប់)
ទារក : ៦ម.ក្រ (១/៤គ្រាប់)

ប្រើថ្នាំចាក់តាមសាច់ដុំ ៥០ម.ក្រ ក្នុង១ម.ល

គួរចាក់Diphenhydramineតែក្នុងករណីមានប្រតិកម្មអាល់ទ្បែស៊ីប៉ុណ្ណោះ។ ចាក់១ដង ហើយបើចាំបាច់អាចចាក់ម្តងទៀតនៅ ២ទៅ៤ម៉ោងបន្ទាប់ :

មនុស្សធំ : ២៥-៥០ម.ក្រ (១/២-១ម.ល)
កុមារ: ១០-២៥ម.ក្រ អាស្រ័យលើទំហំ (១/៥-១/២ម.ល)
ទារក : ៥ម.ក្រ (១/១០ម.ល)

Chlorpheniramine

ឈ្មោះ_____________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ៤ម.ក្រ (ក៏មានជាគ្រាប់ទំហំផ្សេងទៀត និងស៊ីរ៉ូ ។ល។)

***កម្រិតប្រើ*** Chlorpheniramine :

ប្រើ ១កម្រិត ៣ឬ៤ដងក្នុង១ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ៤ម.ក្រ (១គ្រាប់)
កុមារអាយុក្រោម១២ឆ្នាំ : ២ម.ក្រ (១/២គ្រាប់)
ទារក : ១ម.ក្រ (១/៤គ្រាប់)

Dimenhydrinate *(Dramamine)*

ឈ្មោះ_____________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ៥០ម.ក្រ ក៏មានជាស៊ីរ៉ូ ១២,៥ម.ក្រ ក្នុង១ស្លាបព្រាកាហ្វេ និងក៏មានជាថ្នាំសុលរន្ធគូថផងដែរ។

ថ្នាំនេះច្រើនលក់សម្រាប់ការពុលពេលធ្វើដំណើរតាមយានយន្ត ប៉ុន្តែក៏អាចប្រើដូចថ្នាំAntihistamineឯទៀតដែរ ក្នុងការបំបាត់ប្រតិកម្មទំនាស់ និងធ្វើឲ្យងងុយដេក។

***កម្រិតប្រើ*** Dimenhydrinate :

អាចលេបរហូតដល់ ៤ដងក្នុង១ថ្ងៃ។

ក្នុងកម្រិតនីមួយៗ ឲ្យ :

មនុស្សធំ : ៥០-១០០ម.ក្រ (១ឬ២គ្រាប់)
កុមារអាយុ៧-១២ឆ្នាំ : ២៥-៥០ម.ក្រ (១/២-១គ្រាប់)
កុមារអាយុ២-៦ឆ្នាំ : ១២-២៥ម.ក្រ (១/៤-១/២គ្រាប់)
កុមារអាយុក្រោម២ឆ្នាំ : ៦-១២ម.ក្រ (១/៨-១/៤គ្រាប់)

## ថ្នាំAntitoxins

***ប្រយ័ត្ន :*** ថ្នាំAntitoxinsជាច្រើន ត្រូវបានធ្វើពីសេរ៉ូមសេះ ដូចជាថ្នាំAntitoxinsតេតាណូសមួយចំនួន និង ថ្នាំប្រឆាំងពស់ពិស សម្រាប់ពស់ចិក ឬខ្យារដំរីទិច។ ដោយហេតុនេះហើយ ថ្នាំទាំងនេះអាចធ្វើឲ្យមានប្រតិកម្មទំនាស់ដ៏គ្រោះថ្នាក់ (សម្រាប់ប្រតិកម្មអាល់ឡែស៊ី សូមមើលទំ.៧០)។ មុននឹងអ្នកចាក់ថ្នាំAntitoxinsដែលធ្វើពីសេរ៉ូមសេះ **អ្នកត្រូវមាន Adrenalineទុកជាស្រេច សម្រាប់ករណីអាសន្ន។** ចំពោះអ្នកដែលមានប្រតិកម្ម ឬអ្នកដែលធ្លាប់បានទទួលថ្នាំAntitoxinsធ្វើពីសេរ៉ូមសេះពីមុនមក ជាការល្អគួរចាក់Antihistamine ដូចជា Promethazine (*Phenergan*) ឬDiphenhydramine (*Benadryl*) ១៥នាទីមុននឹងឲ្យថ្នាំAntitoxins។

**<u>ថ្នាំAntitoxins ប្រឆាំងពិសពស់</u>**

ឈ្មោះ________________តម្លៃ__________សម្រាប់______

ច្រើនមានជាដបសម្រាប់ចាក់

នៅបណ្តាប្រទេសជាច្រើន ថ្នាំAntitoxins ឬថ្នាំផ្សេងៗទៀតដែលការពាររាងកាយពីជាតិពុល ត្រូវបានបង្កើតឡើងសម្រាប់ព្យាបាលពស់ចិក។ ប្រសិនបើអ្នករស់នៅតំបន់ដែលឧស្សាហ៍មានមនុស្សត្រូវពស់ចឹក **ចូររកថ្នាំប្រឆាំងពស់ពិសទុកជាមុន** ហើយត្រៀមប្រើឲ្យរួចជាស្រេច។ ថ្នាំប្រឆាំងពស់ពិសមួយចំនួនអាចរក្សាទុកបានដោយមិនចាំបាច់ប្រើទូរទឹកកក ឯថ្នាំខ្លះទៀតចាំបាច់ត្រូវទុកឲ្យត្រជាក់ជានិច្ច។

ខាងក្រោមនេះ គឺជាកន្លែងចែកចាយផលិតផលថ្នាំ Antitoxins។ នៅប្រទេសជាច្រើន រដ្ឋាភិបាលរបស់គេផ្គត់ផ្គង់ថ្នាំបន្សាពិសទាំងនេះ

**ប្រទេសថៃ :** សង្គមកាកបាទក្រហមថៃ, បាងកក ប្រទេសថៃ ទូរស័ព្ទ: ៦៦-២២៥៥-៤៦១ ទូរសារ : ៦៦-២២៥២-៧៧៩៥ www.redcross.org.th.

ជាធម្មតា សេចក្តីណែនាំអំពីការប្រើប្រាស់ថ្នាំប្រឆាំងពស់ពិសចំពោះពស់ចឹក មាននៅក្នុងកញ្ចប់ថ្នាំ។ សូមមើលឲ្យច្បាស់មុននឹងប្រើវា។ បើពស់កាន់តែធំ ឬអ្នកដែលពស់ចឹកកាន់តែតូច នោះបរិមាណថ្នាំដែលត្រូវប្រើគឺមានកាន់តែច្រើន។ ជាញឹកញាប់ គេត្រូវប្រើថ្នាំចំនួន ២ដប ឬច្រើនជាងនេះ។ ដើម្បីជួយសង្គ្រោះប្រកបដោយប្រសិទ្ធភាពបំផុត ត្រូវចាក់ថ្នាំប្រឆាំងពស់ពិស ឲ្យបានឆាប់រហ័យនៅពេលដែលនរណាម្នាក់ត្រូវពស់ចឹក។

ត្រូវប្រាកដថាបានធ្វើតាមការប្រុងប្រយ័ត្នដែលចាំបាច់ ដើម្បីចៀសវាងប្រតិកម្មអាល់ឡែស៊ី (មើលទំ.៧០)។

**ព័ត៌មានអំពីថ្នាំAntitoxins ប្រឆាំងពិសខ្យារដំរី ត្រូវបានដកចេញនៅក្នុងការបោះពុម្ពថ្មីនេះ។**



<u>ថ្នាំAntitoxinsសម្រាប់តេតាណូស</u>

ថ្នាំវ៉ាក់សាំងតេតាណូស (សេរ៉ូមមនុស្ស) ច្រើនមានជា : កូនដបចំណុះ ២៥០អ៊ុយនីតេ

ថ្នាំAntitoxinsសម្រាប់តេតាណូស (សេរ៉ូមសេះ) ច្រើនមានជា : កូនដបចំណុះ ១.៥០០, ២០.០០០, ៤០.០០០ និង ៥០.០០០អ៊ុយនីតេ

នៅតំបន់ដែលប្រជាជនមិនបានចាក់ថ្នាំការពារតេតាណូសទេ គួរមានថ្នាំAntitoxinsតេតាណូសនៅក្នុងប្រអប់ថ្នាំពេទ្យ។ វាមាន២ប្រភេទ ទី១គឺធ្វើពីសេរ៉ូមមនុស្ស (វ៉ាក់សាំងតេតាណូស) និងទី២គឺធ្វើពីសេរ៉ូមសេះ (ថ្នាំAntitoxins តេតាណូស)។ **ប្រសិនបើអាច ចូរប្រើវ៉ាក់សាំងតេតាណូស ព្រោះវាមិនសូវជាធ្វើឲ្យមានប្រតិកម្មទំនាស់ធ្ងន់ធ្ងរទេ។**

ប៉ុន្តែប្រសិនបើអ្នកមានថ្នាំAntitoxinsតេតាណូសសេរ៉ូមសេះ ត្រូវប្រុងប្រយ័ត្នពីប្រតិកម្មទំនាស់ : ប្រសិនបើអ្នកជំងឺមានជំងឺហឺត ឬប្រតិកម្មផ្សេងៗទៀត ឬធ្លាប់ទទួលថ្នាំAntitoxinsធ្វើពីសេរ៉ូមសេះពីមុនមក ត្រូវចាក់ថ្នាំAntihistamine ដូចជា Promethazine ១៥នាទីសិន មុននឹងចាក់ថ្នាំAntitoxins។

**ប្រសិនបើអ្នកជំងឺមិនបានចាក់ថ្នាំការពារតេតាណូសសព្វគ្រប់** ហើយមានដំបៅធ្ងន់ធ្ងរដែលទំនងជានឹងកើតតេតាណូស (មើលទំ.៨៩) ដូច្នេះត្រូវចាក់វ៉ាក់សាំងតេតាណូស ២៥០ អ៊ុយនីតេ (១កូនដប) **មុននឹងរោគសញ្ញាតេតាណូសកើតឡើង។** ប្រសិនបើអ្នកប្រើថ្នាំAntitoxinsតេតាណូស សូមចាក់ពី ១.៥០០ ទៅ ៣.០០០អ៊ុយនីតេ។ បើទារក ចាក់ ៧៥០ អ៊ុយនីតេ។

**ប្រសិនបើអ្នកជំងឺមានសញ្ញាតេតាណូស** សូមចាក់វ៉ាក់សាំងតេតាណូស ៥.០០០អ៊ុយនីតេ ឬចាក់ថ្នាំAntitoxinsតេតាណូស ៥០.០០០អ៊ុយនីតេ។ ចាក់ថ្នាំនេះតាមសាច់ដុំច្រើនកន្លែង នៅតំបន់សាច់ដុំធំៗលើរាងកាយ (ត្រគៀក និងភ្លៅ)។ ឬអាចចាក់ពាក់កណ្តាល តាមសរសៃបាន បើមានអ្នកចេះចាក់។

ធម្មតារោគសញ្ញានៃតេតាណូសនៅតែបន្តមានលក្ខណៈធ្ងន់ធ្ងរទោះជាបានទទួលការព្យាបាលដោយថ្នាំAntitoxinsក្តី។ **វិធានការព្យាបាលផ្សេងទៀតដែលបានរៀបរាប់នៅទំ.១៨៣ និង១៨៤ មានលក្ខណៈប្រហែល ឬសំខាន់ជាងនេះទៀត។** ចូរចាប់ផ្តើមព្យាបាលភ្លាមៗ ហើយរកជំនួយពីគ្រូពេទ្យឲ្យបានឆាប់។

# សម្រាប់ការលេបថ្នាំពុល

<u>ម្សៅធ្យូង</u>

ថ្នាំនេះមានជាម្សៅ។ សូមធ្វើតាមការណែនាំមាននៅលើដបថ្នាំ ឬលាយតាមកម្រិតថ្នាំដែលបានបង្ហាញ ជាមួយទឹក ឬទឹកផ្លែឈើ ១កែវ ហើយផឹកឲ្យអស់។

ម្សៅធ្យូងបឺតជាតិពុលដែលបានលេប ហើយបន្ថយគ្រោះថ្នាក់ដែលអាចមាន។ វាមានប្រសិទ្ធិភាពបំផុត ពេលប្រើភ្លាមៗបន្ទាប់ពីលេបថ្នាំពុល។ **ហាមប្រើថ្នាំនេះ ប្រសិនបើជននោះបានលេបអាស៊ីដខ្លាំង ទឹកគីមីសម្អាត សាំង ឬប្រេងកាត។**

***កម្រិតប្រើ*** ម្សៅធ្យូង ក្នុងអំឡុងពេល១ម៉ោង បន្ទាប់ពីលេបថ្នាំពុល :

មនុស្សធំនិងកុមារអាយុចាប់ពី១២ឆ្នាំ : ៥០-១០០ក្រ. ១ដងប៉ុណ្ណោះ
កុមារអាយុ១-១២ឆ្នាំ : ២៥ក្រ. ១ដងប៉ុណ្ណោះ ឬ ៥០ក្រ. ក្នុងករណីពុលខ្លាំង
កុមារអាយុក្រោម១ឆ្នាំ : ១ក្រ./គ.ក្រ ១ដងប៉ុណ្ណោះ

ដើម្បីបំបាត់ជាតិពុលចេញពីរាងកាយ បន្ទាប់ពីថ្នាំពុលបានបញ្ចេញឥទ្ធិពល :

មនុស្សធំនិងកុមារអាយុលើស១ឆ្នាំ : ២៥-៥០ក្រ. រាល់ ៤ទៅ៦ម៉ោងម្តង
កុមារអាយុក្រោម១ឆ្នាំ : ១ក្រ./គ.ក្រ ១ដង ហើយបន្ថែមពាក់កណ្តាលនៃកម្រិតប្រើនេះ រាល់២ទៅ៤ម៉ោងម្តង។ ឧទាហរណ៍ ប្រសិនបើទារកមានទម្ងន់ ៦គ.ក្រ ត្រូវឲ្យថ្នាំ ម្សៅធ្យូង ៦ក្រ.សម្រាប់កម្រិតទី១ និងឲ្យ ៣ក្រ.ទៀត រៀងរាល់២ទៅ៤ម៉ោងបន្ទាប់។

# សម្រាប់ការប្រកាច់

Phenobarbital និងPhenytoin ជាថ្នាំនិយមប្រើញឹកញាប់សម្រាប់បង្ការការប្រកាច់នៃជំងឺឆ្កួតជ្រូក។ ថ្នាំផ្សេងទៀតមានតម្លៃថ្លៃ ជួនកាលអាចរកបានដែរ ហើយគ្រូពេទ្យច្រើនតែបង្គាប់ឲ្យទិញថ្នាំ ២ឬច្រើនមុខ។ ទោះជាយ៉ាងនេះក្តី ជាធម្មតាថ្នាំតែ១មុខក៏មានប្រសិទ្ធភាពល្អដែរ ឬក៏ប្រសើរជាងទៅទៀត ព្រមទាំងមានផលរំខានតិចតួច។ ថ្នាំបង្ការការប្រកាច់គួរប្រើល្អបំផុតនៅពេលចូលដេក ព្រោះវាច្រើនតែធ្វើឲ្យងងុយដេក។ Diazepam អាចប្រើសម្រាប់បញ្ឈប់ការប្រកាច់រយៈពេលយូរនៃជំងឺឆ្កួតជ្រូក ប៉ុន្តែធម្មតាគេមិនប្រើវារាល់ថ្ងៃដើម្បីបង្ការការប្រកាច់នោះទេ។

<u>Phenobarbital (phenobarbitone, *Luminal*)</u>

ឈ្មោះ:______________________

ច្រើនមានជា :
ថ្នាំគ្រាប់ ១៥ម.ក្រ ៣០ម.ក្រ ៦០ម.ក្រ និង ១០០ម.ក្រ
តម្លៃ_____សម្រាប់_____
ស៊ីរ៉ូ ១៥ម.ក្រក្នុង៥ម.ល
តម្លៃ_____សម្រាប់_____

Phenobarbitalអាចលេបដើម្បីបង្ការការប្រកាច់ (ជំងឺឆ្កួតជ្រូក)។ ចំពោះជំងឺឆ្កួតជ្រូក ភាគច្រើនគេត្រូវប្រើថ្នាំនេះអស់មួយជីវិត។ ក្នុងករណីនេះគេគួរប្រើកម្រិតស្រាលបំផុត។

***ប្រយ័ត្ន :*** ការប្រើថ្នាំPhenobarbitalច្រើនពេក អាចបន្ថយ ឬបញ្ឈប់ការដកដង្ហើម។ សកម្មភាពរបស់វាចាប់ផ្តើមយឺតៗ តែមានរយៈពេលយូរ (អាចដល់២៤ម៉ោង ឬយូរជាងនេះ បើអ្នកជំងឺមិននោម)។ **សូមប្រយ័ត្ន មិនត្រូវឲ្យថ្នាំនេះច្រើនពេកទេ!**

***កម្រិតប្រើ*** Phenobarbital :

មនុស្សធំនិងកុមារអាយុលើសពី១២ឆ្នាំ : ១-៣ម.ក្រ/គ.ក្រ/ថ្ងៃ ជាថ្នាំលេប ចែកជា ២ឬ៣កម្រិតស្មើគ្នា ឬមួយឲ្យ ៥០-១០០ម.ក្រ ២ឬ៣ដងក្នុង១ថ្ងៃ

កុមារអាយុ១២ឆ្នាំចុះក្រោម : ឲ្យថ្នាំលេប ១កម្រិតនៅពេលយប់ អាចឲ្យម្តងទាំងអស់ ឬចែកជាពីកម្រិតស្មើគ្នា តាមខាងក្រោម :

កុមារអាយុ៥-១២ឆ្នាំ : ៤-៦ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុ១-៥ឆ្នាំ : ៦-៨ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុក្រោម១ឆ្នាំ : ៥-៨ម.ក្រ/គ.ក្រ/ថ្ងៃ

**យើងមិនបង្ហាញពីកម្រិតប្រើនៃថ្នាំចាក់នៅទីនេះទេ ព្រោះការចាក់ថ្នាំនេះ មានគ្រោះថ្នាក់ខ្លាំងណាស់។** វាគួរត្រូវបានចាក់តែក្នុងករណីអ្នកចាក់នោះមានបទពិសោធន៍ក្នុងការចាក់តាមសរសៃវ៉ែនប៉ុណ្ណោះ (មើលទំ.១៧៨)។

Phenytoin (diphenylhydantoin, *Dilantin*)

ឈ្មោះ________________________________

ច្រើនមានជា :

ថ្នាំគ្រាប់ ២៥ម.ក្រ ៥០ម.ក្រ និង១០០ម.ក្រ
តម្លៃ_____សម្រាប់_____

ស៊ីរ៉ូ ២៥០ម.ក្រក្នុង៥ម.ល
តម្លៃ_____សម្រាប់_____

ថ្នាំនេះជួយបង្ការការប្រកាច់នៃជំងឺឆ្កួតជ្រូក។ ជាញឹកញាប់ថ្នាំនេះត្រូវប្រើអស់មួយជីវិត។ ក្នុងការប្រើបែបនេះ គេគួរតែប្រើកម្រិតស្រាលបំផុត។

***ផលរំខាន :*** ជាញឹកញាប់ធ្វើឲ្យហើម និងរីកអញ្ចាញធ្មេញ ចំពោះការប្រើថ្នាំPhenytoinយូរពេក។ ប្រសិនបើផលរំខាននេះធ្ងន់ធ្ងរ គួរតែប្រើថ្នាំផ្សេងជំនួសវិញ។ បញ្ហាអញ្ចាញធ្មេញអាចបង្ការបានមួយផ្នែក ដោយការសម្អាតធ្មេញនិងអញ្ចាញឲ្យស្អាតក្រោយពេលហូបអ្វីហើយ។

***កម្រិតប្រើ*** Phenytoin ជាថ្នាំលេប

បែងចែកកម្រិតប្រើប្រចាំថ្ងៃ ជា២ឬ៣ចំណែកស្មើគ្នា។ ឧទាហរណ៍ ប្រសិនកុមារអាយុ៤ឆ្នាំ ដែលមានទម្ងន់២០គ.ក្រ ត្រូវឲ្យ១៥០ម.ក្រក្នុង១ថ្ងៃ ដោយចែកវាជា២កម្រិតប្រើដែលកម្រិតនីមួយៗមានថ្នាំ៧៥ម.ក្រ ឬជា៣កម្រិត ត្រូវជា៥០ម.ក្រ ក្នុងកម្រិតនីមួយៗ។

មនុស្សធំនិងកុមារអាយុលើសពី១៦ឆ្នាំ : ៤-៦ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុ១០-១៦ឆ្នាំ : ៦-៧ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុ៧-៩ឆ្នាំ : ៧-៨ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុ៤-៦ឆ្នាំ : ៧,៥-៩ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុ៦ខែ-៤ឆ្នាំ : ៨-១០ម.ក្រ/គ.ក្រ/ថ្ងៃ
កុមារអាយុក្រោម៦ខែ : ៥ម.ក្រ/គ.ក្រ/ថ្ងៃ

ប្រសិនបើប្រើតាមកម្រិតនេះហើយ មិនបានបង្ការការធ្វើទុក្ខបានល្អទេ សូមបង្កើនកម្រិតប្រើបន្តិចម្តងៗ រៀងរាល់១៥ថ្ងៃម្តង រហូតដល់គ្រប់កម្រិតអតិបរមាតាមទម្ងន់របស់គេ ដោយចែកកម្រិតប្រើថ្នាំនេះ ជា៣ចំណែកស្មើៗគ្នា សម្រាប់១ថ្ងៃ។

ប្រសិនបើប្រើតាមកម្រិតនេះ ធ្វើការបង្ការបានល្អហើយ សូមបន្ថយកម្រិតប្រើបន្តិចម្តងៗ រហូតដល់កម្រិតប្រើអប្បរមា។

យើងមិនបង្ហាញពីកម្រិតប្រើPhenytoinជាថ្នាំចាក់ទេ។ វាគួរប្រើ ដោយអ្នកចាក់ដែលមានបទពិសោធន៍ក្នុងការចាក់តាមសរសៃវ៉ែនប៉ុណ្ណោះ(មើលទំ.១៧៨)។

Diazepam (*Valium*)

ឈ្មោះ_____________តម្លៃ_________សម្រាប់______

ច្រើនមានជា :

ថ្នាំចាក់ ៥ម.ក្រក្នុងថ្នាំទឹក១ម.ល
ថ្នាំចាក់ ១០ម.ក្រក្នុងថ្នាំទឹក២ម.ល
ថ្នាំគ្រាប់ ៥ម.ក្រ និង ១០ម.ក្រ

យើងមិនបង្ហាញពីកម្រិតប្រើDiazepamជាថ្នាំចាក់ទេ។ វាគួរប្រើដោយអ្នកចាក់ដែលមានបទពិសោធន៍ក្នុងការចាក់តាមសរសៃវ៉ែនប៉ុណ្ណោះ(មើលទំ.១៧៨)។

**ដើម្បីបញ្ឈប់ការប្រកាច់នៃជំងឺឆ្កួតជ្រូក**ដែលអូសបន្លាយយូរជាង១៥នាទី ត្រូវចាក់ថ្នាំទឹកសម្រាប់ចាក់ ចូលទៅក្នុងរន្ធគូថ ដោយមិនប្រើម្ជុល ឬអាចកិនថ្នាំ១គ្រាប់ឲ្យម៉ត់ លាយជាមួយទឹក រួចចាក់ចូលរន្ធគូថ។

***កម្រិតប្រើ*** ការលាយថ្នាំDiazepam ដាក់ក្នុងរន្ធគូថ:

មនុស្សធំនិងកុមារទម្ងន់លើស១០គ.ក្រ:
០,៥ម.ក្រ/គ.ក្រ អាចបង្កើនដល់ ១០ម.ក្រអតិបរមា
កុមារទម្ងន់ក្រោម១០គ.ក្រ:
០,២-០,៣ម.ក្រ/គ.ក្រ ឬ ១ម.ក្រ/ក្នុងអាយុ១ឆ្នាំ
សម្រាប់មនុស្សចាស់ខ្លាំង : ០,២៥ម.ក្រ/គ.ក្រ

ប្រសិនបើការប្រកាច់មិនអាចគ្រប់គ្រងបានដោយប្រើថ្នាំ១កម្រិតប្រើទេ អ្នកអាចបន្តកម្រិតបន្ទាប់ទៀត រាល់១២ម៉ោងម្តង។

*ប្រយ័ត្ន :*

១. ការប្រើDiazepamច្រើនពេក អាចបន្ថយឬបញ្ឈប់ការដកដង្ហើម។ សូមប្រយ័ត្ន មិនត្រូវប្រើថ្នាំនេះច្រើនពេកទេ!

២. Diazepamជាប្រភេទថ្នាំដែលធ្វើឲ្យញៀន។ ចៀសវាងការប្រើយូរ ឬញឹកញាប់ពេក។ ទុកថ្នាំនេះក្នុងទូចាក់សោរ។

**ចំពោះតេតាណូស** ឲ្យល្មមតែអាចបញ្ឈប់ការកន្ត្រាក់សាច់ដុំបាន។ ចំពោះមនុស្សធំ និងកុមារអាយុលើស៥ឆ្នាំ ឲ្យលើកដំបូងជាថ្នាំលេប ឬតាមគូថ ចំនួន៥ម.ក្រ (បន្ថយកម្រិតថ្នាំចំពោះកុមារ) ហើយឲ្យបន្ថែមទៀតនៅពេលក្រោយ បើចាំបាច់ ប៉ុន្តែក្នុង១ដងមិនត្រូវឲ្យលើស១០ម.ក្រ ឬមិនឲ្យលើស ៥០ ម.ក្រក្នុង១ថ្ងៃ។ រង់ចាំ ៣០នាទី មុននឹងបន្តកម្រិតថ្នាំថ្មីទៀត។ ចំពោះកុមារអាយុតិចជាង៥ឆ្នាំ ឲ្យ ១ទៅ២ម.ក្រ តាមគូថ រាល់ ៣ទៅ៤ម៉ោងម្តង។

**ដើម្បីសំរួលសាច់ដុំ និងបន្ថយការឈឺចាប់** ត្រូវឲ្យថ្នាំលេប ចំនួន១០ម.ក្រ ឲ្យបាន៣០នាទី មុនពេលដាក់ឆ្អឹងបាក់ចំពោះមនុស្សធំ។

# សម្រាប់ការធ្លាក់ឈាមខ្លាំង ក្រោយសម្រាល

សម្រាប់ព័ត៌មានស្តីពីការប្រើថ្នាំត្រឹមត្រូវនិងមិនត្រឹមត្រូវ ក្នុងការបញ្ឈប់ការធ្លាក់ឈាមក្រោយសម្រាល សូមមើលទំ.២៦៦។ តាមក្បួនទូទៅ **គួរប្រើតែថ្នាំOxytocics (Ergonovine, Oxytocin ។ល។) ប៉ុណ្ណោះក្នុងការបញ្ឈប់ការធ្លាក់ឈាមក្រោយសម្រាល។** ការប្រើថ្នាំនេះដើម្បីជួយបង្កើនល្បឿនសម្រាល ឬផ្តល់កម្លាំងឲ្យម្តាយក្នុងពេលសម្រាល អាចបណ្តាលឲ្យមានគ្រោះថ្នាក់ទាំងម្តាយនិងទារក។ ថ្នាំទាំងនេះមិនគួរប្រើទេ កាលណាទារកមិនទាន់កើត ឬបើសុកមិនទាន់ធ្លាក់អស់។ ប្រសិនបើមានឈាមធ្លាក់ច្រើន មុននឹងសុកធ្លាក់ (ប៉ុន្តែក្រោយកូនកើតរួច) គេអាចឲ្យOxytocin១/២ម.ល (៥អ៊ុយនីតេ) ដោយការចាក់តាមសាច់ដុំ ។ **មិនត្រូវប្រើErgonovineទេ មុនសុកធ្លាក់** ព្រោះវាអាចរាំងមិនឲ្យធ្លាក់ទៅវិញទេ។

**ពីទូអ៊ីទ្រីន** ក៏ប្រហាក់ប្រហែលនឹងOxytocinដែរ ប៉ុន្តែវាមានគ្រោះថ្នាក់ច្រើនជាង ហើយមិនត្រូវប្រើទេ លើកលែងតែក្នុងករណីធ្លាក់ឈាមខ្លាំង កាលណាគេរកOxytocin និង Ergonovine មិនបាន។

ចំពោះការធ្លាក់ឈាមនៃទារកទើបកើត ចូរប្រើ**វីតាមីនកា** (មើលទំ.៣៩៤)។ មិនត្រូវប្រើវីតាមីនកា ជាមួយស្ត្រីដែលធ្លាក់ឈាមពេលសម្រាល រលូតកូន ឬការរំលូតកូនទេ។

Ergonovine ឬ Ergometrine maleate *(Ergotrate, Methergine)*

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា :

អំពូលសម្រាប់ចាក់ ០,២ម.ក្រក្នុង១ម.ល

តម្លៃ_______សម្រាប់_____

ថ្នាំគ្រាប់ ០,២ម.ក្រ តម្លៃ_______សម្រាប់_____

សម្រាប់បង្ការ ឬបញ្ឈប់ការហូរឈាម**ក្រោយពេលដែល**សុកបានធ្លាក់។

***កម្រិតប្រើ*** Ergonovineចាក់ :

ចំពោះការធ្លាក់ឈាមខ្លាំង (លើសពី២ពែង) ក្រោយពេលសុកបានធ្លាក់ ចូរចាក់តាមសាច់ដុំនូវErgonovine ១ឬ២អំពូល (០,២ទៅ០,៤ម.ក្រ) (ឬក្នុងករណីបន្ទាន់ជាខ្លាំង អាចចាក់តាមសរសៃ ១អំពូល)។ ប្រសិនបើចាំបាច់ អាចឲ្យម្តងទៀតបាន ក្នុងរយៈពេលកន្លះ ឬ១ម៉ោងក្រោយ។ ត្រូវប្តូរទៅប្រើ Ergonovineជាថ្នាំគ្រាប់ភ្លាមៗ នៅពេលអាចបញ្ឈប់ការហូរឈាមបាន។

***កម្រិតប្រើ*** Ergonovineជាថ្នាំលេប, ប្រើគ្រាប់ ០,២ម.ក្រ :

ដើម្បីបង្ការការធ្លាក់ឈាមខ្លាំងនៅពេលសម្រាលកូនរួច ឬដើម្បីកាត់បន្ថយបរិមាណឈាមដែលធ្លាក់ (ជាពិសេសចំពោះមាតាដែលមានភាពស្លេកស្លាំង) ចូរឲ្យ ១គ្រាប់ ៣ឬ៤ដងក្នុង ១ថ្ងៃ ដោយចាប់ផ្តើមឲ្យនៅពេលសុកធ្លាក់ហើយ។ ប្រសិនបើឈាមធ្លាក់ធ្ងន់ធ្ងរ អាចឲ្យថ្នាំ២គ្រាប់ក្នុងកម្រិតនីមួយៗ។

Oxytocin *(Pitocin)*

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : អំពូល១០អ៊ុយនីតេ ក្នុង១ម.ល

ដើម្បីជួយបញ្ឈប់ការធ្លាក់ឈាមធ្ងន់ធ្ងរ**ក្រោយពេល**សម្រាលរួច និង**មុនពេល**សុកធ្លាក់។ (អាចជួយឲ្យសុកឆាប់ធ្លាក់ផងដែរ ប៉ុន្តែមិនគួរប្រើក្នុងគោលបំណងនេះទេ លើកលែងតែមានធ្លាក់ឈាមធ្ងន់ធ្ងរ ឬមានការពន្យារពេលយូរ)។

***កម្រិតប្រើ*** Oxytocinសម្រាប់មាតាដែលបានសម្រាលកូនរួច :

ត្រូវចាក់ ១/២ម.ល (៥អ៊ុយនីតេ)។ បើឈាមមាននៅធ្លាក់ធ្ងន់ធ្ងរទៀត ត្រូវចាក់ ១/២ម.លទៀត នៅ១៥នាទីបន្ទាប់។

## សម្រាប់ឫសដូងបាត

**ថ្នាំសុលសម្រាប់ជំងឺឫសដូងបាត**

ឈ្មោះ______________តម្លៃ________សម្រាប់______

វាជាថ្នាំមានរាងដូចគ្រាប់កាំភ្លើង សម្រាប់សុលតាមរន្ធគូថ។ វាជួយធ្វើឲ្យឫសដូងបាតរួមតូច និងបន្ថយការឈឺចាប់។ ថ្នាំទាំងនេះមានច្រើនយ៉ាង។ ថ្នាំដែលមានប្រសិទ្ធិភាពបំផុត ប៉ុន្តែមានតម្លៃថ្លៃ មានជាតិcortisone ឬ cortico-steroid។ ក៏មានជាថ្នាំក្រមួនពិសេសម្យ៉ាងដែរ។ របបអាហារដើម្បីបន្ទន់លាមក ក៏ជាការសំខាន់ដែរ (មើលទំ.១២៦)។

***កម្រិតប្រើ :***

ចូរសុលតាមគូថឲ្យជ្រៅរៀងរាល់ថ្ងៃ បន្ទាប់ពីបត់ជើងរួច និងម្តងទៀតនៅពេលចូលដេក។

## សម្រាប់កង្វះអាហារូបត្ថម្ភ និងភាពស្លេកស្លាំង

**ទឹកដោះគោម្សៅ**

ឈ្មោះ______________តម្លៃ________សម្រាប់______

សម្រាប់ទារក **ទឹកដោះម្តាយល្អជាងអ្វីទាំងអស់។** ទឹកដោះម្តាយសំបូរទៅដោយវីតាមីននិងរ៉ែស្ថាបនារាងកាយ ។ នៅពេលដែលមិនមានទឹកដោះម្តាយសម្រាប់ទារកបៅទេ អាចប្រើផលិតផលទឹកដោះផ្សេងទៀតបាន ដូចជាទឹកដោះគោម្សៅជាដើម។ ដើម្បីឲ្យទារកទទួលបានប្រយោជន៍ពេញលេញពីអាហាររបស់វា គួរលាយម្សៅទឹកដោះគោជាមួយស្ករ និងប្រេងដាំស្លបន្តិច (មើលទំ.១២០)។

ក្នុងទឹកឆ្អិន ១ពែង លាយ :

ទឹកដោះគោម្សៅ ១២ស្លាបព្រាកាហ្វេ
ស្ករ ២ស្លាបព្រាកាហ្វេ
ប្រេងដាំស្ល ៣ស្លាបព្រាកាហ្វេ

**វីតាមីនចំរុះ**

ឈ្មោះ______________តម្លៃ________សម្រាប់______

ថ្នាំទាំងនេះមានច្រើនទម្រង់ ប៉ុន្តែតាមធម្មតាថ្នាំគ្រាប់មានតម្លៃថោកជាង និងមានប្រសិទ្ធភាពល្អ។ ថ្នាំវីតាមីនចាក់ មិនសូវជាចាំបាច់ទេ គឺខ្ជះខ្ជាយប្រាក់កាស អាចបណ្តាលឲ្យឈឺចាប់ឥតអំពើ និងជួនកាលកើតអាប់សែ។ ថ្នាំទឹកលើកកំលាំងមិនសូវជាមានវីតាមីនសំខាន់អីទេ ហើយជាទូទៅមានតម្លៃថ្លៃពេកលើសអ្វីដែលវាមានប្រយោជន៍ទៅទៀត។

**អាហារចិញ្ចឹមរាងកាយ គឺជាប្រភពដ៏សំខាន់បំផុតនៃវីតាមីន។** ប្រសិនបើត្រូវការវីតាមីនបន្ថែម គួរប្រើថ្នាំវីតាមីនគ្រាប់។

ក្នុងករណីខ្លះនៃកង្វះអាហារូបត្ថម្ភ វីតាមីនអាចជួយបាន។ ត្រូវប្រាកដថាថ្នាំដែលប្រើនោះមានជាតិវីតាមីនដែលអ្នកលេបត្រូវការ (មើលទំ.១១៨)។

ជាធម្មតាការប្រើថ្នាំវីតាមីនចំរុះ ១គ្រាប់ក្នុង១ថ្ងៃ គឺជាការគ្រប់គ្រាន់។

**វីតាមីនអា (retinol)** សម្រាប់ខ្វាក់មាន់ និងភ្នែកស្ងួត

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ២០០.០០០អ៊ុយនីតេ, ៦០ម.ក្រ retinol (ក៏មានកម្រិតខ្សោយដែរ)

ថ្នាំចាក់ ១០០.០០០អ៊ុយនីតេ

***ប្រយ័ត្ន :*** ការប្រើវីតាមីនអា ច្រើនពេក អាចធ្វើឲ្យប្រកាច់។ មិនត្រូវប្រើច្រើនពេកទេ ហើយទុកដាក់វាឲ្យឆ្ងាយពីដៃកុមារ។

***សម្រាប់ការបង្ការ :*** នៅតំបន់ដែលឧស្សាហ៍មានកុមារកើតខ្វាក់មាន់ និងភ្នែកស្ងួត ពួកគេគួរហូបផ្លែឈើពណ៌លឿង និងបន្លែដែលមានស្លឹកពណ៌បៃតងចាស់ ក៏ដូចជាសាច់សត្វ ស៊ុត និងថ្លើមផងដែរ។ ប្រេងថ្លើមត្រី សំបូរទៅដោយវីតាមីនអា។ ឬអាចប្រើថ្នាំគ្រាប់វីតាមីនអា។ ឲ្យ១គ្រាប់ រៀងរាល់៤ទៅ៦ខែម្តង សម្រាប់ការបង្ការ មិនត្រូវឲ្យលើសពីនេះទេ។

ម្តាយអាចជួយបង្ការបញ្ហាភ្នែកកុំឲ្យកើតលើកូនរបស់គាត់បាន ដោយលេបថ្នាំគ្រាប់វីតាមីនអា ១គ្រាប់(២០០.០០០អ៊ុយនីតេ) នៅពេលដែលទារកកើតរួច ឬក្នុងអំឡុងពេល១ខែក្រោយសម្រាល។

កុមារដែលមានជំងឺកញ្ជ្រឹល មានការប្រឈមនឹងជំងឺភ្នែកស្ងួតខ្ពស់ ហើយគួរឲ្យវីតាមីនអា នៅពេលដែលចាប់មានកញ្ជ្រឹល។

នៅតំបន់ដែលកុមារមិនបានទទួលវីតាមីនអាគ្រប់គ្រាន់ ការឲ្យអាហារ ឬថ្នាំគ្រាប់វីតាមីនអាបន្ថែម នឹងជួយឲ្យកុមាររួចផុតពីជំងឺកញ្ជ្រឹល និងជំងឺធ្ងន់ធ្ងរផ្សេងៗទៀត។

***សម្រាប់ការព្យាបាល :*** ឲ្យថ្នាំគ្រាប់វីតាមីនអា ១គ្រាប់ (២០០.០០០អ៊ុយនីតេ) សម្រាប់លេប ឬ ១០០.០០អ៊ុយនីតេ សម្រាប់ចាក់។ ថ្ងៃបន្ទាប់ ឲ្យលេបថ្នាំគ្រាប់វីតាមីនអា ១គ្រាប់ទៀត ហើយនិង១គ្រាប់ចុងក្រោយ នៅ១ទៅ២សប្តាហ៍ក្រោយទៅទៀត។

ចំពោះកុមារអាយុក្រោម ១ឆ្នាំ ត្រូវបន្ថយកម្រិតប្រើពាក់កណ្តាល។

**<u>ជាតិដែក</u>** សម្រាប់ភាពស្លេកស្លាំង

ឈ្មោះ:______________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ២០០, ៣០០, ឬ ៥០០ម.ក្រ (ក៏មានជាថ្នាំបន្តក់ និងថ្នាំទឹក សម្រាប់កុមារ)

ជាតិដែកមានប្រយោជន៍ក្នុងការព្យាបាល ឬបង្ការភាពស្លេកស្លាំងសឹងតែទាំងអស់។ ជាធម្មតា ការព្យាបាលដោយថ្នាំគ្រាប់ជាតិដែក ត្រូវប្រើពេលវេលាយ៉ាងតិច៣ខែ។ ប្រសិនបើមិនមានការធូរស្រាលទេ ភាពស្លេកស្លាំងប្រហែលជាបណ្តាលមកពីបញ្ហាផ្សេងទៀត ក្រៅពីកង្វះជាតិដែក។ សូមរកជំនួយពីគ្រូពេទ្យ។ ប្រសិនបើពិបាករក ចូរសាកល្បងប្រើFolic acid។

ជាតិដែកមានប្រយោជន៍ជាពិសេស ចំពោះស្ត្រីមានផ្ទៃពោះ ដែលអាចមានភាពស្លេកស្លាំង ឬខ្វះអាហារូបត្ថម្ភ។

ជាតិដែកអាចធ្វើការបានប្រសើរបំផុត ប្រសិនបើប្រើជាមួយវីតាមីនសេ (អាចជាផ្លែឈើ និងបន្លែ ឬថ្នាំវីតាមីនគ្រាប់សេ)។

ជាតិដែកជួនកាលធ្វើទុក្ខក្រពះ ដូច្នេះយកល្អត្រូវលេបពេលហូបបាយ។ វាក៏អាចបណ្តាលឲ្យមានការទល់លាមកផងដែរ ហើយវាអាចធ្វើឲ្យលាមកមានពណ៌ខ្មៅ។ ចំពោះកុមារអាយុក្រោម ៣ឆ្នាំ សូមកិនថ្នាំមួយបំណែកនៃថ្នាំ១គ្រាប់ ឲ្យម៉ត់ ហើយលាយជាមួយបាយ។

***ប្រយ័ត្ន :*** ត្រូវប្រាកដថាបានប្រើតាមកម្រិតត្រឹមត្រូវ។ ការប្រើជាតិដែកច្រើនពេកអាចធ្វើឲ្យពុល។ ទុកដាក់ថ្នាំឲ្យផុតពីដៃកុមារ។ សូមកុំឲ្យថ្នាំជាតិដែកទៅអ្នកដែលមានកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។

***កម្រិតប្រើ*** ជាតិដែក សម្រាប់ភាពស្លេកស្លាំង : ប្រើថ្នាំគ្រាប់ ២០០ម.ក្រ

ប្រើ ៣ដង ក្នុង១ថ្ងៃ ជាមួយបាយ

ក្នុងកម្រិតនីមួយៗ ឲ្យ :

- មនុស្សធំ : ២០០ ទៅ៤០០ម.ក្រ (១ ឬ២គ្រាប់)
- កុមារអាយុលើស៦ឆ្នាំ : ២០០ម.ក្រ (១គ្រាប់)
- កុមារអាយុ៣-៦ឆ្នាំ : ១០០ម.ក្រ (១/២គ្រាប់)
- កុមារអាយុក្រោម៣ឆ្នាំ : ២៥ ទៅ៥០ម.ក្រ (១/៨ ទៅ ១/៤គ្រាប់) កិនឲ្យម៉ត់ រួចលាយជាមួយបាយ

<u>Folic acid</u> សម្រាប់ភាពស្លេកស្លាំងប្រភេទខ្លះ

ឈ្មោះ:______________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ៥ម.ក្រ

Folic acid អាចមានសារសំខាន់សម្រាប់ព្យាបាលភាពស្លេកស្លាំងប្រភេទខ្លះ ដែលគោលិកាឈាមត្រូវបានបំផ្លាញនៅក្នុងសរសៃវ៉ែន ដូចក្នុងករណីជំងឺគ្រុនចាញ់។ អ្នកជំងឺដែលធ្លាក់អណ្តើក ឬកើតលឿង អាចត្រូវការព្យាបាលដោយFolic acid ជាពិសេសប្រសិនបើភាពស្លេកស្លាំងរបស់គាត់ មិនបានធូរស្រាលដោយជាតិដែកទេ។ ជាញឹកញាប់ ទារកដែលបំបៅដោយទឹកដោះពពែ និងស្ត្រីមានផ្ទៃពោះដែលមានភាពស្លេកស្លាំង ឬខ្វះអាហារូបត្ថម្ភ ត្រូវការទាំងFolic acid និងជាតិដែក។

Folic acid អាចទទួលបានដោយការទទួលទានបន្លែស្លឹកពណ៌បៃតងចាស់ សាច់ និងថ្លើម ឬដោយការលេបថ្នាំគ្រាប់ Folic acid។ តាមធម្មតាគេព្យាបាលកុមារតែក្នុងរយៈពេល ២សប្តាហ៍ គឺគ្រប់គ្រាន់ តែក្នុងករណីកុមារមានកើតភាពស្លេកស្លាំងម្យ៉ាង ហៅថា តាឡាសេមី គេត្រូវព្យាបាលរយៈពេលច្រើនឆ្នាំ។ ចំពោះស្ត្រីមានផ្ទៃពោះដែលមានភាពស្លេកស្លាំង និងខ្វះអាហារូបត្ថម្ភ គួរលេបFolic acid និងថ្នាំគ្រាប់ជាតិដែក រាល់ថ្ងៃ ក្នុងអំឡុងពេលមានផ្ទៃពោះ។

***កម្រិតប្រើ*** Folic acid សម្រាប់ភាពស្លេកស្លាំង : ប្រើថ្នាំគ្រាប់ ៥ម.ក្រ

លេប ១ដង ក្នុង១ថ្ងៃ

- មនុស្សធំនិងកុមារអាយុលើស៣ឆ្នាំ : ១គ្រាប់ (៥ម.ក្រ)
- កុមារអាយុក្រោម៣ឆ្នាំ : ១/២គ្រាប់ (២ ១/២ម.ក្រ)

**<u>វីតាមីនបេ១២ (cyanocobalamin)</u>** សម្រាប់ភាពស្លេកស្លាំងធ្ងន់ធ្ងរប៉ុណ្ណោះ

យើងនិយាយពីវីតាមីនបេ១២ នៅទីនេះ គឺគ្រាន់តែមិនចង់ឲ្យប្រើវាប៉ុណ្ណោះ។ វីតាមីនបេ១២ មានប្រយោជន៍តែចំពោះភាពស្លេកស្លាំងដ៏កម្រមានមួយប្រភេទ ដែលស្ទើរតែរកគ្មានលើកលែងតែអ្នកនោះអាយុលើស ៣៥ឆ្នាំ ហើយដែលបុព្វបុរសរបស់គាត់ចេញពីប្រទេសអឺរ៉ុបភាគខាងជើងមក។ មានគ្រូពេទ្យជាច្រើនបានបង្គាប់ឲ្យទិញថ្នាំនេះ ដែលវាមិនចាំបាច់សោះ គឺគ្រាន់តែឲ្យដើម្បីឲ្យតែបាន។ **សូមកុំចំណាយប្រាក់របស់អ្នកទៅលើវីតាមីនបេ១២** ឬកុំទទួលថ្នាំនេះ ប្រសិនបើគ្រូពេទ្យ ឬបុគ្គលិកសុខាភិបាលឲ្យថ្នាំនេះមកអ្នក លុះត្រាតែលទ្ធផលឈាមបញ្ជាក់ថា អ្នកពិតជាមានជំងឺនេះមែន។

**<u>វីតាមីនកា ( phytomenadione, phytonadione )</u>**

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : អំពូល ១ម.ក្រក្នុង២,៥ម.ល នៃថ្នាំទឹកពណ៌ដូចទឹកដោះគោ។

បើទារកទើបកើតមានហូរឈាមត្រង់កន្លែងណាមួយនៃរាងកាយ (មាត់ ផ្ចិត គូថ) នេះប្រហែលជាបណ្ដាលមកពីកង្វះវីតាមីនកា។ ចូរចាក់វីតាមីនកា ១ម.ក្រ (១អំពូល) នៅផ្នែកចំហៀងភ្លៅ។ មិនត្រូវចាក់ថែមទៀតទេ ទោះបីជាឈាមនៅតែមានចេញក៏ដោយ។ ចំពោះទារកដែលកើតមកមានរាងកាយតូច (ទម្ងន់តិចជាង ២គ.ក្រ) ការចាក់វីតាមីនកា ១ម្ជុល អាចបន្ថយការប្រឈមនឹងការឈាមហូរបាន។

វីតាមីនកាគ្មានប្រសិទ្ធភាពក្នុងការបញ្ឈប់ការហូរឈាមចំពោះស្ត្រីទើបសម្រាលទេ។

**<u>វីតាមីនបេ៦ ( pyridoxine )</u>**

ឈ្មោះ______________តម្លៃ________សម្រាប់______

ច្រើនមានជា : ថ្នាំគ្រាប់ ២៥ម.ក្រ

អ្នកជំងឺរបេងដែលកំពុងព្យាបាលដោយ**Isoniazid** ជួនកាលបណ្ដាលឲ្យមានកង្វះវីតាមីនបេ៦។ ដើម្បីបង្ការបញ្ហានេះ គេគួរឲ្យវីតាមីនបេ៦ ៥០ម.ក្ររៀងរាល់ថ្ងៃ ជាមួយគ្នាពេលកំពុងប្រើIsoniazid។ ឬអាចឲ្យតែចំពោះអ្នកជំងឺណាដែលមានកង្វះវីតាមីននេះប៉ុណ្ណោះ។ រោគសញ្ញាមានដូចជា ចុកចាប់ រោយស្រពន់ដៃជើង រមួលសាច់ដុំ រសាប់រសល់ និងដេកមិនលក់។

***កម្រិតប្រើ***វីតាមីនបេ៦ ក្នុងពេលប្រើIsoniazid :

ប្រើថ្នាំគ្រាប់ ២៥ម.ក្រ ២គ្រាប់ រាល់ថ្ងៃ។

## សម្រាប់ផែនការគ្រួសារ

**<u>ថ្នាំគ្រាប់ពន្យារកំណើត</u>**

ព័ត៌មានអំពីការប្រើ គ្រោះថ្នាក់ និងការប្រុងប្រយ័ត្ន ចំពោះថ្នាំគ្រាប់ពន្យារកំណើត អាចរកបាននៅទំ.២៨៦ ទៅ២៨៩។ ព័ត៌មានបន្តបន្ទាប់នេះ និយាយអំពីការជ្រើសរើសថ្នាំលេបដែលកបសម្រាប់ស្ត្រីម្នាក់ៗ។ (ក្នុងឆ្នាំ២០០២ ខែមករា យើងបានកែប្រែក្រុមថ្នាំគ្រាប់ពន្យារកំណើត នៅក្នុងផ្នែកនេះ។ ប្រសិនបើនរណាម្នាក់ធ្វើការជាមួយអ្នក ប្រើសៀវភៅបោះពុម្ពលើកមុន ត្រូវប្រយ័ត្នកុំឲ្យច្រឡំប្រភេទថ្នាំឲ្យសោះ!)

ថ្នាំគ្រាប់ពន្យារកំណើតភាគច្រើន មានជាតិអ័រម៉ូន២យ៉ាងដូចគ្នានឹងអ័រម៉ូនក្នុងខ្លួនស្ត្រីដែលបញ្ឈប់ការហូរឈាមពេលមានរដូវដែរ។ អ័រម៉ូនទាំងនេះ ហៅថាestrogen និង progesterone(progestin)។

ថ្នាំគ្រាប់ទាំងនេះមានម៉ាកផ្សេងៗគ្នាជាច្រើន ហើយកំលាំងនិងជាតុផ្សំរវាងអ័រម៉ូនទាំង២ ក៏ខុសគ្នាដែរ។ ម៉ាកថ្នាំមួយចំនួនប៉ុណ្ណោះដែលមានរៀបរាប់ក្នុងក្រុមដូចខាងក្រោម។

ជាធម្មតា ថ្នាំដែលមានជាតិអ័រម៉ូនទាំង២តិច គឺមានសុវត្ថិភាពបំផុត ហើយមានប្រសិទ្ធភាពបំផុតចំពោះស្ត្រីភាគច្រើន។ ថ្នាំគ្រាប់ "កម្រិតស្រាល" ទាំងនេះ អាចរកឃើញក្នុងក្រុម ១, ២ និង ៣។

**ក្រុម ១ - ថ្នាំគ្រាប់Triphasic**

ថ្នាំទាំងនេះមានជាតិestrogen និងprogestin តិចដូចគ្នា ហើយបរិមាណអ័រម៉ូនទាំងពីរផ្លាស់ប្ដូរជានិច្ច ពេញ១ខែ។ ដោយសារបរិមាណផ្លាស់ប្ដូរ ជាការសំខាន់គឺត្រូវលេបថ្នាំតាមលំដាប់។

ម៉ាកដែលស្គាល់ច្រើន :

*Trinordiol*

**ក្រុម ២ - ថ្នាំគ្រាប់កម្រិតស្រាល**

ថ្នាំទាំងនេះមានជាតិestrogen (estrogen ៣៥មីក្រូក្រាម "ethinyl estradiol" ឬestrogen ៥០មីក្រូក្រាម "mestranol") និងជាតិprogestinផ្សំគ្នា ក្នុងបរិមាណទាប ដែលបរិមាណនេះមិនប្រែប្រួលទេ ក្នុងពេល១ខែ។

ម៉ាកដែលស្គាល់ច្រើន :

*Brevicon 1+35*    *Diane*

**ក្រុម ៣ - ថ្នាំគ្រាប់កម្រិតស្រាល**

ថ្នាំទាំងនេះមានជាតិprogestinខ្ពស់ និងestrogenទាប (៣០ ឬ៣៥មីក្រូក្រាមនៃestrogen "ethinyl estradiol")។

ម៉ាកដែលស្គាល់ច្រើន :

*Microgynon 30*
*OK*
*ស្រីពេជ្រ*
*Jasmine*
*COC*

ដើម្បីកាត់បន្ថយការធ្លាក់ឈាមក្នុងបរិមាណតិចតួចនៅពេលណាផ្សេងពីពេលធ្លាក់ឈាមរដូវ សូមលេបថ្នាំឲ្យទៀងទាត់ពេលវេលារាល់ថ្ងៃ ជាពិសេសថ្នាំដែលមានជាតិអ័រម៉ូនតិច។ ប្រសិនបើមានការធ្លាក់ឈាមក្នុងបរិមាណតិចតួចនៅពេលណាផ្សេងពីពេលធ្លាក់ឈាមរដូវ ក្រោយពេលប្រើ៣ឬ៤ខែ សូមសាកល្បងប្រើថ្នាំម៉ាកផ្សេងទៀត ក្នុងក្រុម៣។ ប្រសិនបើនៅតែដដែល បន្ទាប់ពីបាន៣ខែ ចូរសាកល្បងថ្នាំក្នុងក្រុម៤។

តាមក្បួនទូទៅ ស្ត្រីដែលប្រើថ្នាំគ្រាប់ពន្យារកំណើត តែងមានឈាមរដូវតិច។ នេះអាចជារឿងល្អ ជាពិសេសចំពោះស្ត្រីដែលមានភាពស្លេកស្លាំង។ ប៉ុន្តែប្រសិនបើស្ត្រីបាត់រដូវច្រើនខែ ឬឈាមរដូវតិច គាត់អាចប្ដូរប្រើថ្នាំដែលមានជាតិestrogen ច្រើន នៅក្នុងក្រុម៤។

ចំពោះស្ត្រីដែលធ្លាក់ឈាមរដូវច្រើន ឬស្ត្រីដែលមានដោះឈឺ មុនពេលមានរដូវ ជាការប្រសើរគួរតែប្រើថ្នាំដែលមានជាតិ estrogenទាប ប៉ុន្តែមានជាតិprogestinខ្ពស់។ ថ្នាំទាំងនេះមាននៅក្នុងក្រុម៣។

ចំពោះស្ត្រីដែលនៅតែមានការធ្លាក់ឈាមក្នុងបរិមាណតិចតួចនៅពេលណាផ្សេងពីពេលធ្លាក់ឈាមរដូវ ឬបាត់រដូវពេលប្រើថ្នាំក្នុងក្រុម៣, ឬស្ត្រីដែលក្លាយជាមានផ្ទៃពោះពេលប្រើថ្នាំប្រភេទផ្សេងទៀត, អាចប្តូរប្រើថ្នាំដែលមានជាតិestrogen ច្រើនបន្តិច។ ថ្នាំកម្រិតខ្ពស់ទាំងនេះ មាននៅក្នុងក្រុម ៤។

### ក្រុម ៤ - ថ្នាំគ្រាប់កម្រិតខ្ពស់

ថ្នាំទាំងនេះមានជាតិestrogenខ្ពស់ ( "ethinyl estradiol" ៥0មីក្រូក្រាមនៃestrogen ) ហើយភាគច្រើនមានជាតិ progestinខ្ពស់ដែរ។

ម៉ាកដែលស្គាល់ច្រើន :

*Eugynon*

ប្រសិនបើប្រើថ្នាំក្នុងក្រុម ៤ហើយ នៅតែមានការធ្លាក់ឈាមក្នុងបរិមាណតិចតួចនៅពេលណាផ្សេងពីពេលធ្លាក់ឈាមរដូវ នោះថ្នាំ Ovulen និងDemulenជាញឹកញាប់អាចបញ្ឈប់វាបាន។ ប៉ុន្តែថ្នាំនេះមានជាតិestrogenខ្ពស់ខ្លាំងណាស់ ដូច្នេះវាមិនសូវបានណែនាំឲ្យប្រើទេ។ ថ្នាំទាំងនេះជួនកាលមានប្រយោជន៍ចំពោះស្ត្រីដែលមានកើតមុនធ្ងន់ធ្ងរ។

ស្ត្រីដែលមានបញ្ហាជាមួយនឹងការចាញ់កូន ឬផលរំខានផ្សេងទៀតក្រោយពេលប្រើថ្នាំពន្យារកំណើតបាន២ឬ៣ខែ, និងស្ត្រីដែលប្រឈមខ្ពស់នឹងកំណកឈាម គួរសាកល្បងប្រើថ្នាំគ្រាប់ពន្យារកំណើត Triphasic ដែលមានជាតិestrogen និង progestinទាប ដែលស្ថិតក្នុងក្រុម ១។

ចំពោះស្ត្រីបំបៅដោះកូន ឬស្ត្រីដែលមិនគួរប្រើថ្នាំទៀងទាត់ដោយសារឈឺក្បាល ឬសំពាធឈាមខ្ពស់កម្រិតស្រាល, គួរប្រើថ្នាំគ្រាប់ដែលមានតែជាតិ Progestin បានហើយ។ ថ្នាំទាំងនេះមាននៅក្នុងក្រុម ៥ ហើយជួនកាលហៅថា "ថ្នាំគ្រាប់តូចៗ"។

### ក្រុម ៥ - ថ្នាំគ្រាប់ដែលមានតែជាតិProgestin

ថ្នាំទាំងនេះ ជួនកាលហៅថា "ថ្នាំគ្រាប់តូចៗ" ដែលមានតែជាតិProgestinប៉ុណ្ណោះ។

ថ្នាំទាំងនេះគួរតែលេបឲ្យទៀងពេលរាល់ថ្ងៃ សូម្បីតែក្នុងពេលមានរដូវក៏ដោយ។ ការធ្លាក់រដូវមិនសូវជាទៀងទាត់ទេ។ ប្រសិនបើភ្លេចលេបថ្នាំនេះតែមួយគ្រាប់ ក៏អាចមានផ្ទៃពោះបានដែរ។

ម៉ាកដែលស្គាល់ច្រើន :

| | | |
|---|---|---|
| *POP* | *Microval* | *ថ្នាំនេះក៏អាចប្រើសម្រាប់ការពន្យារកំណើតបន្ទាន់បានដែរ, សូមមើលផ្នែកបន្ទាប់នេះ* |
| | *Ovrette* | |

## ផែនការគ្រួសារបន្ទាន់
## ( ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ )

ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ គឺជាថ្នាំគ្រាប់ពន្យារកំណើតកម្រិតពិសេសមួយ សម្រាប់ស្ត្រីដែលបានរួមភេទដោយមិនបានការពារ ហើយចង់ចៀសវាងពីការមានកូន។ ការប្រើថ្នាំគ្រាប់ពន្យារកំណើតបែបនេះ គឺមានសុវត្ថិភាព សូម្បីតែចំពោះស្ត្រីដែលមិនគួរប្រើថ្នាំគ្រប់ពេលក៏ដោយ។

***កំរិតប្រើ ៖*** ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ ត្រូវលេបក្នុងអំឡុងពេល ៥ថ្ងៃ បន្ទាប់ពីបានរួមភេទដោយមិនបានការពារ។ ប្រសិនបើអ្នកលេបថ្នាំគ្រាប់នេះបានកាន់តែឆាប់ក្រោយពីរួមភេទដោយមិនបាច់ការពារ នោះអ្នកកាន់តែមិនអាចមានកូនបាន។ សម្រាប់ការពន្យារកំណើតបន្ទាន់ ចូរអនុវត្តតាមសេចក្តីណែនាំខាងក្រោមដោយប្រុងប្រយ័ត្ន :

> លេបថ្នាំគ្រាប់ពន្យារកំណើត "កម្រិតខ្ពស់" នៅក្នុងក្រុម៤ ចំនួន ២គ្រាប់ ក្នុងអំឡុងពេល៥ថ្ងៃបន្ទាន់ពីបានរួមភេទដោយមិនបានការពារ បន្ទាប់មកលេបថ្នាំនៅក្នុងក្រុម៤ ចំនួន២គ្រាប់ទៀត នៅ១២ម៉ោងបន្ទាប់។
>
> **ឬ**
>
> លេបថ្នាំគ្រាប់ពន្យារកំណើត "កម្រិតទាប" ក្នុងក្រុម២ ឬក្រុម ៣ ចំនួន ៤គ្រាប់ ក្នុងអំឡុងពេល៥ថ្ងៃ បន្ទាប់ពីបានរួមភេទដោយមិនបានការពារ បន្ទាប់មកលេបថ្នាំក្នុងក្រុម២ឬក្រុម៣ ចំនួន ៤គ្រាប់ទៀត នៅ១២ម៉ោងបន្ទាប់។
>
> **ឬ**
>
> លេប "ថ្នាំគ្រាប់តូចៗ" ឬថ្នាំគ្រាប់progestinសុទ្ធ ក្នុងក្រុម៥ ចំនួន ២៥គ្រាប់ ដែលមានកម្រិតprogestin 0,0៣ម.ក្រ ហៅថា levonorgestrel ក្នុងអំឡុងពេល៥ថ្ងៃបន្ទាប់ពេលបានរួមភេទដោយមិនបានការពារ បន្ទាប់មក លេបថ្នាំដដែល ចំនួន២៥គ្រាប់ទៀត នៅ១២ម៉ោងបន្ទាប់។
>
> **ឬ**
>
> លេបថ្នាំOvrette ឬថ្នាំគ្រាប់តូចៗផ្សេងទៀតដែលមាន levonorgestrel 0.0៣៧៥ មក្រ ចំនួន ២0គ្រាប់ ក្នុងអំឡុងពេល៥ថ្ងៃបន្ទាប់ពីបានរួមភេទដោយមិនបានការពារ បន្ទាប់មកលេបថ្នាំដដែលនេះ ២0គ្រាប់ទៀត នៅ១២ម៉ោងបន្ទាប់។

ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ថ្មីៗត្រូវបានបង្កើតឡើង គ្រាន់តែសម្រាប់ការពន្យារកំណើតភ្លាមៗប៉ុណ្ណោះ ហើយអាចរកទិញបានក្នុងតំបន់របស់អ្នក។ ឈ្មោះថ្នាំមួយចំនួននោះរួមមាន ៖ ***Norlevo, Postinor-2*** ។ ឧទាហរណ៍ ដូចជា ការប្រើ ***Postinor-2*** ដែលមានតែជាតិprogestin អ្នកលេបចំនួន ១គ្រាប់ ក្នុងអំឡុងពេល៥ថ្ងៃបន្ទាប់ពីបានរួមភេទដោយមិនបានការពារ បន្ទាប់មកលេប១គ្រាប់ទៀតនៅ១២ម៉ោងបន្ទាន់។

***ផលរំខាន ៖*** តិចជាងពាក់កណ្តាលនៃស្ត្រីដែលប្រើប្រាស់ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ មានចង្អោរ ឬក្អួត។ ប្រសិនបើមានក្អួត ក្នុងអំឡុងពេល៣ម៉ោងបន្ទាប់ពីលេបថ្នាំ ត្រូវលេបថែមមួយដងទៀត។ ប្រសិនបើអ្នកមានបញ្ហាក្អួត អ្នកអាចលេបថ្នាំ Promethazine ក្នុងកម្រិត ២៥មក្រ ២ដង ក្នុងមួយថ្ងៃ។ ឬជំនួសឲ្យការលេបថ្នាំពន្យារកំណើតបន្ទាន់តាមមាត់ អ្នកអាចសុលវាតាមទ្វារមាស។ វិធីនេះ ក៏មានប្រសិទ្ធិភាពល្អដូចគ្នាក្នុងការបង្ការកុំឲ្យមានផ្ទៃពោះ។ការធ្វើរបៀបនេះ មិនមែនបង្ការមិនឲ្យមានផលរំខានដូចជាចង្អោរ ឬក្អួតនោះទេ តែវាអាចការពារមិនឲ្យក្អួតថ្នាំចេញមក។

ថ្នាំគ្រាប់ដែលមានតែជាតិprogestin ធ្វើឲ្យមានការចង្អោរ និងក្អួតតិចតួចជាងការប្រើថ្នាំគ្រាប់ដែលផ្សំគ្នា។ ស្ត្រីដែលមានជំងឺបេះដូង ជំងឺកំណកឈាម ឬដាច់សរសៃឈាមខួរក្បាល គួរប្រើថ្នាំ គ្រាប់ដែលមានតែprogestinបានហើយ។

**ស្រោមអនាម័យ**

ឈ្មោះ:___________________តម្លៃ______សម្រាប់______

ច្រើនមានជា : កញ្ចប់ដែលមានស្រោមអនាម័យចំនួន ៣។

ស្រោមអនាម័យម៉ាកខុសៗគ្នាជាច្រើន។ ស្រោមអនាម័យមួយចំនួន មានជាតិរំអិល ខ្លះមានពណ៌ខុសៗគ្នា និងមួយចំនួនទៀត មានថ្នាំសម្លាប់មេជីវិតឈ្មោល។

បន្ថែមលើការបង្ការមិនឲ្យមានផ្ទៃពោះ ស្រោមអនាម័យក៏អាចជួយបង្ការការឆ្លងរោលដាលនៃជំងឺកាមរោគផងដែរ ដូចជាមេរោគអេដស៍/ជំងឺអេដស៍។ មនុស្សជាច្រើន ប្រើស្រោមអនាម័យជាមួយនឹងថ្នាំគ្រាប់ពន្យារកំណើតក្នុងទំរង់ណាមួយទៀត។

ការប្រើប្រាស់ និងការថែទាំស្រោមអនាម័យ ត្រូវបានរៀបរាប់នៅទំព័រ ២៩០។

**ដ្យ៉ាហ្វ្រាម**

ឈ្មោះ:__________តម្លៃ_____សម្រាប់_____

ដ្យ៉ាហ្វ្រាម មានប្រសិទ្ធិភាពបំផុតនៅពេលប្រើជាមួយក្រែមលាប ឬចាហ៊ួយសម្លាប់មេជីវិត។ ចូរលាបក្នុងដ្យ៉ាហ្វ្រាម ហើយលាប ទៅលើគែមដ្យ៉ាហ្វ្រាមផងដែរ មុនពេលសិកវាបញ្ចូលក្នុងទ្វារមាស (ចូរអានទំព័រ ២៩០)។

ឈ្មោះចាហ៊ួយឬក្រែមលាប :____________តម្លៃ_____

**ថ្នាំពពុះពន្យារកំណើត** (ម៉ាកល្បី ៖ *Emko, Lempko, Delfen*)

ឈ្មោះ:__________________________តម្លៃ________

ចំពោះការពិភាក្សាពីការប្រើប្រាស់ថ្នាំពពុះនេះ សូមអានទំ.២៩០។

**ថ្នាំសុលពន្យារកំណើត**

(ម៉ាកដែលគេនិយមប្រើ ៖ *Neo Sampoon*)

ឈ្មោះ:__________________________តម្លៃ________

វាគឺជាប្រភេទថ្នាំគ្រាប់ដែលមានផ្ទុកជាតិសម្លាប់មេជីវិត ដែលស្ត្រីសុលវាបញ្ចូលឲ្យជ្រៅទៅក្នុងទ្វាមាស នៅជិតកស្បូន។ ថ្នាំនេះ គួរសុលឲ្យបាន ១៥នាទី មុនពេលរួមភេទ។ (ចូរធ្វើតាមការណែនាំដែលមាននៅលើកញ្ចប់)។ វាគឺជាមធ្យោបាយពន្យារកំណើតដែលមានប្រសិទ្ធភាពគួរសម ជាពិសេសប្រសិនបើប្ដីប្រពន្ធប្រើស្រោមអនាម័យបន្ថែម។

**កងដាក់ក្នុងស្បូន**

ឈ្មោះ:__________________________តម្លៃ________

ប្រាក់ឈ្នួលសម្រាប់ការដាក់កង:___________________

កងដាក់ក្នុងស្បូន ត្រូវតែសិកចូល និងដកចេញ ដោយបុគ្គលិកសុខាភិបាលដែលទទួលការហាត់រៀន។ ផលរំខានដែលកើតឡើងញឹកញាប់បំផុតគឺ ការមករដូវរយៈពេលយូរ ឈឺចាប់ និងច្រើនជាងធម្មតា ប៉ុន្តែវានឹងបាត់ទៅវិញបន្ទាប់ពីដាក់បានរយៈពេល ៣ខែដំបូង។ ករណីកម្រ កងដាក់ក្នុងស្បូនអាចរអិលចេញពីកន្លែងរបស់វា។ ប្រសិនបើមានហេតុការណ៍នេះកើតឡើង វានឹងមិនមានប្រសិទ្ធភាពក្នុងការបង្ការកុំឲ្យមានផ្ទៃពោះទេ ដូចនេះ វាជាការសំខាន់សម្រាប់ស្ត្រីប្រើកងក្នុងស្បូន ចេះពិនិត្យមើលឲ្យដឹងថាវាស្ថិតនៅចំកន្លែងដដែលឬអត់។ កងដាក់ក្នុងស្បូនភាគច្រើនមានសរសៃដូចខ្សែ២ភ្ជាប់ជាមួយ ដែលសំយ៉ុងចុះទៅក្នុងទ្វារមាស។ ស្ត្រីគួរពិនិត្យមើលខ្សែទាំងពីរនោះ នៅរាល់ពេលផ្តាច់ឈាមរដូវរួច។ ដើម្បីពិនិត្យមើលខ្សែនោះ ស្ត្រីត្រូវលាងដៃឲ្យស្អាត បន្ទាប់មកលូកម្រាមដៃពីរចូលទៅក្នុងទ្វារមាសយ៉ាងជ្រៅ ហើយស្ទាបរកខ្សែរបស់កង។ **ហាមទាញខ្សែទាំងនោះឡើង។** ប្រសិនបើស្ទាបរកខ្សែមិនប៉ះ ឬប៉ះផ្នែករឹងរបស់កងនោះ គាត់ចាំបាច់ប្រើស្រោមអនាម័យ ឬមធ្យោបាយពន្យារកំណើតផ្សេងទៀត រហូតដល់បុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល ពិនិត្យមើលកងរបស់គាត់។ សម្រាប់ពត៌មានស្តីពីកងដាក់ក្នុងស្បូន សូមអានទំ. ២៩០។

ជំងឺរលាកអាងត្រគាក គឺជាបញ្ហាធ្ងន់ធ្ងរបំផុត ដែលអាចបណ្តាលមកពីការដាក់កងក្នុងស្បូន។ ការបង្ករោគភាគច្រើនកើតឡើងក្នុងអំឡុងពេល៣ខែដំបូង ដែលជាទូទៅបណ្តាលមកពីស្ត្រីនោះ មានការបង្ករោគស្រាប់ នៅពេលដែលដាក់កងចូល។ ឬវាអាចកើតឡើងដោយសារបុគ្គលិកសុខាភិបាលបានដាក់កងដោយគ្មានអនាម័យ។ ប្រសិនបើស្ត្រីដែលដាក់កងមានសញ្ញាបង្ករោគណាមួយ គាត់គួរតែទៅជួបបុគ្គលិកសុខាភិបាលជាបន្ទាន់។ ចូរអានទំព័រទី ២៤៣។

**ថ្នាំចាក់ពន្យារកំណើត**

(ម៉ាកដែលគេនិយមប្រើ ៖ *ថ្នាំចាក់ពន្យារកំណើតOK*)

ឈ្មោះ:______________តម្លៃ_________

ថ្នាំចាក់ពន្យារកំណើត ធ្វើការទប់ស្កាត់ទៅលើអូវែរស្ត្រី កុំឲ្យបញ្ចេញពង។ អ័រម៉ូន ក៏ធ្វើឲ្យភ្នាសរំអិលនៅមាត់ស្បូនឡើងក្រាស់ ដែលជួយទប់ស្កាត់មេជីវិតឈ្មោល មិនឲ្យចូលទៅក្នុងស្បូនបាន។

ការចាក់ថ្នាំពន្យារកំណើតដែលមានផ្ទុកតែអ័រម៉ូនprogestin ដូចជា Depo-Provera និងNoristerat មានតែជាតិprogestin តែប៉ុណ្ណោះ។ ការប្រើថ្នាំពន្យារកំណើតប្រភេទនេះ ផ្តល់ផលល្អដល់ស្ត្រីដែលកំពុងបំបៅដោះកូន ប៉ុន្តែវាមិនគួរប្រើដោយស្ត្រីដែលមានបញ្ហាសុខភាពណាមួយ ដូចបានរៀបរាប់ក្នុងទំព័រ ២៨៨ ទេ។ ថ្នាំចាក់ពន្យារកំណើតប្រភេទនេះ ភាគច្រើនធ្វើឲ្យរដូវមកមិនទៀង។ ស្ត្រីដែលប្រើថ្នាំចាក់ពន្យារកំណើតប្រភេទនេះ អាចធ្វើមានឈាមរដូវតិចៗរៀងរាល់ថ្ងៃ ឬយូរៗម្តង។ គាត់នឹងអាចលែងមានឈាមរដូវ នៅចុងឆ្នាំដំបូង។ ការប្រែប្រួលទាំងនេះ គឺជាការធម្មតាទេ។

ថ្នាំចាក់ពន្យារកំណើតដែលផ្សំបញ្ចូលគ្នា ដូចជា Lunelle ឬ Cyclofem មានផ្ទុកទាំងអ័រម៉ូន estrogen និង progestin។ ការចាក់ថ្នាំពន្យារកំណើតប្រភេទនេះ ល្អចំពោះស្ត្រីដែលចង់បានរដូវមកទៀង។ ចំពោះស្ត្រីដែលកំពុងបំបៅដោះកូន និងស្ត្រីដែលមានបញ្ហាសុខភាពណាមួយ ដូចបានរៀបរាប់ក្នុងទំព័រទី ២៨៨ មិនគួរប្រើថ្នាំចាក់ពន្យារកំណើតផ្សំទេ។ ថ្នាំចាក់ពន្យារកំណើតផ្សំ ត្រូវចាក់រៀងរាល់ខែ មានតំលៃថ្លៃជាងថ្នាំចាក់ដែលមានតែអ័រម៉ូនprogestin ហើយវាមានការលំបាកក្នុងការរកទិញទៀតផង។

ស្ត្រីដែលប្រើថ្នាំចាក់ពន្យារកំណើតពីរប្រភេទខាងលើនេះ ជួនកាលឡើងទម្ងន់ និងឈឺក្បាល ប៉ុន្តែផលរំខានទាំងនេះ នឹងបាត់ទៅវិញ ក្រោយពីចាក់បានពីរបីដង។ ស្ត្រីអាចឈប់ប្រើមធ្យោបាយចាក់ថ្នាំពន្យារកំណើត គ្រប់ពេលដែលគាត់ចង់បាន។ ប៉ុន្តែក្រោយពេលគាត់ឈប់ចាក់ គាត់ត្រូវការរយៈពេលមួយឆ្នាំ ឬច្រើនជាងនេះ ដើម្បីអាចមានផ្ទៃពោះ និងមករដូវរាល់ខែវិញបានដូចធម្មតា។ ប្រសិនបើគាត់ឈប់ចាក់ថ្នាំពន្យារកំណើត ហើយមិនទាន់ចង់បានកូនភ្លាមៗ នោះគាត់ត្រូវមធ្យោបាយពន្យារកំណើតណាមួយផ្សេងទៀត។

**<u>កងដាក់នៅដៃ</u>**

(ម៉ាកដែលគេនិយមប្រើ ៖ *Norplant, Implanon, Jadelle*)

កងដាក់នៅដៃ ធ្វើការទប់ស្កាត់ទៅលើអូវែរស្ត្រី កុំឲ្យបញ្ចេញពង។ អ័រម៉ូនក៏ធ្វើឲ្យភ្នាសរំអិលនៅមាត់ស្បូន ឡើងក្រាស់ផងដែរ ដែលជួយទប់ស្កាត់មេជីវិតឈ្មោល មិនឲ្យចូលទៅក្នុងស្បូនបាន។ កងដាក់នៅដៃ អាចប្រើបានចំពោះស្ត្រីដែលកំពុងបំបៅដោះកូន ប៉ុន្តែមិនគួរប្រើចំពោះស្ត្រីដែលមានបញ្ហាសុខភាពណាមួយ ដូចបានរៀបរាប់នៅទំព័រទី ២៨៨ ទេ។ Norplant មាន ៦បំពង់ ហើយការពារកុំឲ្យមានផ្ទៃពោះរយៈពេល ៥-៧ ឆ្នាំ។ Jadelle មាន ២បំពង់ ហើយអាចការពារកុំឲ្យមានផ្ទៃពោះរយៈពេល ៥ ឆ្នាំ។ Implanon មាន១បំពង់ ហើយការពារកុំឲ្យមានផ្ទៃពោះរយៈពេល៣ឆ្នាំ។ នៅតាមបណ្តាប្រទេសជាច្រើន Jadelle និងImplanon ពិបាករកទិញជាង Norplant។

នៅក្នុងអំឡុងពេល ១ ឆ្នាំ ដំបូង កងដាក់នៅដៃ អាចធ្វើឲ្យមានការធ្លាក់ឈាមរដូវមិនទៀង ឬ ធ្លាក់ឈាមច្រើនថ្ងៃក្នុងពេលមករដូវ។ ស្ត្រីអាចលែងមានការធ្លាក់ឈាមរដូវ ប៉ុន្តែនេះមិនមែនមានន័យថា គាត់មានផ្ទៃពោះ ឬមានបញ្ហាអ្វីនោះឡើយ។ ស្ត្រីក៏អាចឡើងទម្ងន់ ឬឈឺក្បាល ប៉ុន្តែការផ្លាស់ប្តូរទាំងនេះ តែងតែបាត់ទៅវិញ នៅពេលដែលរាងកាយរបស់គាត់ ទម្លាប់ទៅនឹងអ័រម៉ូនប្រភេទនោះ។

ស្ត្រីអាចសម្រេចចិត្តយកកងដាក់នៅដៃនោះចេញ នៅពេលណាក៏បាន ប៉ុន្តែគាត់ត្រូវរកបុគ្គលិកសុខាភិបាលណាដែលចេះយកវាចេញដោយសុវត្ថិភាព។ បន្ទាប់ពីយកវាចេញហើយ ស្ត្រីអាចមានទម្ងន់វិញភ្លាមៗ ដូចនេះគាត់នឹងត្រូវប្រើមធ្យោបាយពន្យារកំណើតផ្សេងទៀត បើគាត់មិនទាន់ចង់បានកូនទេ។

ចូរសរសេរនៅត្រង់ទំព័រនេះ អំពីព័ត៌មានថ្នាំពេទ្យ ឬឱសថបុរាណផ្សេងទៀត ដែលមានប្រយោជន៍នៅក្នុងតំបន់របស់អ្នក។